# គណិតវិទ្យា

# មេរៀនសង្ខេប និង លំហាត់

## គន្លឹះដោះស្រាយលំហាត់

# សមីការ និងវិសមីការ



## សម្រាប់ត្រៀមប្រឡងប្រជែងនានា

ស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ

ឆ្នាំ ២០១៥

# អារម្ភកថា

សៀវភៅ **សមីការ វិសមីការ និងប្រព័ន្ធវិសមីការ** នេះសម្រាប់សិស្សថ្នាក់ទី **៧-៨-៩-១០** សិស្សសិក្សាទូទៅ និងនិស្សិត ដែលអ្នកសិក្សាកំពុងកាន់នៅក្នុងដៃនេះ គឺជាស្នាដៃលើកដំបូងដែលពួកយើងខ្ញុំបាននិពន្ធ និងរៀបរៀងឡើងក្នុងគោលបំណង ទុកជាឯកសារសម្រាប់អ្នកសិក្សា ដែលមានបំណងចង់សិក្សាស្រាវជ្រាវ ចង់ចេះ ចង់យល់ដឹងអំពីមេរៀននេះឱ្យបានកាន់តែច្បាស់ និងម្យ៉ាងទៀតដើម្បីជាជំនួយដល់អ្នកសិក្សាដែលមានបំណងត្រៀមប្រឡងសិស្សពូកែផ្នែកគណិតវិទ្យាថ្នាក់ទី៩ និងប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ។

នៅក្នុងសៀវភៅនេះ ពួកយើងខ្ញុំបានខិតខំស្រាវជ្រាវជ្រើសរើសយកនូវរូបមន្ត ទ្រឹស្តីបទ និងលំហាត់យ៉ាងសម្រាំងបំផុត យកមកធ្វើការសរសេរ និងបកស្រាយយ៉ាងលម្អិត ដែលអាចឱ្យលោកអ្នកងាយយល់ឆាប់ចងចាំអំពីវិធីសាស្រ្តនៃការដោះស្រាយ និងស្រាយបំភ្លឺទាំងអស់ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏កង្វះខាត និងកំហុសឆ្គងដោយអចេតនាដែលបានកើតឡើង ក៏គង់តែមានជាពុំខាន ទាំងផ្នែកបច្ចេកទេស និងអក្ខរាវិរុទ្ធ ។ អាស្រ័យហេតុនេះ ពួកយើងខ្ញុំដែលជាអ្នករៀបរៀង រង់ចាំដោយក្តីសោមនស្សរីករាយជានិច្ចនូវមតិរិះគន់ ក្នុងន័យស្ថាបនាពីសំណាកអ្នកសិក្សាក្នុងគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីជួយកែលំអសៀវភៅនេះឱ្យកាន់តែមានភាពសុក្រឹតថែមមួយកម្រិតទៀត ។

ចុងបញ្ចប់នេះ ពួកក្រុមយើងខ្ញុំដែលជាអ្នកនិពន្ធ និងរៀបរៀងសូមគោរពអរគុណ និងជូនពរដល់អ្នកសិក្សាទាំងអស់ ឱ្យមានសុខភាពល្អ កម្លាំងពលំមាំមួន ប្រាជ្ញាវាងវៃ និងទទួលជ័យជំនះគ្រប់ភារកិច្ច ។

**បាត់ដំបង, ថ្ងៃទី ៣០ ខែកក្កដា ព.ស ២៥៥៩ / គ.ស ២០១៥**


**រៀបរៀង និងចងក្រងដោយ**

**គរុសិស្សខេត្ត ពោធិ៍សាត់**

១. លោក **ខៀវ សុទីន** (០៩៦ ២៨ ៣០ ៧៣៧)

២.លោក **ទូច គីមហៃ** (០៩៦ ៧៣ ៣៣ ៥៩៥)

៣. លោក **មី ឃឿន** (០៩៦ ៧២ ៦៤ ៩៦៧)


© **រក្សាសិទ្ធិគ្រប់យ៉ាង**

**សូមអរគុណ!**

# សេចក្តីថ្លែងអំណរគុណ

ពួកយើងខ្ញុំទាំងអស់គ្នាដែលជាគរុសិស្ស **១២+២ ជំនាន់ទី២៥ ឆ្នាំទី២** ឯកទេស **គណិត-រូបវិទ្យា** នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តបាត់ដំបង សូមសម្តែងនូវសេចក្តីដឹងគុណចំពោះលោកអ្នកមានគុណទាំងពីរ ដែលលោកបានផ្តល់កំណើតដល់យើងខ្ញុំ ព្រមទាំងខំចិញ្ចឹមបីបាច់ថែរក្សាពួកខ្ញុំដោយដៃរបស់លោកផ្ទាល់ មិនត្រឹមតែប៉ុណ្ណោះ ញើសឈាមរបស់លោកដែលបានបញ្ចេញដើម្បីពួកខ្ញុំទាំងប៉ុន្មាន បានក្លាយជាកម្លាំងចលករ អូសទាញយិតយោងពួកខ្ញុំឲ្យចាកឆ្ងាយពីភាពអវិជ្ជា ហើយក្លាយជាមនុស្សដែលមានតម្លៃក្នុងជីវិត រហូតដល់សម្រេចបាននូវសមិទ្ធផលដ៏ធំធេងក្នុងឆាកជីវិតដូចសព្វថ្ងៃនេះ ពោលគឺអាជីពជាគ្រូបង្រៀន ។ ហើយយើងខ្ញុំក៏សូមសម្តែងការដឹងគុណ និងអរគុណផងដែរចំពោះ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បងប្អូនប្រុសស្រី និងចាស់ព្រឹទ្ធាចារ្យទាំងអស់ ចាប់តាំងពីថ្ងៃដំបូងនៃការចូលរៀនរបស់ពួកខ្ញុំរហូតមកដល់សព្វថ្ងៃនេះ ពួកលោកប្រៀបបានជាអ្នកមានគុណទីពីររបស់ពួកខ្ញុំដែរ ព្រោះរាល់អនុសាសន៍ណែនាំរបស់លោក រួមផ្សំនឹងចំណេះដឹងដែលលោកប្រគល់ឲ្យ បានបំភ្លឺនូវខ្សែជីវិតរបស់ខ្ញុំឲ្យមានរស្មីឡើង សមដូចពាក្យមួយឃ្លានិយាយថា « គ្រូបង្រៀន គឺជាអ្នកបង្កើតពន្លឺបំភ្លឺទីងងឹត » ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះបុព្វបុរសខ្មែរយើងដែលបាន ចងក្រងនូវកម្រងស្នាដៃល្អៗ ជាច្រើនដែលជួយដល់ការស្រាវជ្រាវរបស់ពួកយើងខ្ញុំ និងដកស្រង់នូវឧត្តមគតិល្អៗដើម្បីបញ្ចូលក្នុងឯកសាររបស់ពួកយើងខ្ញុំ ។

សារជាថ្មីម្តងទៀតនេះ យើងទាំងអស់គ្នាក៏សូមថ្លែងអំណរគុណចំពោះលោកគ្រូ **ឈាន ហាង** និងលោកគ្រូ **សាង តិដា** លោកទាំងពីរគឺជាគ្រូបង្រៀនគណិតវិទ្យា (**ចំណេះដឹង និងវិធីសាស្ត្របង្រៀន**) ប្រចាំមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តបាត់ដំបង ដែលលោកទាំងពីរបានផ្តល់នូវចំណេះដឹងថ្មីៗជាច្រើនផ្នែកគណិតវិទ្យា និងវិធីសាស្ត្របង្រៀនគណិតវិទ្យា សីលធម៌រស់នៅ ក៏ដូចជាសីលធម៌វិជ្ជាជីវៈជាគ្រូបង្រៀនផ្តល់នូវចំណេះដឹងផ្នែកសង្គមខាងក្រៅ ដែលជាដើមទុនដ៏សំខាន់ ធ្វើឱ្យពួកយើងខ្ញុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើជាគ្រូបង្រៀនក្នុងពេលឆាប់ៗខាងមុខនេះ ។

ជាចុងក្រោយ ពួកយើងខ្ញុំសូមថ្លែងអំណរគុណដល់លោកគ្រូអ្នកគ្រូទាំងអស់ដែលបានបង្រៀនពួកយើងខ្ញុំចាប់តាំងពី **ថ្នាក់ទី ០១ ដល់ទី ១២** និងលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ គ្រូឧទ្ទេស នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគបាត់ដំបងទាំងអស់ដែលបានបណ្តុះបណ្តាលពួកយើងខ្ញុំកន្លងមក ។ ហើយក៏សូមជូនពរលោកអ្នកដ៏មានគុណទាំងពីរ លោកយាយលោកតា ពុកម៉ែមាមីងបងប្អូន អ្នកសិក្សាទូទៅគ្រប់កម្រិតថ្នាក់ លោកនាយក លោកស្រីនាយិការង សាស្ត្រាចារ្យ គ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូទាំងអស់ឱ្យជួបតែជោគជ័យគ្រប់ភារកិច្ច ៕

**សូមអរគុណ** !

# មាតិកា


- អារម្ភកថា.......................................................i
- សេចក្តីថ្លែងអំណរគុណ..........................................ii
- មាតិកា.........................................................iii

**មេរៀនទី១ សមីការ**

I. **សមភាព**.....................................................១

II. **សមីការដឺក្រេទី១មានមួយអញ្ញាត**...............................១

១.សញ្ញាណសមីការដឺក្រេទី១មានមួយអញ្ញាត...........................១

២. ឫសសមីការដឺក្រេទី១មានមួយអញ្ញាត..............................១

៣.ដោះស្រាយសមីការដឺក្រេទី១មានមួយអញ្ញាត..........................២

III. **សមីការដឺក្រេទី២មានមួយអញ្ញាត**...............................៦

១.សញ្ញាណសមីការដឺក្រេទី២មានមួយអញ្ញាត...........................៦

២.ដោះស្រាយសមីការដឺក្រេទី២មានមួយអញ្ញាត..........................៦

៣.ទនាក់ទំនងឫស និងមេគុណឫស......................................១០

IV. **សមីការដែលមានរាងផ្សេងៗ**.....................................១៣

១.សមីការប៊ីការេ................................................១៣

២.សមីការដែលមានអញ្ញាតនៅភាគបែង..................................១៤

៣.សមីការដែលមានអញ្ញាតជាស្វ័យគុណ.................................១៥

៤.សមីការអេសនិទាន..............................................១៧

៥.សមីការច្រើនអថេរ..............................................១៨

៦.ដោះស្រាយសមីការដឺក្រេទី៣តាមវិធីបន្ថែមបន្ថយតួ.....................២០

V. **ចំណោទសមីការ**................................................២១

❖ **លំហាត់សមីការ**................................................២៦

## មេរៀនទី២ វិសមីការ និងប្រព័ន្ធវិសមីការ


I. **វិសមភាព**..........៣២

II. **វិសមីការដឺក្រេទី១មានមួយអញ្ញាត**..........៣៤

១.សញ្ញាណវិសមីការដឺក្រេទី១មានមួយអញ្ញាត..........៣៤

២.ដោះស្រាយវិសមីការដឺក្រេទី១មានមួយអញ្ញាត..........៣៤

III. **ដោះស្រាយប្រព័ន្ធវិសមីការដឺក្រេទី១មានមួយអញ្ញាត**..........៣៧

១.ដោះស្រាយប្រព័ន្ធវិសមីការដោយប្រើលក្ខណៈវិសមភាព..........៣៧

២.ដោះស្រាយប្រព័ន្ធវិសមីការ តាមសញ្ញាទ្វេធា..........៣៩

IV. **វិសមីការដឺក្រេទី២មានមួយអញ្ញាត**..........៤០

១.សញ្ញាណវិសមីការដឺក្រេទី២មានមួយអញ្ញាត..........៤០

២. ដោះស្រាយវិសមីការដឺក្រេទី២ តាមសញ្ញាត្រីធាដឺក្រេទី២..........៤១

V. **ដោះស្រាយប្រព័ន្ធវិសមីការដឺក្រេទី២មានមួយអញ្ញាត**..........៤៤

VI. **អនុវត្តន៍វិសមីការ**..........៤៦

VII. **ចំណោទវិសមីការ**..........៤៩

❖ **លំហាត់វិសមីការ និងប្រព័ន្ធវិសមីការ**..........៥០


## « ដំណោះស្រាយលំហាត់ »


❖ **ដំណោះស្រាយលំហាត់ សមីការ**..........៥៧

❖ **ដំណោះស្រាយលំហាត់វិសមីការ និងប្រព័ន្ធវិសមីការ**..........១២២

# មេរៀនទី១ សមីការ

## I. សមភាព

បើគេមាន: $a=b$ ,$(a,b\in\mathbb{R})$

នោះ $a+c=b+c$

$a-c=b-c$

$a\times c=b\times c$

$a\div c=b\div c$ ដែល $c\neq 0$ និង $c$ ជាចំនួនពិត ។

ឧទាហរណ៍: បើគេមាន: $5=5$ នាំឱ្យ $5+2=5+2$

$7=7$ ពិត

ឬ $5-2=5-2$

$3=3$ ពិត

ឬ $5\times 2=5\times 2$

$10=10$ ពិត

ឬ $5\div 2=5\div 2$

$\frac{5}{2}=\frac{5}{2}$ ពិត ។

## II. សមីការដឺក្រេទី១មានមួយអញ្ញាត

### 1. សញ្ញាណសមីការដឺក្រេទី១មានមួយអញ្ញាត

បើយើងឱ្យកន្សោមពីជគណិត $ax+b=0$ ឬ $ax+b=c$ គេហៅកន្សោមនេះថា សមីការដឺក្រេទី១មានមួយអញ្ញាត ដែល $a,b,c\in\mathbb{R}$ ,$a\neq 0$ ។

ឧទាហរណ៍: $3x+5=0$ , $\frac{1}{7}x-\frac{10}{15}=7$ , $\sqrt{2}x+\frac{\sqrt{2}}{3}=3$ ,... ហៅថា *សមីការដឺក្រេទី១មានមួយអញ្ញាត* ។

*ជាទូទៅ:* សមីការដឺក្រេទី១មានមួយអញ្ញាតមានទម្រង់ $ax+b=c$ ដែល $a, b, c$ ជាចំនួនថេរ $a\neq 0$ , $x$ ជាអញ្ញាត ។

### 2. ឫសសមីការដឺក្រេទី១មានមួយអញ្ញាត

ឧបមាថាយើងមានសមីការ $x+7=9$

បើ $x=0$ នោះ $0+7=9$ មិនពិត

បើ $x=1$ នោះ $1+7=9$ មិនពិត

បើ $x=2$ នោះ $2+7=9$ ពិត

បើ $x=3$ នោះ $3+7=9$ មិនពិត

ដូចនេះ: $x=2$ នាំឱ្យសមីការផ្ទៀងផ្ទាត់ គេថា $x=2$ ជាឫសរបស់សមីការ ។

ឧទាហរណ៍: រកឫសនៃសមីការ $5x+1=6$

បើ $x=0$ នោះ $5\times 0+1=6$ មិនពិត

បើ $x=1$ នោះ $5\times 1+1=6$ ពិត

បើ $x=2$ នោះ $5\times2+1=6$ មិនពិត

ដូចនេះ $x=1$ ធ្វើឱ្យសមីការក្លាយជាសមភាពពិត នោះ $x=1$ ជាឫសនៃសមីការ ។

### 3. ដោះស្រាយសមីការដឺក្រេទី១មានមួយអញ្ញាត

*វិធាន:* ដើម្បីដោះស្រាយសមីការដឺក្រេទី១មានមួយអញ្ញាត គេត្រូវរកតម្លៃអញ្ញាតរបស់វាគឺត្រូវបំបាត់គ្រប់តម្លៃលេខទាំងអស់ដែលនៅជាប់អញ្ញាត ឱ្យនៅសល់តែអញ្ញាត១គត់ស្មើនឹងចំនួនណាមួយ ។

a) *ដោះស្រាយសមីការដោយប្រើវិធីបូក ឬដក*

*ឧទាហរណ៍:* ដោះស្រាយសមីការខាងក្រោម ៖

ក. $x-2=1$

$x-2+2=1+2$ ( បូកអង្គទាំងពីរនឹង $2$ )

$x=3$

ផ្ទៀងផ្ទាត់: បើ $x=3$ នោះ $x-2=1$

$3-2=1$

$1=1$ ពិត

ដូចនេះ $x=3$ ជាឫសរបស់សមីការ ។

ខ. $x+10=21$

$x+10-10=21-10$ ( ដកអង្គទាំងពីរនឹង $10$ )

$x=11$

ផ្ទៀងផ្ទាត់: បើ $x=11$ នោះ $x+10=21$

$11+10=21$

$21=21$ ពិត

ដូចនេះ $x=11$ ជាឫសរបស់សមីការ ។

b) *ដោះស្រាយសមីការដោយប្រើវិធីគុណ ឬចែក*

ឧទាហរណ៍: ដោះស្រាយសមីការខាងក្រោម ៖

ក. $\frac{t}{4}=2$

$\frac{t}{4}\times4=2\times4$ ( គុណអង្គទាំងពីរនឹង $4$ ) នោះ $t=8$

ដូចនេះ $t=8$ ជាឫសនៃសមីការ ។

ខ. $7.2=3x$

$\frac{7.2}{3}=\frac{3x}{3}$ ( ចែកអង្គទាំងពីរនឹង $3$ ) នោះ $2.4=x$

ដូចនេះ $x=2.4$ ជាឫសនៃសមីការ ។

c) *ដោះស្រាយសមីការដោយប្រើវិធីចម្រុះ* ( *ជាវិធីដែលយើងប្រើជាទូទៅ* )

ឧទាហរណ៍: ដោះស្រាយសមីការខាងក្រោម ៖

ក. $2x-50=60$

$2x=60+50$

$2x=110$

$x=\dfrac{110}{2}=55$

ដូចនេះ $x=55$ ជាឫសនៃសមីការ ។

ខ. $5x-(7x-4)-2=5-(3x+2)$

$5x-7x+4-2=5-3x-2$

$-2x+2=-3x+3$

$-2x+3x=3-2$

$x=1$

ដូចនេះ $x=1$ ជាឫសនៃសមីការ ។

*វិធាន:* ដើម្បីដោះស្រាយសមីការដឺក្រេទី១មានមួយអញ្ញាត គេត្រូវទាញអង្គដែលមានអញ្ញាតមកអង្គម្ខាង ហើយរុញអង្គដែលគ្មានអញ្ញាតទៅអង្គម្ខាងទៀតដោយប្តូរសញ្ញា ។ បើសញ្ញាបូក$(+)$ ប្តូរទៅដក$(-)$ , ដក$(-)$ ប្តូរទៅបូក$(+)$ , គុណ$(\times)$ ប្តូរទៅចែក$(\div)$ ,ចែក$(\div)$ប្តូរទៅគុណ$(\times)$ ។

## d) *ដោះស្រាយសមីការដែលមានភាគបែងជាលេខ*

*វិធាន:* ដើម្បីដោះស្រាយសមីការដែលមានភាគបែងជាលេខ គេត្រូវ រកភាគបែងរួមរបស់វា ( $PPCM$ នៃភាគបែង ) រួចតម្រូវភាគបែង ហើយលុបភាគបែងរួមចោល រួចដោះស្រាយសមីការតាមធម្មតា ។

ឧទាហរណ៍: ដោះស្រាយសមីការខាងក្រោម ៖

ក. $\dfrac{x}{2}+\dfrac{x-3}{4}=\dfrac{1}{6}$

ដោយ $2=2$ , $4=2^2$, $6=3\times 2$ នាំឱ្យ $PPCM(2,4,6)=2^2\times 3=12$ ជាភាគបែងរួមនៃសមីការ ។

គេបាន $\dfrac{6x}{2\times 6}+\dfrac{3(x-3)}{4\times 3}=\dfrac{2}{6\times 2}$

$\dfrac{6x+3x+9}{12}=\dfrac{2}{12}$

$6x+3x+9=2$

$9x=-7$ នោះ $x=-\dfrac{7}{9}$

ដូចនេះ $x=-\dfrac{7}{9}$ ជាឫសនៃសមីការ ។

ខ. $\dfrac{x-5}{4}-\dfrac{x+7}{12}=\dfrac{1}{8}$

ដោយ $4=2^2$ , $12=2^2\times 3$, $8=2^3$ នាំឱ្យ $PPCM(4,12,8)=2^3\times 3=24$ ជាភាគបែងរួមនៃសមីការ ។

គេបាន: $\dfrac{(x-5)6}{4\times 6}-\dfrac{(x+7)2}{12\times 2}=\dfrac{3}{8\times 3}$

$\dfrac{6x-30-2x-14}{24}=\dfrac{3}{24}$

$4x-44=3 \Rightarrow x=\dfrac{47}{4}$

ដូចនេះ $x=\dfrac{47}{4}$ ជាឫសនៃសមីការ ។

e) ដោះស្រាយសមីការប៉ារ៉ាម៉ែតដឺក្រេទី១មានមួយអញ្ញាត

**វិធាន:** សមីការដឺក្រេទី១មានមួយអញ្ញាតក្រោយពីបង្រួមរួចហើយមានទម្រង់ $ax=b$

$x$ ជាអញ្ញាត:

i. បើ $a\neq 0$ , $b\neq 0$ សមីការមានឫសតែមួយគត់គឺ $x=\dfrac{b}{a}$ ។

ii. បើ $a\neq 0$ , $b=0$ សមីការមានឫសតែមួយគត់គឺ $x=0$ ។

iii. បើ $a=0$ , $b\neq 0$ សមីការមានទម្រង់ $0x=b$ នោះសមីការគ្មានឫស ។

iv. បើ $a=0$ , $b=0$ សមីការមានទម្រង់ $0x=0$ នោះសមីការមាននឫសច្រើនរាប់មិនអស់ ។

ឧទាហរណ៍ទី១ គេឱ្យសមីការ $(m-1)x+5m=2mx+2$ ។

ក. រកតម្លៃ $m$ ដើម្បីឱ្យសមីការមានឫសមួយគត់ខុសពីសូន្យ ។

ខ. រកតម្លៃ $m$ ដើម្បីឱ្យសមីការមានឫសច្រើនរាប់មិនអស់ ។

គ. រកតម្លៃ $m$ ដើម្បីឱ្យសមីការមានឫសមួយគត់ស្មើសូន្យ ។

ឃ. រកតម្លៃ $m$ ដើម្បីឱ្យសមីការគ្មានឫស ។

ចម្លើយ

ដោយសមីការ $(m-1)x+5m=2mx+2$

អាចសរសេរជា $(m-1)x-2mx=2-5m$

$-mx-x=2-5m$

$x(m+1)=5m-2$

ក. រកតម្លៃ $m$ ដើម្បីឱ្យសមីការមានឫសមួយគត់ខុសពីសូន្យ

ដើម្បីឱ្យសមីកាមានឫសមួយគត់ខុសពីសូន្យកាលណា $\begin{cases} m+1\neq 0 \\ 5m-2\neq 0 \end{cases} \Leftrightarrow \begin{cases} m\neq -1 \\ m\neq \dfrac{2}{5} \end{cases}$

ដូចនេះ: $m\neq -1$ និង $m\neq \dfrac{2}{5}$ នាំឱ្យសមីការមានឫសមួយគត់ខុសពីសូន្យ ។

ខ. រកតម្លៃ $m$ ដើម្បីឱ្យសមីការមានឫសច្រើនរាប់មិនអស់

ដើម្បីឱ្យសមីការមានឫសច្រើនរាប់មិនអស់កាលណា $\begin{cases} m+1=0 \\ 5m-2=0 \end{cases} \Leftrightarrow \begin{cases} m=-1 \\ m=\dfrac{2}{5} \end{cases}$

ដូចនេះ: $m=-1$ និង $m=\dfrac{2}{5}$ នាំឱ្យសមីការមានឫសច្រើនរាប់មិនអស់ ។

គ. រកតម្លៃ $m$ ដើម្បីឱ្យសមីការមានឫសមួយគត់ស្មើសូន្យ

ដើម្បីឱ្យសមីការមានឫសមួយគត់ស្មើសូន្យកាលណា $5m-2=0$ ឬ $m=\dfrac{2}{5}$

ដូចនេះ: $m=\dfrac{2}{5}$ នាំឱ្យសមីការមានឫសមួយគត់ស្មើសូន្យ ។

ឃ. រកតម្លៃ $m$ ដើម្បីឱ្យសមីការគ្មានឫស

ដើម្បីឱ្យសមីការគ្មានឫសកាលណា $m-1=0$ ឬ $m=1$

ដូចនេះ: $m=1$ នាំឱ្យសមីការគ្មានឫស ។

ឧទាហរណ៍ទី២ ដោះស្រាយ និងពិភាក្សាសមីការ $mx+7m=x+3$ ( $m$ ជាប៉ារ៉ាម៉ែត ) ។

ចម្លើយ

គេមានសមីការ $mx+7m=x+3$

$$mx-x=3-7m$$
$$(m-1)x=3-7m$$

- បើ $\begin{cases} m-1\neq 0 \\ 3-7m\neq 0 \end{cases} \Leftrightarrow \begin{cases} m\neq 1 \\ m\neq \frac{3}{7} \end{cases}$ នាំឱ្យសមីការមានឫសខុសពីសូន្យគឺ: $x=\frac{3-7m}{m-1}$
- បើ $\begin{cases} m-1=0 \\ 3-7m=0 \end{cases} \Leftrightarrow \begin{cases} m=1 \\ m=\frac{3}{7} \end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់
- បើ $m-1=0$ ឬ $m=1$ នាំឱ្យសមីការមានរាង $0x=-4$ នោះសមីការគ្មានឫស
- បើ $3-7m=0$ ឬ $m=\frac{3}{7}$ នាំឱ្យសមីការមានរាង $-\frac{4}{7}x=0$ នោះសមីការមានឫសមួយគត់ស្មើសូន្យ ។

សន្និដ្ឋាន:

- សមីការមានឫស $x=\frac{3-7m}{m-1}$ ខុសពីសូន្យកាលណា $m\neq 1$ និង $m\neq\frac{3}{7}$ ។
- សមីការមានឫសច្រើនរាប់មិនអស់ កាលណា $m=1$ និង $m=\frac{3}{7}$ ។
- សមីការគ្មានឫស កាលណា $m=\frac{3}{7}$ ។
- សមីការមានឫសមួយគត់ស្មើសូន្យ កាលណា $m=1$ ។

ឧទាហរណ៍ទី៣ ដោះស្រាយ និងពិភាក្សាសមីការ $7(m-1)x+5=3mx+2x+7$ ( $m$ ជាប៉ារ៉ាម៉ែត ) ។

ចម្លើយ

គេមានសមីការ $7(m-1)x+5=3mx+2x+7$

$$7mx-7x-3mx-2x=7-5$$
$$(4m-9)x=2$$

- បើ $4m-9=0$ ឬ $m=\frac{9}{4}$ នាំឱ្យសមីការមានរាង $0x=2$ នោះសមីការគ្មានឫស
- បើ $4m-9\neq 0$ ឬ $m\neq\frac{9}{4}$ នាំឱ្យសមីការមានឫស១គត់គឺ $x=\frac{2}{4m-9}$

សន្និដ្ឋាន:

- សមីការគ្មានឫស កាលណា $m=\frac{9}{4}$ ។
- សមីការមានឫស១គត់ខុសពីសូន្យ កាលណា $m\neq\frac{9}{4}$ គឺ $x=\frac{2}{4m-9}$ ។

* បញ្ជាក់: ដោយសមីការក្រោយពេលបង្រួមហើយមានតួ $b=2$ ជាចំនួនពិតថេរស្រាប់ ដូចនេះ យើងសិក្សាតែតួ $a=4m-9$ ដែលមានប៉ារ៉ាម៉ែត តែប៉ុណ្ណោះ ( ព្រោះ $b\neq 0$ ជានិច្ច ) ។

ឧទាហរណ៍ទី៤ ដោះស្រាយ និងពិភាក្សាសមីការ $7x+m+3=2x-m-5$ ។

ចម្លើយ

គេមានសមីការ $7x+m+3=2x-m-5$

$7x-2x=-m-5-m-3$

$5x=-2m-8$

– បើ $-2m-8=0$ ឬ $m=-4$ នាំឱ្យសមីការមានរាង $5x=0$ នោះសមីការឫសតែ១គត់គឺ $x=0$

– បើ $-2m-8\neq 0$ ឬ $m\neq -4$ នាំឱ្យនោះសមីការឫសតែ១គត់គឺ $x=\dfrac{-2m-8}{5}$

<u>សន្និដ្ឋាន</u>

– សមីការឫសតែ១គត់ $x=0$ កាលណា $m=-4$ ។

– សមីការឫសតែ១គត់ខុសពីសូន្យ $x=\dfrac{-2m-8}{5}$ កាលណា $m\neq -4$ ។

## III. សមីការដឺក្រេទី២មានមួយអញ្ញាត

### 1. សញ្ញាណដឺក្រេទី២មានមួយអញ្ញាត

***ជាទូទៅ:*** សមីការដឺក្រេទី២មានមួយអញ្ញាតជាសមីការដែលមានទម្រង់ $ax^2+bx+c=0$ ដែល $(a\neq 0)$ $a, b, c$ ជាចំនួនពិត , $x$ ជាអញ្ញាត ។

<u>ឧទាហរណ៍:</u> $x^2+7x+\frac{1}{2}=0$ , $2x^2-2x+-3=0$, $x^2-9=0$ ជាសមីការដឺក្រេទី២មានមួយអញ្ញាត ។

### 2. ដោះស្រាយសមីការដឺក្រេទី២មានមួយអញ្ញាត

a) *ដោះស្រាយសមីការដោយប្រើផលគុណកត្តា*

***ជាទូទៅ:*** ផលគុណនៃពីរកត្តាស្មើសូន្យ កាលណាកត្តាណាមួយស្មើសូន្យ ។
$A\times B=0$ លុះត្រាតែ $A=0\vee B=0$ ។

<u>ឧទាហរណ៍:</u> ដោះស្រាយសមីការខាងក្រោម ៖

ក. $x^2-2x-8=0$

$\Leftrightarrow (x-4)(x+2)=0$

$\Leftrightarrow \begin{cases} x-4=0 \\ x+2=0 \end{cases} \Leftrightarrow \begin{cases} x=4 \\ x=-2 \end{cases}$

ដូចនេះ $\boxed{x=4 \text{ ឬ } x=-2 \text{ ជាឫសនៃសមីការ}}$ ។

ខ. $(3x-1)^2-25x^2=0$

$(3x-1)^2-(5x)^2=0$

$(3x-1-5x)(3x-1+5x)=0$

$(-2x-1)(8x-1)=0$

នាំឱ្យ $\begin{cases} -2x-1=0 \\ 8x-1=0 \end{cases} \Leftrightarrow \begin{cases} x=-\frac{1}{2} \\ x=\frac{1}{8} \end{cases}$

ដូចនេះ $\boxed{x=-\frac{1}{2} \text{ ឬ } x=\frac{1}{8} \text{ ជាឫសនៃសមីការ}}$ ។

គ. $(x-4)(x+1)=-4$

$x^2+x-4x-4+4=0$

$x^2-3x=0$

$(x-3)x=0$

នាំឱ្យ $x=0$ ឬ $x-3=0 \Rightarrow x=3$

ដូចនេះ $\boxed{x=0 \text{ ឬ } x=3 \text{ ជាឫសនៃសមីការ}}$ ។

b) ***ដោះស្រាយសមីការតាមលក្ខណៈឫសការេ***

| |
|---|
| ***ជាទូទៅ:*** សមីការ $x^2=b$ ដែល $b$ ជាចំនួនពិតវិជ្ជមាន មានឫសពីរផ្ទុយគ្នា គឺ $x=\pm\sqrt{b}$ ។ |

<u>ឧទាហរណ៍:</u> ដោះស្រាយសមីការខាងក្រោម ៖

ក. $(x-2)^2=9$

$x-2=\pm\sqrt{9}$

$x=\pm3+2$

ដូចនេះ $\boxed{x=5 \text{ ឬ } x=-1 \text{ ជាឫសនៃសមីការ}}$ ។

ខ. $3(5x+4)^2-81=0$

$3(5x+4)^2=81$

$(5x+4)^2=27$

$5x+4=\pm\sqrt{27}$

$5x=-4\pm3\sqrt{3}$

$x=\dfrac{-4\pm3\sqrt{3}}{5}$

ដូចនេះ $\boxed{x=\dfrac{-4\pm3\sqrt{3}}{5} \text{ ជាឫសនៃសមីការ}}$ ។

គ. $x^2-6x+9=16$

$(x-3)^2=16$

$x-3=\pm\sqrt{16}$

$x=3\pm4$

ដូចនេះ $\boxed{x=7 \text{ ឬ } x=-1 \text{ ជាឫសនៃសមីការ}}$ ។

ឃ. $x^2+8=1$

$x^2=-7$ សមីការគ្មានឫសក្នុងសំណុំចំនួនពិតទេព្រោះ $x^2>0, \forall x\in\mathbb{R}$ ។

c) ***ដោះស្រាយសមីការដោយបំពេញជាការេទ្វេធា***

| |
|---|
| ***ជាទូទៅ:*** ដើម្បីបំពេញជាការេទ្វេធាចំពោះកន្សោម $x^2+bx$ គេបូកនឹង $\left(\dfrac{b}{2}\right)^2$ ដែលជាការេនៃពាក់កណ្ដាលមេគុណនៃ $x$ ។ ហើយគេបាន $x^2+bx+\left(\dfrac{b}{2}\right)^2=\left(x+\dfrac{b}{2}\right)^2$ ។ |

<u>ឧទាហរណ៍:</u> ដោះស្រាយសមីការខាងក្រោម ៖

ក. $x^2+5x+2=0$

$x^2+5x+\left(\dfrac{5}{2}\right)^2+2-\dfrac{25}{4}=0$

$\left(x+\dfrac{5}{2}\right)^2-\dfrac{17}{4}=0$

ខ. $2x^2-x-2=0$

$2\left(x^2-\dfrac{1}{2}x-1\right)=0$

$x^2-\dfrac{1}{2}x-1+\left(\dfrac{1}{4}\right)^2-\left(\dfrac{1}{4}\right)^2=0$

$\left(x+\frac{5}{2}\right)^2=\frac{17}{4}$

$x+\frac{5}{2}=\pm\sqrt{\frac{17}{4}}$

$x=\pm\sqrt{\frac{17}{4}}-\frac{5}{2}$

$x=\frac{\pm\sqrt{17}-5}{2}$

ដូចនេះ $\boxed{x=\frac{\pm\sqrt{17}-5}{2}\text{ ជាឫសនៃសមីកា}}$ ។

$\left(x-\frac{1}{4}\right)^2-\frac{17}{16}=0$

$\left(x-\frac{1}{4}\right)^2=\frac{17}{16}$

$x-\frac{1}{4}=\pm\sqrt{\frac{17}{16}}$

$x=\pm\sqrt{\frac{17}{16}}+\frac{1}{4}$

ដូចនេះ $\boxed{x=\frac{\pm\sqrt{17}+1}{4}\text{ ជាឫសនៃសមីការ}}$ ។

គ. $x^2-4x+8=0$

$x^2-4x+2^2+8-4=0$

$(x-2)^2=-4<0$ នាំឱ្យសមីការគ្មានឫស ។

d) ***ដោះស្រាយសមីការដឺក្រេទី២តាមឌីសគ្រីមីណង់***

❖ សមីការដឺក្រេទី២មានមួយអញ្ញាតមានទម្រង់ $ax^2+bx+c=0,\ a\neq 0$

* មានឌីសគ្រីមីណង់ $\Delta=b^2-4ac$

i. បើ $\Delta>0$ សមីការមានឫសពីរផ្សេងគ្នាគឺ: $x_1=\frac{-b-\sqrt{\Delta}}{2a}$ , $x_2=\frac{-b+\sqrt{\Delta}}{2a}$

ii. បើ $\Delta=0$ សមីការមានឫសឌុបគឺ: $x_1=x_2=\frac{-b}{2a}$

iii. បើ $\Delta<0$ សមីការគ្មានឫសក្នុងចំនួនពិតទេ តែមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់ចាប់ពីថ្នាក់ទី១០ឡើង គឺ: $x_1=\frac{-b-i\sqrt{-\Delta}}{2a}$ , $x_2=\frac{-b+i\sqrt{-\Delta}}{2a}$ ជាប់ជាអនុគមន៍ $i$ ដែល $i^2=-1$ ជាឯកតានិមិត្ត ។

* បើ $b$ ជាចំនួនគូ គេបាន $\Delta'=(b')^2-ac$ ដែល $b'=\frac{b}{2}$

i. បើ $\Delta'>0$ សមីការមានឫសពីរផ្សេងគ្នាគឺ: $x_1=\frac{-b'-\sqrt{\Delta'}}{a}$ , $x_2=\frac{-b'+\sqrt{\Delta'}}{a}$

ii. បើ $\Delta'=0$ សមីការមានឫសឌុបគឺ: $x_1=x_2=\frac{-b'}{a}$

iii. បើ $\Delta'<0$ សមីការគ្មានឫសក្នុងចំនួនពិតទេ តែមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់ចាប់ពីថ្នាក់ទី១០ឡើង គឺ: $x_1=\frac{-b'-i\sqrt{-\Delta'}}{a}$ , $x_2=\frac{-b'+i\sqrt{-\Delta'}}{a}$ ជាប់ជាអនុគមន៍ $i$ ដែល $i^2=-1$ ជាឯកតានិមិត្ត ។

<u>ឧទាហរណ៍:</u> ដោះស្រាយសមីការខាងក្រោម ៖

ក. $x^2-6x-7=0$

មាន $b'=\frac{-6}{2}=-3$

នាំឱ្យ $\Delta'=(b')^2-ac$

$=(-3)^2-1(-7)$

$=9+7=16$

នោះ $\sqrt{\Delta'}=\sqrt{16}=4$

គេបាន $x_1=\frac{-b'-\sqrt{\Delta'}}{a}=\frac{3-4}{1}=-1$

$x_2=\frac{-b'+\sqrt{\Delta'}}{a}=\frac{3+4}{1}=7$

ដូចនេះ: $x=-1$ ឬ $x=7$ ជាឫសសមីការ ។

ខ. $4x^2+3x+2=0$

មាន $\Delta=3^2-4\times4\times2$

$=9-32=-23<0$ សមីការគ្មានឫស

តែសម្រាប់ថ្នាក់ទី១០ឡើងមានឫសក្នុងសំណុំចំនួនកុំផ្លិច ។

នាំឱ្យ $\sqrt{\Delta}=\sqrt{-23}=i\sqrt{23}$

គេបាន $x=\frac{-3\pm i\sqrt{23}}{8}$ ជាឫសនៃសមីការក្នុង $\mathbb{C}$

ដូចនេះ: $x=\frac{-3\pm i\sqrt{23}}{8}$ ជាឫសរបស់សមីការ ។

ឃ. $2y^2+12y+19=0$

មាន $b'=\frac{12}{2}=6$

នោះ $\Delta'=6^2-2\times19$

$=36-38=-2<0$ សមីការគ្មានឫស តែសម្រាប់ថ្នាក់ទី១០ឡើងមានឫសក្នុងសំណុំចំនួនកុំផ្លិច ។

គ. $\frac{1}{9}x^2-\frac{2}{3}x+1=0$

ឬ $x^2-6x+9=0$

មាន $b'=\frac{-6}{2}=-3$

នាំឱ្យ $\Delta'=(b')^2-ac$

$=(-3)^2-1\times9$

$=9-9=0$

នោះសមីការមានឫសឌុប គឺ: $x_1=x_2=\frac{-b'}{a}=\frac{3}{1}=3$

ដូចនេះ: $x=3$ ជាឫសនៃសមីការ ។

**e) *អនុវត្តន៍សមីការដឺក្រេទី២មានមួយអញ្ញាត***

<u>ឧទាហរណ៍ទី១</u> រកតម្លៃ $k$ ដើម្បីឱ្យសមីការ $(k-2)x^2+(3k-6)x+2k-3=0$ មានឫសឌុប ហើយរកឫសឌុបនោះ ។

<u>ចម្លើយ</u>

យើងមានសមីការ $(k-2)x^2+(3k-6)x+2k-3=0$ មានន័យកាលណា $k-2\neq0$ ឬ $k\neq2$

មាន: $\Delta=(3k-6)^2-4(k-2)(2k-3)$

$=9k^2-36k+36-8k^2+28k-24$

$=k^2-8k+12$

ដើម្បីឱ្យសមីការមានឫសឌុប លុះត្រាតែ $\Delta = 0$

នោះ $k^2 - 8k + 12 = 0$

$\Delta'_k = (-4)^2 - 1\times 12 = 16 - 12 = 4 \Rightarrow \sqrt{\Delta'_k} = 2$ , យើងបាន

នោះ $k_1 = \frac{4+2}{1} = 6$ , $k_2 = \frac{4-2}{1} = 2$ មិនយក ( ព្រោះ $k \neq 2$ )

ដូចនេះ $\boxed{k = 6}$ ។

\+ រកឫសឌុបរបស់សមីការ

សមីការមានឫសឌុបគឺ: $x_0 = \frac{-b}{2a} = -\frac{3k-6}{2(k-2)}$

បើ $k = 6$ នោះ $x_0 = -\frac{3\times 6 - 6}{2(6-2)} = -\frac{12}{8} = -\frac{3}{2}$

ដូចនេះ $\boxed{k = 6 \text{ នាំឱ្យសមីការមានឫសឌុបគឺ: } x_0 = -\frac{3}{2}}$ ។

<u>ឧទាហរណ៍ទី២</u> រកតម្លៃ $k$ ដើម្បីឱ្យសមីការ $4x^2 - 2kx + k + 3 = 0$ មានឫសឌុប ហើយរកឫសឌុបនោះ ។

<u>ចម្លើយ</u>

គេមានសមីការ $4x^2 - 2kx + k + 3 = 0$

មាន $\Delta'_x = (-k)^2 - 4(k+3)$

$= k^2 - 4k - 12$

ដើម្បីឱ្យសមីការមានឫសឌុប កាលណា $\Delta'_x = 0$

នោះ $k^2 - 4k - 12 = 0$

នាំឱ្យ $\Delta'_k = (-2)^2 - 1\times(-12)$

$= 4 + 12 = 16$

នោះ $\sqrt{\Delta'_k} = 4$

គេបាន: $k_1 = \frac{2-4}{1} = -2$ , $k_2 = \frac{2+4}{1} = 6$

ឫសឌុបនៃសមីការគឺ: $x_0 = -\frac{b'_x}{a_x} = \frac{k}{4}$

- បើ $k = -2$ នោះ $x_0 = -\frac{2}{4} = -\frac{1}{2}$
- បើ $k = 6$ នោះ $x_0 = \frac{6}{4} = \frac{3}{2}$

ដូចនេះ $\boxed{k = -2 \text{ នោះ } x_0 = -\frac{1}{2} \text{ ឬ } k = 6 \text{ នោះ } x_0 = \frac{3}{2}}$ ។

## 3. ទំនាក់ទំនងឫស និងមេគុណ

### a) គណនាផលបូក ផលគុណឫស

**ជាទូទៅ:** បើ $\alpha$ , $\beta$ ជាឫសនៃសមីការដឺក្រេទី២ $ax^2 + bx + c = 0$ , $a \neq 0$ នោះ $S = \alpha + \beta = -\frac{b}{a}$

និង $P = \alpha \times \beta = \frac{c}{a}$ ។

ឧទាហរណ៍ទី១ រកផលបូក និងផលគុណឫសនៃសមីការខាងក្រោម ៖

ក. $x^2-13x+42=0$ នោះ $\begin{cases}\alpha+\beta=-\dfrac{b}{a}=\dfrac{13}{1}=13\\ \alpha\times\beta=\dfrac{c}{a}=\dfrac{42}{1}=42\end{cases}$

ខ. $2x^2+3x-7=0$ នោះ $\begin{cases}\alpha+\beta=-\dfrac{b}{a}=-\dfrac{3}{2}\\ \alpha\times\beta=\dfrac{c}{a}=-\dfrac{7}{2}\end{cases}$

ឧទាហរណ៍ទី២ បើ $\alpha$ , $\beta$ ជាឫសនៃសមីការ $2x^2+8x+3=0$ ។ គណនា:

ក. $\alpha^2\beta+\alpha\beta^2$ ខ. $\alpha^2+\beta^2$

ចម្លើយ

ដោយ $\alpha$ , $\beta$ ជាឫសនៃសមីការ $2x^2+8x+3=0$

នាំឱ្យ $\alpha+\beta=-\dfrac{b}{a}=-\dfrac{8}{4}=-2$ , $\alpha\beta=\dfrac{c}{a}=\dfrac{3}{2}$

គណនា:

ក. $\alpha^2\beta+\alpha\beta^2=\alpha\beta(\alpha+\beta)=\dfrac{3}{2}\times(-4)=-6$

ដូចនេះ $\boxed{\alpha^2\beta+\alpha\beta^2=-6}$ ។

ខ. $\alpha^2+\beta^2=(\alpha+\beta)^2-2\alpha\beta=(-4)^2-2\times\dfrac{3}{2}=13$

ដូចនេះ $\boxed{\alpha^2+\beta^2=13}$ ។

b) ដោះស្រាយសមីការដឺក្រេទី២ផាយ

ឧទាហរណ៍: ដោះស្រាយសមីការខាងក្រោម ៖

ក. $x^2-5x+6=0$

ដោយ $x^2-5x+6=0$

$2+3 \quad 2\times3$

ដូចនេះ $\boxed{x=2 \text{ ឬ } x=3 \text{ ជាឫសសមីការ}}$ ។

ខ. $x^2-8x+12=0$

ដោយ $x^2-8x+12=0$

$6+2 \quad 6\times2$

ដូចនេះ $\boxed{x=6 \text{ ឬ } x=2 \text{ ជាឫសសមីការ}}$ ។

c) ដោះស្រាយសមីការដោយស្គាល់ឫសមួយទាញរកឫសមួយទៀត

សមីការដឺក្រេទី២មានមួយអញ្ញាត មានទម្រង់ $ax^2+bx+c=0$ , $a\neq0$

- បើ $a+b+c=0$ នាំឱ្យសមីការមានឫស២គឺ: $x_1=1$, $x_2=\dfrac{c}{a}$
- បើ $a-b+c=0$ នាំឱ្យសមីការមានឫស២គឺ: $x_1=-1$, $x_2=-\dfrac{c}{a}$ ។

ឧទាហរណ៍: ដោះស្រាយសមីការខាងក្រោម ៖

ក. $\frac{4}{x-2}-\frac{x-3}{x+4}=0$

$\frac{4(x+4)-(x-3)(x-2)}{(x-2)(x+4)}=0 \quad ; x\neq 2, x\neq -4$

$4x+16-\left(x^2-5x+6\right)=0$

$4x+16-x^2-5x+6=0$

$-x^2+9x+10=0$

មាន $a=-1$ , $b=9$ , $c=10$

នាំឱ្យ $a-b+c=-1-9+10=0$

សមីការមានឫសពីរគឺ: $x_1=-1$ , $x_2=-\frac{c}{a}=\frac{-10}{-1}=10$

ដូចនេះ $x=-1$ ឬ $x=10$ ជាឫសនៃសមីការ ។

ខ. $2x^2+7x-9=0$

មាន $a=2$ , $b=7$ , $c=-9$

នាំឱ្យ $a+b+c=2+7-9=0$

សមីការមានឫសពីរគឺ: $x_1=1$ , $x_2=\frac{c}{a}=-\frac{9}{2}$

ដូចនេះ $x_1=1$ ឬ $x_2=-\frac{9}{2}$ ជាឫសនៃសមីការ ។

d) ***សរសេរសមីការដឺក្រេទី២មានមួយអញ្ញាតជាផលគុណកត្តា***

**ជាទូទៅ:** បើសមីការ $ax^2+bx+c=0$ មា នឫសពីរផ្សេងគ្នាគឺ $\alpha$ និង $\beta$ នោះកន្សោម $ax^2+bx+c=a(x-\alpha)(x-\beta)$ ។

**បញ្ជាក់:** បើសមីការមានឫសឌុប $\alpha$ គេបាន $ax^2+bx+c=a(x-\alpha)^2$ ។

ឧទាហរណ៍: ដាក់កន្សោមខាងក្រោមជាផលគុណកត្តា ៖

ក. $x^2+2x-1$

បើ $x^2+2x-1=0$

មាន $\Delta'=1+1=2 \Rightarrow \sqrt{\Delta'}=\sqrt{2}$

នាំឱ្យ $x_1=-1-\sqrt{2}$ , $x_2=-1+\sqrt{2}$

ដូចនេះ $x^2+2x-1=\left(x+1-\sqrt{2}\right)\left(x+1+\sqrt{2}\right)$ ។

ខ. $-2x^2-3x+2$

បើ $-2x^2-3x+2=0$

មាន $\Delta=9+16=25 \Rightarrow \sqrt{\Delta}=5$

នាំឱ្យ $x_1=\frac{3-5}{-4}=\frac{1}{2}$ , $x_2=\frac{3+5}{-4}=-2$

ដូចនេះ $-2x^2-3x+2=(-2x+1)(x+2)$ ។

e) ***បង្កើតសមីការដឺក្រេទី២ ដោយស្គាល់ផលបូក និងផលគុណឫស***

**ជាទូទៅ:** សមីការដឺក្រេទី២ ដែលមានឫសពីរផ្សេងគ្នាគឺ $\alpha$ និង $\beta$ ដែល $S=\alpha+\beta$ និង $P=\alpha\beta$ កំណត់ដោយ $X^2-SX+P=0$ ។

ឧទាហរណ៍ទី១ រកសមីការដឺក្រេទី២ដែលមានឫស $\alpha=3+2\sqrt{2}$ , $\beta=3-2\sqrt{2}$ ។

ចម្លើយ

ដោយ $S=\alpha+\beta=3+2\sqrt{2}+3-2\sqrt{2}=6$

$P=\alpha\beta=\left(3+2\sqrt{2}\right)\left(3-2\sqrt{2}\right)=9-8=1$

នាំឱ្យសមីការដែលត្រូវរកគឺ: $X^2-SX+P=0\Leftrightarrow X^2-6X+1=0$

ដូចនេះ $X^2-6X+1=0$ ជាសមីការដែលត្រូវរក ។

*ឧទាហរណ៍ទី២* សមីការ $x^2-2x+7=0$ មានឫស $\alpha$ និង $\beta$ ។ រកសមីការដឺក្រេទី២ ដែលមានឫស $\alpha+2$ និង $\beta+2$ ។

*ចម្លើយ*

ដោយ $\alpha$ និង $\beta$ ជាឫសរបស់សមីការ $x^2-2x+7=0$ នោះ $\begin{cases}\alpha+\beta=-\dfrac{b}{a}=2\\ \alpha\beta=\dfrac{c}{a}=7\end{cases}$

នាំឱ្យ $S=(\alpha+2)+(\beta+2)=(\alpha+\beta)+4=2+4=6$

$P=(\alpha+2)(\beta+2)=\alpha\beta+2(\alpha+\beta)+4=7+4+4=15$

ដូចនេះ សមីការដែលត្រូវរកគឺ: $X^2-6X+15=0$ ។

ឧទាហរណ៍ទី៣ រកពីរចំនួនដោយស្គាល់ផលបូកស្មើ 20 និង ផលគុណស្មើ 51 ។

ចម្លើយ

តាង $\alpha$ ជាចំនួនទី1 , $\beta$ ជាចំនួនទី 2

តាមបម្រាប់: $\begin{cases}\alpha+\beta=20\\ \alpha\beta=51\end{cases}$ នាំឱ្យ $\alpha$ និង $\beta$ ជាឫសនៃសមីការ $X^2-20X+51=0$

មាន: $\Delta'=(-10)^2-51=100-51=49$ នោះ $\sqrt{\Delta'}=7$

នាំឱ្យ $\alpha=\dfrac{10-7}{1}=3$ , $\beta=\dfrac{10+7}{1}=17$

ដូចនេះ $(\alpha=3\ ,\ \beta=17)$ ឬ $(\beta=3\ \ \alpha=17)$ ជាចំនួនដែលត្រូវរក ។

## IV. សមីការដែលមានរាងផ្សេងៗ

### 1. សមីការប៊ីការេ

*សមីការប៊ីការេ* ជាសមីការដែលមានទម្រង់ $ax^4+bx^2+c=0$ ដែល $a\neq 0$ ។ ដើម្បីដោះស្រាយសមីការនេះគេត្រូវ តាង $t=x^2$ , $t>0$ សមីការទៅជា $at^2+bt+c=0$ រួចដោះស្រាយវាតាមសមីការដឺក្រេទី២ គេនឹងបានតម្លៃ $t_1$ , $t_2$ រួចយកទៅជំនួសក្នុង $t=x^2$ នោះគេបានឫសរបស់សមីការគឺ: $\begin{cases}x^2=t_1\\ x^2=t_2\end{cases}\Leftrightarrow\begin{cases}x=\pm\sqrt{t_1}\\ x=\pm\sqrt{t_2}\end{cases}$ ជាឫសរបស់សមីការ ។

*ឧទាហរណ៍:* ដោះស្រាយសមីការខាងក្រោម ៖

ក. $x^4-2x^2-15=0$

តាង $t=x^2$ , $t>0$ , គេបានសមីការ

$t^2-2t-15=0$

មាន $\Delta'=(-1)^2-1(-15)=16\Rightarrow\sqrt{\Delta'}=\sqrt{16}=4$

នោះ $t_1=\frac{1-4}{1}=-3<0$ (មិនយក) , $t_2=\frac{1+4}{1}=5$

គេបាន $x^2=5\Rightarrow x=\pm\sqrt{5}$

ដូចនេះ $x=\pm\sqrt{5}$ ជាឫសនៃសមីការ ។

ខ. $x^4-16x^2+16=0$

តាង $t=x^2,\ t>0$

$t^2-16t+16=0$

មាន $\Delta'=(-8)^2-1(16)=64-16=48>0\Rightarrow\sqrt{\Delta'}=\sqrt{48}=4\sqrt{3}$

នោះ $t_1=\frac{16-4\sqrt{3}}{1}=16-4\sqrt{3}$

$t_2=\frac{16+4\sqrt{3}}{1}=16+4\sqrt{3}$

បើ $t=16-4\sqrt{3}$ នោះ $x^2=16-4\sqrt{3}$

ឬ $x=\pm\sqrt{16-4\sqrt{3}}=\pm2\sqrt{4-\sqrt{3}}$

បើ $t=16+4\sqrt{3}$ នោះ $x^2=16+4\sqrt{3}$

ឬ $x=\pm\sqrt{16+4\sqrt{3}}=\pm2\sqrt{4+\sqrt{3}}$

ដូចនេះ $x=\pm2\sqrt{4-\sqrt{3}}$ ឬ $x==\pm2\sqrt{4+\sqrt{3}}$ ជាឫសនៃសមីការ ។

* ***បញ្ជាក់:*** សមីការដឺក្រេទី២ $at^2+bt+c=0$ អាចដោះស្រាយតាមវិធីណាក៏បានឱ្យតែឃើញតម្លៃ $t_1$ , $t_2$ តាមអ្វីដែលយើងបានសិក្សាកន្លងមក ។

## 2. សមីការដែលមានអញ្ញាតនៅភាគបែង

*វិធាន:* ដើម្បីដោះស្រាយសមីការដែលមានអញ្ញាតនៅភាគបែងគេត្រូវ:

- ឱ្យលក្ខខណ្ឌភាគបែងខុសពីសូន្យ
- តម្រូវភាគបែងរួម រួចលុបភាគបែងចោល
- ដោះស្រាយសមីការតាមធម្មតា ។

*បញ្ជាក់:* ឫសដែលរកឃើញជាន់នឹងលក្ខខណ្ឌមិនយក ។

ឧទាហរណ៍: ដោះស្រាយសមីការខាងក្រោម ៖

ក. $\frac{x+4}{x-4}-\frac{x-4}{x+4}=\frac{32}{(x-4)(x+4)}$

លក្ខខណ្ឌ: សមីការមានន័យកាលណា $\begin{cases}x-4\neq0\\x+4\neq0\end{cases}\Leftrightarrow\begin{cases}x\neq4\\x\neq-4\end{cases}$ , យើងបាន

$\frac{(x+4)^2-(x-4)^2}{(x-4)(x+4)}=\frac{32}{(x-4)(x+4)}$

$x^2+8x+16-x^2+8x-16=32$

$16x=32$ ឬ $x=2$

ដូចនេះ $x=2$ ជាឫសនៃសមីការ ។

ខ. $\frac{3x}{x-1}-\frac{2}{x+1}=1$

លក្ខខណ្ឌ: សមីការមានន័យកាលណា $\begin{cases}x-1\neq 0\\ x+1\neq 0\end{cases}\Leftrightarrow\begin{cases}x\neq 1\\ x\neq -1\end{cases}$ , យើងបាន

$$\frac{3x(x+1)-2(x-1)}{(x-1)(x+1)}=1$$

$$3x^2+3x-2x+2=x^2-1$$

$$2x^2+x+3=0$$

មាន $\Delta=1-24=-23<0$

ដូចនេះ **សមីការគ្មានឫស** ។

គ. $\frac{3x-4}{x-2}+\frac{3-x}{3+x}=\frac{3x^2+x}{(x-2)(3+x)}$

លក្ខខណ្ឌ: សមីការមានន័យកាលណា $\begin{cases}x-2\neq 0\\ x+3\neq 0\end{cases}\Leftrightarrow\begin{cases}x\neq 2\\ x\neq -3\end{cases}$ , យើងបាន

$$\frac{(3x-4)(x+3)+(3-x)(x-2)}{(x-2)(x+3)}=\frac{3x^2+x}{(x-2)(x+3)}$$

$$3x^2+9x-12-4x+3x-6-x^2+2x=3x^2+x$$

$$-x^2+9x-18=0$$

មាន $\Delta=9^2-4(-18)(-1)=9\Rightarrow\sqrt{\Delta}=3$

នោះ $x_1=\frac{-9-3}{-2}=6$ , $x_2=\frac{-9+3}{-2}=3$

ដូចនេះ **$x=6$ ឬ $x=3$ ជាឫសនៃសមីការ** ។

## 3. សមីការដែលមានអញ្ញាតជាស្វ័យគុណ ( សមីការអ៊ិចស្ប៉ូណង់ស្យែល )

*ជាទូទៅ:* ដើម្បីដោះស្រាយសមីការដែលមានទម្រង់ $a^x=b\ ,b>0$ គេត្រូវបម្លែងវាឱ្យទៅជា $a^x=a^y$ នោះយើងបាន $x=y$ រួចដោះស្រាយសមីការតាមធម្មតា ។

❖ *រំលឹករូបមន្តស្វ័យគុណ*

1. $a^m\times a^n=a^{m+n}$
2. $\frac{a^m}{a^n}=a^{m-n}$ , $a\neq 0$
3. $(a^m)^n=a^{mn}$
4. 
5. $\left(\frac{a}{b}\right)^n=\frac{a^n}{b^n}$ , $b\neq 0$
6. $\left(\frac{a}{b}\right)^{-n}=\left(\frac{b}{a}\right)^n=\frac{b^n}{a^n}$ , $a\neq 0, b\neq 0$
7. $a^{-n}=\frac{1}{a^n}$ , $a\neq 0$
8. $a^0=1$
9. $10^{-n}=0.\underbrace{000...0001}_{n \text{ ជាចំនួនខ្ទង់ក្រោយក្បៀស}}$
10. $\sqrt[n]{a^m}=a^{\frac{m}{n}}$
11. $\sqrt[n]{\sqrt[k]{a}}=\sqrt[nk]{a}=a^{\frac{1}{nk}}$
12. $10^n=1\underbrace{000...000}_{0 \text{ ជាចំនួនខ្ទង់នៃ } n}$

ឧទាហរណ៍: ដោះស្រាយសមីការខាងក្រោម ៖

ក. $4^x+5=2^x+17$

$\Leftrightarrow (2^x)^2-2^x-17+5=0$

$\Leftrightarrow (2^x)^2-2^x-12=0$

តាង $t=2^x$ , $t>0$ , គេបាន

$t^2-t-12=0$

$\Leftrightarrow t^2+3t-4t-12=0$

$\Leftrightarrow t(t+3)-4(t+3)=0$

$\Leftrightarrow (t+3)(t-4)=0$

$\Rightarrow \left[\begin{array}{l} t+3=0 \\ t-4=0 \end{array}\right. \Leftrightarrow \left[\begin{array}{l} t=-3<0 \text{ មិនយក} \\ t=4 \end{array}\right.$

បើ $t=4$ នោះ $2^x=4 \Leftrightarrow 2^x=2^2 \Rightarrow x=2$

ដូចនេះ $\boxed{x=2 \text{ ជាឫសនៃសមីការ}}$ ។

ខ. $4^{x+1}\times 2^x=\sqrt{8}$

$\Leftrightarrow 2^{2(x+2)}\times 2^x=\sqrt{2^3}$

$\Leftrightarrow 2^{2x+4+x}=2^{\frac{3}{2}}$

$\Leftrightarrow 3x+4=\frac{3}{2}$

$\Leftrightarrow 3x=\frac{3}{2}-4$

$\Rightarrow x=-\frac{5}{6}$

ដូចនេះ $\boxed{x=-\frac{5}{6} \text{ ជាឫសនៃសមីការ}}$ ។

គ. $25^x+15^x=2\cdot 9^x$

$\Leftrightarrow \left(\frac{25}{9}\right)^x+\left(\frac{15}{9}\right)^x=2$ ( ចែកអង្គទាំងពីរនឹង $9^x$ )

$\Leftrightarrow \left(\frac{5}{3}\right)^{2x}+\left(\frac{5}{3}\right)^x-2=0$

តាង $t=\left(\frac{5}{3}\right)^x$ , $t>0$ , គេបាន

$t^2+t-2=0$

មាន: $a+b+c=0$

$\Rightarrow \left[\begin{array}{l} t_1=1 \\ t_2=\frac{c}{a} \end{array}\right. \Leftrightarrow \left[\begin{array}{l} t_1=1 \\ t_2=\frac{-2}{1}=-2 \text{ មិនយក} \end{array}\right.$

បើ $t=1$ នោះ $\left(\frac{5}{3}\right)^x=1 \Leftrightarrow \left(\frac{5}{3}\right)^x=\left(\frac{5}{3}\right)^0 \Rightarrow x=0$

ដូចនេះ $\boxed{x=0 \text{ ជាឫសនៃសមីការ}}$ ។

**4. សមីការអសនិទាន** ( *មានរ៉ាឌីកាល់សន្ទស្សន៍ពីរ* )

*វិធាន: ដើម្បីដោះស្រាយសមីការអសនិទានរ៉ាឌីកាលសន្ទស្សន៍ពីរ គេត្រូវ:*
- ឱ្យលក្ខខណ្ឌចំនួនក្នុងរ៉ាឌីកាល់ធំជាង ឬស្មើសូន្យ
- លើកអង្គទាំងពីរជាការេដើម្បីបំបាត់រ៉ាឌីកាល់
- ដោះស្រាយសមីការតាមធម្មតា រួចរកឫសរបស់សមីការដែលផ្ទៀងផ្ទាត់លក្ខខណ្ឌជាចម្លើយ ។

*ឧទាហរណ៍:* ដោះស្រាយសមីការខាងក្រោម ៖

ក. $\sqrt{2x-1}=\sqrt{x-1}+1$

លក្ខខណ្ឌ: $\begin{cases}2x-1\ge 0\\ x-1\ge 0\end{cases} \Leftrightarrow \begin{cases}x\ge \dfrac{1}{2}\\ x\ge 1\end{cases} \Rightarrow x\ge 1$

លើកអង្គទាំងពីរជាការេ , គេបាន

$\left(\sqrt{2x-1}\right)^2=\left(\sqrt{x-1}+1\right)^2$

$\Leftrightarrow 2x-1=x-1+2\sqrt{x-1}+1$

$\Leftrightarrow x-1=2\sqrt{x-1}$

$\Leftrightarrow (x-1)^2=\left(2\sqrt{x-1}\right)^2$ ( លើកអង្គទាំងពីរជាការេ )

$\Leftrightarrow x^2-2x+1=4x-4$

$\Leftrightarrow x^2-6x+5=0$

មាន: $a+b+c=0$ នោះ $x_1=1$ ឬ $x_2=\dfrac{c}{a}=\dfrac{5}{1}=5$

ដូចនេះ $\boxed{x=1 \text{ ឬ } x=5 \text{ ជាឫសនៃសមីការ}}$ ។

ខ. $\sqrt{x+3-\sqrt{x+5}}=2$

លក្ខខណ្ឌ: $\begin{cases}x+5\ge 0\\ x+3-\sqrt{x+5}>0\end{cases} \Leftrightarrow \begin{cases}x\ge -5\\ x-\sqrt{x+5}>-3\end{cases}$

លើកអង្គទាំងពីរជាការេ , គេបាន

$\left(\sqrt{x+3-\sqrt{x+5}}\right)^2=(2)^2$

$\Leftrightarrow x+3-\sqrt{x+5}=4$

$\Leftrightarrow x-1=\sqrt{x+5}$

$\Leftrightarrow (x-1)^2=\left(\sqrt{x+5}\right)^2$ ( លើកអង្គទាំងពីរជាការេ )

$\Leftrightarrow x^2-2x+1=x+5$

$\Leftrightarrow x^2-3x-4=0$

មាន: $a-b+c=0$ នោះ $x_1=-1$ ឬ $x_2=-\dfrac{c}{a}=-\dfrac{-4}{1}=4$

បើ $x=-1$ នោះ $x-\sqrt{x+5}>-3$

$-1-\sqrt{-1+5}>-3$

$-1-2>-3$

$-3>-3$ មិនពិត

បើ $x=4$ នោះ $x-\sqrt{x+5}>-3$

$4-\sqrt{4+5}>-3$

$4-3>-3$

$1>-3$ ពិត

ដូចនេះ $\boxed{x=4 \text{ ជាឫសនៃសមីការ}}$ ។

គ. $8+\sqrt{x-1}=6$

លក្ខខណ្ឌ: $x-1\geq 0 \Leftrightarrow x\geq 1$

$\sqrt{x-1}=6-8$

$\Leftrightarrow \sqrt{x-1}=-2<0$ គ្មានឫសព្រោះ គ្រប់ចំនួនដែលឋិតនៅរ៉ាឌីកាលត្រូវវិជ្ជមានជានិច្ច នោះតម្លៃវាក៏ត្រូវវិជ្ជមានដែរ ។

ឃ. $x-5=(6x+73)^{\frac{1}{2}}$

គេអាចសរសេរជា $x-5=\sqrt{6x+73}$ ព្រោះ $a^{\frac{m}{n}}=\sqrt[n]{a^m}$

លក្ខខណ្ឌ: $6x+73\geq 0 \Leftrightarrow x\geq -\frac{73}{6}$

លើកអង្គទាំងពីរជាការេ , គេបាន

$(x-5)^2=\left(\sqrt{6x+73}\right)^2$

$\Leftrightarrow x^2-10x+25=6x+73$

$\Leftrightarrow x^2-16x-48=0$

មាន: $\Delta'=16+48=64 \Rightarrow \sqrt{\Delta'}=8$

នោះ $x_1=\frac{4-8}{1}=-4$ , $x_2=\frac{4+8}{1}=12$

ដូចនេះ $\boxed{x=-4 \text{ ឬ } x=12 \text{ ជាឫសនៃសមីការ}}$ ។

## 5. សមីការមានច្រើនអថេរ

<u>*ឧទាហរណ៍ទី១*</u> ដោះស្រាយសមីការ $x+y=90$ ដោយដឹងថា $PGCD(x,y)=30$ ។

<u>*ចម្លើយ*</u>

ដោយ: $PPCD(x,y)=30$ នោះ $x=30a\ ,y=30b$

ដែល $PPCD(a,b)=1$ ឬ $a\ ,b$ ជាចំនួនបឋមរវាងគ្នា ។

គេបាន: $x+y=30a+30b=30(a+b)$ តែ $x+y=90$ ( សម្មតិកម្ម )

នោះ $a+b=3$ នាំឱ្យ $a=2,b=1$ ឬ $a=1,b=2$

បើ $a=2,b=1$ នោះ $x=60\ ,y=30$

បើ $a=1,b=2$ នោះ $x=30\ ,y=60$

ដូចនេះ $\boxed{(x=60\ ,y=30) \text{ ឬ } (x=30\ ,y=60) \text{ ជាឫសនៃសមីការ}}$ ។

ឧទាហរណ៍ទី២ រកតម្លៃ $x \& y$ ដោយដឹងថា $x^2 - y^2 = 1415$ និង $PGCD(x,y) = 17$ ។

ចម្លើយ

ដោយ: $PPCD(x,y) = 17$ នោះ $x = 17a$ , $y = 17b$

ដែល $PPCD(a,b) = 1$ ឬ $a$ ,$b$ ជាចំនួនបឋមរវាងគ្នា ។

គេបាន: $x^2 - y^2 = (17a)^2 - (17b)^2$ តែ $x^2 - y^2 = 1415$ ( សម្មតិកម្ម )

នោះ $17^2(a^2 - b^2) = 1415$ នាំឱ្យ $(a-b)(a+b) = 1 \times 5$

នោះគេបាន $a - b = 1$ $(1)$ និង $a + b = 5$ $(2)$

យក $(1)$ បូក $(2)$, យើងបាន $2a = 6 \Rightarrow a = 3$ នោះ $b = 2$

គេបាន: $x = 17 \times 3 = 51$ និង $y = 17 \times 2 = 34$

ដូចនេះ: $x = 51$ និង $y = 34$ ជាឫសនៃសមីការ ។

ឧទាហរណ៍ទី៣ ចូររកគូនៃចំនួនគត់រ៉ឺឡាទីប $(x\ ,y)$ ដែលផ្ទៀងផ្ទាត់ $x^2 - 249xy - 250y^2 = 6033$ ។

ចម្លើយ

គេមានសមីការ: $x^2 - 249xy - 250y^2 = 6033$

$$\Leftrightarrow \quad x^2 - y^2 - 249xy - 249y^2 = 3 \times 2011$$

$$\Leftrightarrow (x-y)(x+y) - 249y(x+y) = 3 \times 2011$$

$$\Leftrightarrow \quad (x+y)(x-y-249y) = 3 \times 2011$$

$$\Leftrightarrow \quad (x+y)(x-250y) = 3 \times 2011$$

ដោយសារតែតម្លៃ $x,y \in \mathbb{Z}$ នោះយើងមិនអាចកំណត់បានថា $x+y$ ឬ $x-250y$ មួយណាធំជាងនោះទេ

នោះយើងបាន: $\begin{cases} x+y=3 \\ x-250y=2011 \end{cases}$ $(*)$ ឬ $\begin{cases} x+y=2011 \\ x-250y=3 \end{cases}$ $(**)$

តាម $(*)$, យើងបាន $+\begin{cases} x+y=3 \\ x-250y=2011 \end{cases} \times(-1)$

$$251y = -2008$$

$$\Rightarrow y = -8$$

នាំឱ្យ $x = 3 - y = 3 - (-8) = 11$

តាម $(**)$, យើងបាន $+\begin{cases} x+y=2011 \\ x-250y=3 \ \times(-1) \end{cases}$

$$251y = 2008$$

$$\Rightarrow y = 8$$

នាំឱ្យ $x = 2011 - y = 2011 - 8 = 2003$

ដូចនេះ: គូចម្លើយនៃ $(x\ ,y)$ គឺ: $(11,-8)$ ឬ $(-11,8)$ ឬ $(2003,8)$ ឬ $(-2003,-8)$ ។

ឧទាហរណ៍ទី៤ ដោះស្រាយសមីការ $\sqrt{4\sqrt{3}-6} = \sqrt{x\sqrt{3}} - \sqrt{y\sqrt{3}}$ ។

លក្ខខណ្ឌ: $x > 0$ ,$y > 0$ ( ព្រោះ $\sqrt{x\sqrt{3}} - \sqrt{y\sqrt{3}} > 0$ )

លើកអង្គទាំងពីរជាការេ , យើងបាន $\left(\sqrt{4\sqrt{3}-6}\right)^2 = \left(\sqrt{x\sqrt{3}} - \sqrt{y\sqrt{3}}\right)^2$

$$\Leftrightarrow 4\sqrt{3} - 6 = x\sqrt{3} + y\sqrt{3} - 2\sqrt{3xy}$$

$$\Leftrightarrow\left(4-2\sqrt{3}\right)\sqrt{3}=\left(x+y-2\sqrt{xy}\right)\sqrt{3}$$

$$\Leftrightarrow\left(4-2\sqrt{3}\right)=\left(x+y-2\sqrt{xy}\right)$$

$$\Leftrightarrow\left(\sqrt{3}-1\right)^2=\left(\sqrt{x}-\sqrt{y}\right)^2\Rightarrow x=3\ ,\ y=1$$

ដូចនេះ $x=3$ ឬ $y=1$ ជាឫសនៃសមីការ ។

<u>*ឧទាហរណ៍ទី៩*</u> ដោះស្រាយសមីការ $x^2+\dfrac{1}{x^2}+y^2+\dfrac{1}{y^2}=4$ ។

$$\Leftrightarrow x^2-2+\frac{1}{x^2}+y^2-2+\frac{1}{y^2}=0$$

$$\Leftrightarrow\left(x-\frac{1}{x}\right)^2+\left(y-\frac{1}{y}\right)^2=0$$

$$\Rightarrow\begin{cases}x-\dfrac{1}{x}=0\\ y-\dfrac{1}{y}=0\end{cases}\Leftrightarrow\begin{cases}x=\dfrac{1}{x}\\ y=\dfrac{1}{y}\end{cases}\Leftrightarrow\begin{cases}x^2=1\\ y^2=1\end{cases}\Leftrightarrow\begin{cases}x=\pm1\\ y=\pm1\end{cases}$$

ដូចនេះ $(x=1,y=1)$ ឬ $(x=1,y=-1)$ ឬ $(x=-1,y=1)$ ឬ $(x=-1,y=-1)$ ជាឫសនៃសមីការ ។

## 6. ដោះស្រាយសមីការដឺក្រេទី៣តាមវិធីបន្ថែមបន្ថយតួ

* ដើម្បីដោះស្រាយសមីការដឺក្រេទី៣ $ax^3+bx^2+cx+d=0$ គេត្រូវដាក់វាជាផលគុណកត្តា ។
* យើងអាចរកឫសងាយរបស់សមីការដឺក្រេទី៣ ដោយប្រើទ្រឹស្តីបទកត្តា

តាង $f(x)=ax^3+bx^2+cx+d$

បើ $f(\alpha)=0$ នោះ $f(x)$ ចែកដាច់នឹង $x-\alpha$ ឱ្យលទ្ធផល $g(x)=a_1x^2+b_1x+c_1$

នោះគេបាន: $f(x)=(x-\alpha)g(x)$ ដោយ $f(x)=0\Rightarrow(x-\alpha)g(x)=0$

គេបាន: $\left[\begin{array}{l}x-\alpha=0\\ g(x)=0\end{array}\right.$ រួចដោះស្រាយធម្មតា ។

<u>*ឧទាហរណ៍:*</u> ដោះស្រាយសមីការខាងក្រោម ៖

ក. $x^3-2x^2-x+2=0$

តាង $f(x)=x^3-2x^2-x+2$

ដោយ $f(1)=1^3-2\times1^2-1+2=0$

គេបាន: $f(x)$ ចែកដាច់នឹង $x-1$

យើងបាន: $f(x)=(x-1)(x^2-x-2)$

តែ $f(x)=0$ នោះ: $(x-1)(x^2-x-2)=0$

នោះ: $x-1=0\Rightarrow x=1$

ឬ $x^2-x-2=0$

$(x+1)(x-2)=0$

$$\Rightarrow\left[\begin{array}{l}x-2=0\\ x+1=0\end{array}\right.\Leftrightarrow\left[\begin{array}{l}x=2\\ x=-1\end{array}\right.$$

ម្យ៉ាងទៀត: $x^3-2x^2-x+2=0$

ចែកពហុធា

$$\begin{array}{r|l} & x-1\\ x^2-x-2 & x^3-2x^2-x+2\\ & -x^2-x\\ & -2x+2\\ & 0\end{array}$$

$\left(x^3-2x^2\right)-\left(x-2\right)=0$

$x^2\left(x-2\right)-\left(x-2\right)=0$

$\left(x-2\right)\left(x^2-1\right)=0$

នាំឱ្យ $\left[\begin{array}{l} x-2=0 \\ x^2-1=0 \end{array}\right. \Leftrightarrow \left[\begin{array}{l} x=2 \\ x^2=1 \end{array}\right. \Leftrightarrow \left[\begin{array}{l} x=2 \\ x=\pm 1 \end{array}\right.$

ដូចនេះ $\boxed{x=\pm 1 \text{ ឬ } x=2 \text{ ជាឫសនៃសមីការ}}$ ។

ខ. $x^3+6x^2+11x+6=0$

តាង $f\left(x\right)=x^3+6x^2+11x+6$

ដោយ $f\left(-1\right)=\left(-1\right)^3+6\left(-1\right)^2-11+6=0$

គេបាន: $f\left(x\right)$ ចែកដាច់នឹង $x+1$

យើងបាន: $f\left(x\right)=\left(x+1\right)\left(x^2+5x+6\right)$

តែ $f\left(x\right)=0$ នោះ $\left(x+1\right)\left(x^2+5x+6\right)=0$

នោះ $x+1=0 \Rightarrow x=-1$

ឬ $x^2+5x+6=0$

$\left(x+2\right)\left(x+3\right)=0$

$\Rightarrow \left[\begin{array}{l} x+2=0 \\ x+3=0 \end{array}\right. \Leftrightarrow \left[\begin{array}{l} x=-2 \\ x=-3 \end{array}\right.$

ចែកពហុធា

$$\begin{array}{r|l} x^2+5x+6 & x^3+6x^2+11x+6 \\ \hline & x+1 \\ & 5x^2+11x \\ & 6x+6 \\ & 0 \end{array}$$

ម្យ៉ាងទៀត:

$x^3+6x^2+11x+6=0$

$x^3+x^2+5x^2+5x+6x+6=0$

$x^2\left(x+1\right)+5x\left(x+1\right)+6\left(x+1\right)=0$

$\left(x+1\right)\left(x^2+5x+6\right)=0$

$\left(x+1\right)\left(x+2\right)\left(x+3\right)=0$

នាំឱ្យ $\left[\begin{array}{l} x+1=0 \\ x+2=0 \\ x+3=0 \end{array}\right. \Leftrightarrow \left[\begin{array}{l} x=-1 \\ x=-2 \\ x=-3 \end{array}\right.$

ដូចនេះ $\boxed{x=-1 \text{ ឬ } x=-2 \text{ ឬ } x=-3 \text{ ជាឫសនៃសមីការ}}$ ។

## IV. ចំណោទសមីការ

☞ ដើម្បីដោះស្រាយចំណោទសមីការដឺក្រេទី១ មានមួយអញ្ញាតគេត្រូវ ៖

- ❖ តាងអញ្ញាត រួចឱ្យលក្ខខណ្ឌបើមាន
- ❖ សរសេរសមីការ
- ❖ ដោះស្រាយសមីការ
- ❖ ផ្ទៀងផ្ទាត់ចម្លើយ ។

*ឧទាហរណ៍:* ក. ម៉ារីមានអាយុ 8 ឆ្នាំ ច្រើនជាងអាយុបូណា។ ផលបូកអាយុរបស់ម៉ារី និងបូណាស្មើនឹង 38 ឆ្នាំ ។ ចូររកអាយុរបស់បូណា ។

*ចម្លើយ*

☞ រកអាយុរបស់បូណា:

តាង $x$ ជាអាយុរបស់បូណា

$x+8$ ជាអាយុរបស់ម៉ារី , $(0<x<38)$

ដោយផលបូកអាយុអ្នកទាំងពីរស្មើនឹង 38 ឆ្នាំ

គេបានសមីការ: $x+(x+8)=38$

$$x+x+8=38$$
$$2x=38-8$$
$$2x=30$$
$$x=\frac{30}{2}=15$$

ផ្ទៀងផ្ទាត់: $x+x+8=38$

$$15+15+8=38$$
$$38=38 \text{ ពិត}$$

*ដូចនេះ* **បូណាមានអាយុ 15 ឆ្នាំ** ។

*ឧទាហរណ៍:* ខ. គេយកសៀវភៅ 280 ក្បាល ទៅចែកដល់សិស្សមួយថ្នាក់ ។ ក្រោយពេលចែកសៀវភៅអស់គេសង្កេតឃើញថា សិស្សម្នាក់ៗទទួលបានសៀវភៅ 4 ក្បាល ។

កំណត់ចំនួនសិស្សនៅក្នុងថ្នាក់នោះ ?

*ចម្លើយ:*

☞ រកចំនួនសិស្សនៅក្នុងថ្នាក់នោះ

តាង $x$ ជាចំនួនសិស្សនៅក្នុងថ្នាក់ $(x>0)$

ដោយគេយកសៀវភៅចំនួន 280 ក្បាលទៅចែកសិស្សមួយថ្នាក់ ហើយសិស្សម្នាក់ៗទទួលបានសៀវភៅចំនួន 4 ក្បាល

នោះគេបានសមីការ: $4x=280$

$$4x=280$$

នោះ $x=\frac{280}{4}=70$

ផ្ទៀងផ្ទាត់: ចំពោះ $x=70$

គេបាន: $4x=280$

សមមូល $4\times 70=280 \Leftrightarrow 280=280$ ពិត

*ដូចនេះ* **នៅក្នុងថ្នាក់នោះមានសិស្សសរុបចំនួន 70 នាក់** ។

*ឧទាហរណ៍:* គ. នៅពេលបច្ចុប្បន្ននេះឪពុកមានអាយុ $42$ ឆ្នាំ ហើយកូនមានអាយុ $15$ ឆ្នាំ ។ តើនៅប៉ុន្មានឆ្នាំទៅមុខទៀតទើបអាយុឪពុកស្មើនឹង $2$ ដងអាយុកូន ?

*ចម្លើយ:*

☞ រករយៈពេលដែលអាយុឪពុកស្មើនឹង $2$ ដងអាយុកូន (គិតជាឆ្នាំ) ៖

តាង: $t$ ជារយៈពេលដែលអាយុឪពុកស្មើនឹងពីរដងអាយុកូន ,$(t>0)$

គេបាន: $t+15$ ជាអាយុកូននៅរយៈពេល $t$ ឆ្នាំទៅមុខទៀត

$t+42$ ជាអាយុឪពុកនៅរយៈពេល $t$ ឆ្នាំទៅមុខទៀត

ដោយនៅរយៈពេល $t$ ឆ្នាំទៅមុខទៀតអាយុឪពុកស្មើនឹង $2$ ដងអាយុកូន

នោះគេបានសមីការ: $t+42=2(t+15)$

$$t+42=2t+30$$
$$2t-t=42-30$$
$$t=12$$

ផ្ទៀងផ្ទាត់: ចំពោះ $t=12$ គេបាន:

$$t+42=2(t+15)$$
$$12+42=2(12+15)$$
$$54=54 \text{ ពិត}$$

ដូចនេះ $t=12$ ឆ្នាំទៅមុខទៀតទើបអាយុឪពុកស្មើនឹង $2$ ដងអាយុកូន ៕

*ឧទាហរណ៍:* ឃ. គេមានពីរចំនួនដែលមានផលដកស្មើនឹង $8$ ផលគុណនៃចំនួនទាំងពីរនោះស្មើនឹង $128$ ។ គណនាចំនួនទាំងពីរនោះ ។

*ចម្លើយ:*

☞ រកចំនួនទាំងពីរនោះ

តាង: $x$ ជាចំនួនទី១

$x+8$ ជាចំនួនទី២

ដោយផលគុណចំនួនទាំងពីរស្មើនឹង $128$

នោះគេបានសមីការ: $x(x+8)=128$

$$x^2+8x=128$$
$$x^2+8x-128=0$$

មាន: $\Delta'=4^2-1\times(-128)$

$=16+128=144>0$ ( មានឫសពីរផ្សេងគ្នា )

$$\sqrt{\Delta'}=\sqrt{144}=12$$

នាំឱ្យ: $x_1=\dfrac{-4-12}{1}=-16$ , $x_2=\dfrac{-4+12}{1}=8$

ចំពោះ $x=-16$ នោះ $x+8=-16+8=-8$

$x=8$ នោះ $x+8=8+8=16$

ផ្ទៀងផ្ទាត់: បើ $x=8$ នោះ $x+8=16$

នាំឱ្យ $8\times16=128$

$128=128$ ពិត

បើ $x=-16$ នោះ $x+8=-16+8=-8$

នាំឱ្យ $(-16)(-8)=128 \Rightarrow 128=128$ ពិត

ដូចនេះ **ចំនួនដែលត្រូវរកគឺ $(-8,-16)\vee(8,16)$** ។

*ឧទាហរណ៍:* ង. ពូសុខមានចំការមួយមានរាងជាចតុកោណកែង ដែលមានប្រវែងទទឹងស្មើនឹង $12m$ និងបណ្តោយ $16m$ ។ គាត់ចង់ធ្វើផ្លូវមួយ ជុំវិញក្នុងចំការនោះដោយឱ្យទទឹងផ្លូវមានប្រវែងស្មើៗគ្នា ។ ផ្ទៃក្រឡាដីដែលនៅសល់ពីធ្វើផ្លូវស្មើនឹងពាក់កណ្តាលផ្ទៃក្រឡាចំការទាំងមូល ។ តើពូសុខត្រូវយកទទឹងផ្លូវស្មើនឹងប៉ុន្មាន ?




*ចម្លើយ:*

☞ រកប្រវែងទទឹងផ្លូវ ៖

តាង $x$ ជាប្រវែងទទឹងនៃផ្លូវ , $(0<x<12)$

ដោយផ្ទៃដីដែលសល់ពីធ្វើផ្លូវស្មើនឹងពាក់កណ្តាលដីចំការទាំងមូល នោះគេបាន:

*សមីការ:* $(12-2x)(16-2x)=\dfrac{12\times16}{2}$

ឬ $192-24x-32x+4x^2=96$

ឬ $4x^2-56x+96=0$

ឬ $x^2-14x+24=0$

មាន: $\Delta'=(-7)^2-1\times24$

$=49-24=25>0$

នាំឱ្យ: $\sqrt{\Delta'}=\sqrt{25}=5$

នោះ $x_1=\dfrac{7-5}{1}=2>0$ យក

$x_2=\dfrac{7+5}{1}=12$ មិនយកពីព្រោះ $(0<x<12)$

ផ្ទៀងផ្ទាត់: បើ $x=2$

នោះសមីការ: $(12-2x)(16-2x)=96$

$(12-4)(16-4)=96$

$96=96$ ពិត

<u>ដូចនេះ:</u> **ទទឹងផ្លូវមានប្រវែង $x=2m$** ។

<u>ឧទាហរណ៍:</u> ច. ផលបូកការេនៃពីរចំនួនតគ្នាស្មើនឹង 113 ។ គណនាចំនួនទាំងពីរនោះ ។

<u>ចម្លើយ:</u>

☞ រកចំនួនទាំងពីរនោះ

តាង: $x$ ជាចំនួនទី១

$x+1$ ជាចំនួនទី២

ដោយផលបូកការេនៃពីរចំនួនតគ្នានេះស្មើ 113 នោះ

គេបានសមីការ: $x^2+(x+1)^2=113$

$$x^2+x^2+2x+1-113=0$$

$$2x^2+2x-112=0$$

$$2(x^2+x-56)=0$$

$$(x^2+x-56)=0$$

ឬ $x^2-7x+8x-56=0$

$$x(x-7)+8(x-7)=0$$

$$(x-7)(x+8)=0$$

គេបាន: $\begin{cases} x-7=0 \\ x+8=0 \end{cases} \Leftrightarrow \begin{cases} x=7 \\ x=-8 \end{cases}$

ផ្ទៀងផ្ទាត់: បើ $x=7 \Rightarrow x+1=7+1=8$

$$7^2+8^2=113$$

$113=113$ ពិត

បើ $x=-8 \Rightarrow x+1=-8+1=-7$

$$(-8)^2+(-7)^2=113$$

$113=113$ ពិត

<u>ដូចនេះ</u> $(7,8)$ ឬ $(-8,-7)$ ជាចំនួនគត់ដែលត្រូវរក ។

❖ កត្តា៥យ៉ាងដែលកំណត់ការសិក្សារបស់មនុស្សគឺ:

- ➢ កត្តាកំណើត
- ➢ កត្តាគ្រួសារ
- ➢ កត្តាសង្គម និងមជ្ឈដ្ឋានជុំវិញ
- ➢ កត្តាគ្រូ
- ➢ កត្តាខ្លួនឯង

រៀនទៅជាអាវុធ ប្រយុទ្ធនឹងភាពល្ងង់ខ្លៅ

# លំហាត់

**I.** ដោះស្រាយសមីការខាងក្រោម ៖

**1.** $4(x-5)=2x-14$

**2.** $x-(8+4x)=2(3x-4)$

**3.** $5x-(8-x)=2\left[-4-(3+5x)-13\right]$

**4.** $-\left[k-(4k+2)\right]=2+(2k+7)$

**5.** $2-4\left\langle -2x+3\left[-1+5(1-x)-1\right]\right\rangle=0$

**6.** $\sqrt{3}(x-2)-2\sqrt{2}x=2\left(x\sqrt{3}-3-x\sqrt{2}\right)$

**7.** $6(7x+8)-7(6x+4)=5(6+7x)-35(x-1)$

**8.** $8(3-2x)-16(1-x)-3(x-4)=20-3x$

**9.** $(2x+3)^2-(2x+5)=4x(x+4)+4$

**10.** $(3x+5)^2+(x-2)^2=(4x+1)^2-6x(x+1)$

**11.** $(x-2)(3x+4)=x(3x+1)-10$

**12.** $(2x-2)(2x+5)-4x^2+3=0$

**13.** $(x+4)^2-(x-4)^2=32$

**14.** $3(x+1)x-2x(x-1)=(x+1)(x-1)$

**15.** $(2x+4)(3x-1)=(x-1)(2x+1)+4x^2$

**16.** $7x(x-1)+8\left(x^2+2x-1\right)=(5x-1)(3x+2)$

**17.** $x\left(x+3x^2\right)+3x^2-7x(x+1)=3\left(x^3-x^2+12\right)$

**18.** $(x+1)(x+4)+(x+2)(x+3)=(2x+1)(x-2)+10$

**19.** $2x+10x^2-x(x-1)=(3x+1)^2+2(x-1)$

**20.** $\sqrt{3}\left(x^2+3x-1\right)=\sqrt{3}(x-1)^2+2\sqrt{3}x-1$

**II.** ដោះស្រាយសមីការខាងក្រោម ៖

**1.** $\dfrac{5x}{3}+\dfrac{9}{8}=\dfrac{7x}{6}+\dfrac{3}{16}$

**2.** $\dfrac{2x+1}{3}+\dfrac{5-x}{4}=1-\dfrac{3x+2}{6}$

**3.** $\dfrac{2(3x-8)}{9}-\dfrac{5(x-3)}{3}=\dfrac{3(x-8)}{4}+\dfrac{17}{36}$

**4.** $\dfrac{3x-5}{8}+\dfrac{x+12}{12}=1$

**5.** $\dfrac{x+4}{3}-\dfrac{x-4}{5}=2+\dfrac{3x-1}{15}$

**6.** $1+\dfrac{2x}{3}-\dfrac{1}{2}-x=\dfrac{1-x}{3}$

**7.** $3x+\dfrac{5x-3}{3}=37$

**8.** $\left(\dfrac{3x}{4}-\dfrac{2}{5}\right)+\left(\dfrac{2x}{3}+0.6\right)-\left(\dfrac{7x}{12}-0.3\right)=5.8$

**9.** $x+\dfrac{3}{2}-\dfrac{4x-3}{4}=1-\dfrac{5x-12}{6}$

**10.** $8(x-2)+3=7x+\dfrac{2x-1}{2}-3$

**11.** $\dfrac{(2x+1)^2}{4}-\dfrac{3(x+2)^2}{6}=\dfrac{x(x-2)}{2}$

**12.** $\dfrac{(x-2)^2}{3}+\dfrac{x(x-3)}{5}=\dfrac{(8x+7)(x-1)}{15}+\dfrac{4}{5}$

**13.** $\dfrac{x(x+1)}{4}+\dfrac{4x}{8}=\dfrac{2x(x-1)}{6}+\dfrac{1}{2}-\dfrac{x^2}{12}$

**14.** $\dfrac{(x-1)(x+5)}{3}+\dfrac{3x(x+7)}{6}=\dfrac{(x+5)(3x-4)}{4}+\dfrac{x^2}{12}$

**15.** $\dfrac{3}{5}\left[\dfrac{5}{3}\left(\dfrac{x}{4}+1\right)+5\right]-\dfrac{1}{2}=x$

**16.** $\dfrac{x-4}{2013}+\dfrac{x-3}{2014}+\dfrac{x-2}{2015}+\dfrac{x-1}{2016}+\dfrac{x}{2017}=5$

**17.** ក. បើ $\dfrac{1}{x+2}=5$ តើ $\dfrac{1}{x+3}$ ស្មើប៉ុន្មាន?

ខ. រកតម្លៃ $x$ ដើម្បីឱ្យ $\frac{x}{3}-\frac{x}{6}+\frac{x}{9}-\frac{x}{12}=-1+\frac{1}{2}-\frac{1}{3}+\frac{1}{4}$ ។

**18.** $\frac{x-ab}{a+b}+\frac{x-bc}{b+c}+\frac{x-ac}{a+c}=a+b+c$ ដែល $a+b\neq 0$ ,$b+c\neq 0$,$a+c\neq 0$ , $x$ ជាអញ្ញាត ។

**19.** ក. $\frac{x-a}{bc}+\frac{x-b}{ac}+\frac{x-c}{ab}=2\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$ ដែល $a,b,c\neq 0$ ។

ខ. $\frac{a+b-x}{c}+\frac{a+c-x}{b}+\frac{b+c-x}{a}+\frac{4x}{a+b+c}=1$ ដែល $a,b,c\neq 0$ និង $a+b+c\neq 0$ ។

**20.** $\frac{3}{2}+\frac{9}{2}+\frac{15}{2}+...+\frac{6x-3}{2}=\frac{75}{2}$ ។

**III.** *ដោះស្រាយ និងពិភាក្សាសមីការប៉ារ៉ាម៉ែត ($m$ ជាប៉ារ៉ាម៉ែត)*

**1.** $(1-m)x=3m-1$

**2.** $(x-1)x+4m=x^2$

**3.** $3mx+4m=13m+2mx$

**4.** $\frac{2m}{5}x-\frac{m}{10}=1-\frac{7}{10}x$

**5.** $(3x+2)\frac{m}{3}=1-\frac{m}{2}x$

**6.** $3mx+5m-1=4m(x-2)+x+m$

**7.** $4mx(5x-1)=5(4mx+3)x+m-1$

**8.** $7mx-4m+9=2(x-2m)+5$

**9.** $2(x-m)+4=4x-(m-x)+1$

**10.** $\frac{5m}{10}x+\frac{3m-x}{5}=\frac{2x-1}{2}+m$

**11.** $\frac{2x-m}{6}+\frac{m}{3}=\frac{x-2m}{2}+mx$

**12.** $2mx+\frac{m-5}{7}=\frac{x-m}{2}+3$

**13.** $(2m-x)^2+4(1-m)m=x(x+5m)+m-1$

**14.** $(3m+2x)^2-(9m-1)(m-x)=(2x-1)^2-m(x-4)$

**15.** $(m-3x)^2+(m-7x)x-2x(x-1)=(m-x)(m+2)$

**16.** $(m-3)^2+(x+m)^2-2m(m-1)=x^2+7mx-3$

**17.** $\frac{m^2(x+2)^2}{8}-2(2x+m+1)=(m+1)^2+\frac{m^2(x-2)^2}{8}+1$

**IV.** *ដោះស្រាយសមីការខាងក្រោម ដោយមិនប្រើរូបមន្តឌីសគ្រីមីណង់:*

**1.** $x^2+14x+24=0$

**2.** $x(x-2)=24$

**3.** $x^2-2x-8=0$

**4.** $4x^2-16=0$

**5.** $9x^2-21=-5$

**6.** $x^2-4x+4=0$

**7.** $x^2+2\sqrt{3}x-1=0$

**8.** $2x^2+20x-22=0$

**9.** $(2x-1)^2-25=0$

**10.** $2x^2-5x+3=0$

**11.** $3x^2+7x+4=0$

**12.** $6x^2+5x-11=0$

**13.** $x^2-14=5x$

**14.** $x^2-x=3x+12$

**15.** $x^2-12x+32=0$

**16.** $x^2-2x+3=0$

**17.** $4(x-1)^2-(2x-3)^2=0$

**18.** $x^2+2x=2(x+4)$

**19.** $3x^2+9x=0$

**20.** $2x^2+3x-5=0$

**V.** *ដោះស្រាយសមីការខាងក្រោម ៖*

**1.** $x^2-9x-22=0$

**2.** $2x^2+7x-1=0$

**3.** $3x^2+7x+4=0$

**4.** $3x^2+5x-11=0$

**5.** $4x^2-4x-24=0$

**6.** $4x^2-37x+9=0$

**7.** $13x-36=x^2$

**8.** $81x^2+1=18x$

**9.** $x^2+5x-14=0$

**10.** $2x^2-x-1=0$

**11.** $x^2-6x+5=0$

**12.** $3x^2+8x-4=0$

**13.** $x^2+x-9=0$ **14.** $2x^2+3x-9=0$ **15.** $x^2+3x+5=0$

**16.** $6x^2=7x-5$ **17.** $x^2+2x-4=0$ **18.** $x^2+7=4x$

**19.** $2x^2+5x+1=0$ **20.** $(x+1)(2-x)=7x(x+4)$

**VI.** បើ $\alpha$ & $\beta$ ជាឫសនៃសមីការ $x^2+x+1=0$ ។ ដោយមិនដោះស្រាយសមីការ ចូររកតម្លៃ:

**1.** $\alpha^2+\beta^2$ **2.** $(\alpha-\beta)^2$ **3.** $\alpha^3+\beta^3$

**VII.** គេឱ្យសមីការ $x^2+2x+3=0$ មានឫស $\alpha$ & $\beta$ ។ ចូររកតម្លៃនៃកន្សោមខាងក្រោម:

**1.** $\alpha+\beta$ **2.** $\alpha\beta$ **3.** $(1+\alpha)(1+\beta)$ **4.** $\frac{1}{\alpha}+\frac{1}{\beta}$ **5.** $\frac{1}{\alpha-1}+\frac{1}{\beta-1}$

**VIII.** គេឱ្យសមីការ $x^2-x+8=0$ មានឫស $\alpha$ & $\beta$ ។ គណនា:

**1.** $\frac{1}{1+\alpha^2}+\frac{1}{1+\beta^2}$ **2.** $\alpha^4+\beta^4$

**IX.** គេឱ្យ $\alpha$ & $\beta$ ជាឫសនៃសមីការ $x^2+2x+4=0$ ។ ចូរបង្កើតសមីការដឺក្រេទី២ដោយស្គាល់ឫសរបស់វាដូចខាងក្រោម ៖

**1.** $\alpha+3$ និង $\beta+3$ **2.** $\alpha^2+1$ និង $\beta^2+1$ **3.** $2\alpha+4$ និង $2\beta+4$

**4.** $2\alpha^2-1$ និង $2\beta^2-1$ **5.** $\frac{1}{\alpha}$ និង $\frac{1}{\beta}$ **6.** $\frac{1}{\alpha+1}$ និង $\frac{1}{\beta+1}$ **7.** $\frac{1}{\alpha^2-1}$ និង $\frac{1}{\beta^2-1}$

**X.** រកតម្លៃ $k$ ដើម្បីឱ្យសមីការខាងក្រោមមានឫសឌុប ហើយរកឫសឌុបនោះ ៖

**1.** $(k-2)x^2+(3k-6)x+2k-3=0$ **2.** $4x^2-2kx+k+3=0$

**3.** $(k+1)x^2-(k+3)x+3-k=0$ **4.** $kx^2+3(k+2)x+3k-1=0$

**5.** $(k-3)x^2-(2k-1)x+2k-3=0$

**XI.** ដោះស្រាយសមីការខាងក្រោម ៖

**1.** $\frac{x+1}{x-1}-\frac{x-5}{x-3}=0$ **2.** $\frac{4x-1}{x-1}+\frac{4x+1}{1-x}=\frac{9}{4}$ **3.** $\frac{x}{x-3}-\frac{2}{x+3}=1$

**4.** $\frac{x+3}{x-1}-\frac{2x-3}{x+5}=\frac{10-x^2}{(x-1)(x+5)}$ **5.** $\frac{9x^2-25}{(x+2)(3x+5)}=0$ **6.** $\frac{(x-2)(x-1)}{2x-4}+\frac{1}{2}=0$

**7.** $\frac{2}{5x}-\frac{6}{3x}=1-\frac{7}{15x}$ **8.** $\frac{3}{x}-\frac{8}{3x}+\frac{4}{5x}=\frac{1}{15}$ **9.** $\frac{-\frac{3}{4}}{2x-1}=\frac{\frac{1}{3}}{\frac{8x}{5}}$

**10.** $\frac{3x-4}{x-2}+\frac{3-x}{3+x}=\frac{2x^2+x}{(x-2)(3+x)}$ **11.** $\frac{3}{x+\frac{1}{1+\frac{x+1}{3-x}}}=x-1$

**XII.** ដោះស្រាយសមីការខាងក្រោម ៖

**1.** $4^x\cdot16^{3x-1}=8$ **2.** $\frac{4^{x+1}}{8^{x-1}}=16^x$ **3.** $\left(2^{2016}-2^{2015}\right)\left(2^{2017}-2^{2016}\right)=8^x$

**4.** $\left[2\left(2^{\sqrt{x}+1}\right)^{\frac{1}{2}}\right]^{\frac{2}{\sqrt{x}+2}}=4$ **5.** $\left(\frac{1}{5}\right)^{-x-\frac{1}{x}+\frac{3}{2}}=5\sqrt{5}$ **6.** $4^x-5\times2^{x+4}+1024=0$

**7.** $3\times4^{x+1}+6^{x+1}=18\times9^x$ **8.** $\frac{3^{2x^2+3x}}{9}+x^{2016}(x+1)=x\left(x^{2016}+x^{2015}+\frac{1}{x}\right)$

**9.** $\left(\sqrt{7+\sqrt{48}}\right)^x+\left(\sqrt{7-\sqrt{48}}\right)^x=14$ **10.** $\left(\sqrt[3]{2+\sqrt{3}}\right)^x+\left(\sqrt[3]{2-\sqrt{3}}\right)^x=4$

**11.** $\sqrt{2x+5}-\sqrt{3x-5}=2$ **12.** $\sqrt{1-x}=\sqrt{6-x}-\sqrt{5-2x}$

**13.** $\sqrt{x-2\sqrt{x-1}}+\sqrt{x+3-4\sqrt{x-1}}=1$ **14.** $\sqrt{x-5}-\frac{x-14}{3+\sqrt{x-5}}=3$

**15.** $\sqrt{x-2-2\sqrt{x-3}}=1$ **16.** $\sqrt{2x+\sqrt{4x-1}}+\sqrt{2x-\sqrt{4x-1}}=6$

**17.** $\sqrt[3]{13x+17}-\sqrt[3]{13x-37}=\sqrt[3]{2}$ **18.** $\sqrt[3]{1+\sqrt{x}}+\sqrt[3]{1-\sqrt{x}}=\sqrt[3]{5}$

**19.** $\frac{\sqrt{a}+\sqrt{x-a}}{\sqrt{b}+\sqrt{x-a}}=\sqrt{\frac{a}{b}}$ ; $(a>0\ ;b>0\ \&\ a\neq b)$ **20.** $\frac{\frac{x+\sqrt{2}}{x-\sqrt{2}}-\frac{x-\sqrt{2}}{x+\sqrt{2}}}{1-\frac{x-\sqrt{2}}{x+\sqrt{2}}}=\sqrt{2}$

**XIII.** ដោះស្រាយសមីការខាងក្រោម ៖

**1.** $3x^3-10x^2+10x-4=0$ **2.** $x^3-6x^2+11x-6=0$ **3.** $x^3-7x+6=0$

**4.** $x^3+2x^2-5x-6=0$ **5.** $4x^4-37x^2+9=0$ **6.** $81x^4+1=18x^2$

**7.** $13x^2-36=x^4$ **8.** $x^4-36=5x^2$ **9.** $x^4-23x^2=-112$

**10.** $\sqrt{2}x^{2017}-\sqrt{2}x=2\cdot x^{2016}-2$ **11.** $\left(x^2-7x\right)^2=2\left(x^2-7x\right)+48$

**12.** $a^2b^2x^4-b^4x^2-a^4x^2+a^2b^2=0\ ;a,b\neq0$ និង $x$ ជាអញ្ញាត ។

**13.** $4x^4=3x^3+x^2$ **14.** $(x+1)(x+2)(x+3)(x+4)=3$

**15.** $\left(x^2+2x+4\right)\left(x^2+2x+3\right)=x^2+2x+7$ **16.** $\left(x^2+x+3\right)\left(x^2+x\right)=4$

**17.** $x^4-4x=1$ **18.** $x^{2017}-5x^{2016}+6x^{2015}=0$

**19.** $\frac{1}{(3x+1)(3x+2)}+\frac{1}{(3x+2)(3x+3)}+\frac{1}{(3x+3)(3x+4)}=\frac{2}{3x+1}$

**20.** $\frac{1}{x^2+5x+4}+\frac{1}{x^2+11x+28}+\frac{1}{x^2+17x+70}+\frac{2}{x^2+23x+130}=\frac{4}{13}$

**XIV.** 1. រកតម្លៃ $x,y,z$ ដែលផ្ទៀងផ្ទាត់ទំនាក់ទំនងខាងក្រោម ៖

a) $x+y+z=2\sqrt{x-2}+4\sqrt{y-3}+6\sqrt{z-5}-4$

b) $\sqrt{x}+\sqrt{y-1}+\sqrt{z-2}=\frac{1}{2}(x+y+z)$

c) $x+y+z+47=6\sqrt{x-1}+8\sqrt{y-1}+10\sqrt{z-1}$

**2.** រកឬសគត់វិជ្ជមាននៃសមីការ $2(x+y)+16=3xy$ ។

**3.** រកគ្រប់គូនៃចំនួនគត់រ៉ឺឡាទីប $(x,y)$ ដែលផ្ទៀងផ្ទាត់ $\frac{1}{x}+\frac{1}{y}=\frac{1}{3}$ ។

**4.** រកគ្រប់គូ $(x,y)$ ជាចំនួនគត់វិជ្ជមានដែលជាឬសនៃសមីការ $x^2+2018^2=y^2+2017^2$ ។

**5.** a.កំណត់តម្លៃ $x,y$ ដើម្បីឱ្យកន្សោម $2x^2+9y^2-6xy-6x-12y+30$ តូចបំផុត ។

b.កំណត់តម្លៃ $x,y$ ដោយដឹងថា $PGCD(x,y)=12$ , $x+y=72$ ។

**XV.** ចំណោទសមីការ

1. រកចំនួនដែលត្រូវថែមលើតួទាំងពីរនៃប្រភាគ $\frac{8}{3}$ ដើម្បីឱ្យវាស្មើនឹងប្រភាគ $\frac{3}{2}$ ។
2. ផលបូកការេនឹងចម្រាសការេនៃមួយចំនួនស្មើនឹង $\frac{17}{4}$ ។ ចូរគណនាចំនួននោះ ។
3. មធ្យមភាគ $n$ ចំនួនគត់ខុសពីសូន្យ $(x_1,x_2,x_3,...,x_n)$ ស្មើនឹង $22$ ។ បើគេបន្ថែម $29$ ទៅលើ $n$ ចំនួនគត់ទាំងនោះ គេបានមធ្យមភាគថ្មីគឺ $23$ ។ តើគេមានចំនួនគត់ទាំងអស់ប៉ុន្មាន ?
4. ការប្រលងមួយមាន $25$ សំណួរ ។ ចម្លើយត្រូវមួយបាន $4$ ពិន្ទុ ហើយចម្លើយខុសមួយបានពិន្ទុ $-1$ ។ សិស្សម្នាក់ឆ្លើយបានគ្រប់សំណួរហើយបានពិន្ទុ $70$ ។ តើសិស្សនោះឆ្លើយត្រូវបានប៉ុន្មានសំណួរ ?
5. រកពីរចំនួនដែលមានផលបូកស្មើនឹង $25$ ហើយផលបូកចម្រាសរបស់វាស្មើនឹង $\frac{1}{6}$ ។
6. ក្បួនរថយន្តមួយខ្សែផ្ទុកអង្ករ $30t$ ពីទីក្រុង $A$ ទៅទីក្រុង $B$ ។ នៅពេលដែលរៀបចេញដំណើរស្រាប់តែមានរថយន្តពីរមកបន្ថែមទៀត ។ ដូចនេះរថយន្តនីមួយៗត្រូវផ្ទុកអង្ករថយ $\frac{1}{2}t$ ។ រកចំនួនរថយន្តនៃក្បួនដំបូង ។
7. សួនច្បារមួយមានរាងជាចតុកោណកែងដែលមានប្រវែងបណ្តោយលើសទទឹងចំនួន $10m$ ។ គេចង់សង់របងព័ទ្ធជុំវិញសួនច្បារនោះ ។ រកប្រវែងរបងបើសួនច្បារនោះមានក្រឡាផ្ទៃ $1200m^2$ ។
8. សួនផ្កាមួយមានរាងជាចតុកោណកែងដែលមានទទឹង $15m$ និងបណ្តោយ $20m$ ។ គេចង់សង់ផ្លូវព័ទ្ធជុំវិញសួនផ្កានោះដោយឱ្យទទឹងផ្លូវមានប្រវែងស្មើៗគ្នា និងផ្ទៃក្រឡាផ្លូវស្មើនឹង $74m^2$ ។ ចូររកប្រវែងទទឹងផ្លូវនោះ ។
9. ទីធ្លាមួយមានរាងជាចតុកោណកែងដែលមានផ្ទៃក្រឡា $48m^2$ ហើយទទឹងមានប្រវែងស្មើនឹង $75\%$ នៃបណ្តោយ ។ រកបរិមាត្រទីធ្លានោះ ។
10. សួនកម្សាន្តមួយមានរាងចតុកោណកែងដែលមានបណ្តោយ $30m$ និងទទឹង $20m$ ។ គេចង់ពង្រីកទីធ្លានោះដោយបន្ថែមប្រវែងស្មើៗគ្នាទៅលើវិមាត្រទាំងពីរ ដោយឱ្យក្រឡាផ្ទៃស្មើនឹងពីរដងនៃផ្ទៃក្រឡាចាស់ ។ រកប្រវែងដែលត្រូវបន្ថែមនោះ ។
11. ត្រីកោណ $ABC$ មួយមានក្រឡាផ្ទៃ $120cm^2$ បើគេដឹងថា $4$ ដងនៃកម្ពស់វែងជាងបាត $16cm$ ។ គណនារង្វាស់បាត និងកម្ពស់នៃត្រីកោណ $ABC$ ។

12. នៅម៉ោង $7h\ 30mn$ ព្រឹកមនុស្សម្នាក់ដើរពីទីក្រុង $A$ ទៅទីក្រុង $B$ ដោយល្បឿន $5km/h$ ។ ដល់ទីក្រុង $B$ គាត់បានសម្រាកអស់រយៈពេល $1h$ ហើយគាត់បានធ្វើដំណើរត្រលប់មកទីក្រុង $A$ វិញដោយល្បឿនមធ្យម $20km/h$ ។ ពេលត្រលប់មកវិញគាត់ជិះផ្លូវផ្សេងដែលឆ្ងាយជាងផ្លូវមុន $17km$ ។គាត់មកដល់ទីក្រុង $A$ នោះនៅម៉ោង $3h\ 6mn$ ល្ងាច។ រកចម្ងាយផ្លូវដែលជិតជាងគេពីទីក្រុង $A$ ទៅទីក្រុង $B$ ។
13. $n$ ជាចំនួនគត់ធម្មជាតិមិនសូន្យ ។ រកលក្ខខណ្ឌដែល $n$ ត្រូវបំពេញដើម្បីឱ្យវាស្មើនឹងផលដកនៃការេនៃពីរចំនួនគត់តគ្នា ។ អនុវត្តន៍: គណនាពីរចំនួនគត់តគ្នាដែលផលដកនៃការេរបស់វាស្មើ $2015$ ។
14. គេដឹងថាជ្រុងទាំងបីនៃត្រីកោណ $ABC$ ជាចំនួនគត់វិជ្ជមានតគ្នា ហើយមុំធំបំផុតស្មើនឹងពីរដងនៃមុំតូចបំផុត។ រកបរិមាត្រនៃត្រីកោណ $ABC$ ។
15. ឫស្សីមួយដើមមានកម្ពស់ $10m$ ត្រូវខ្យល់បោកបាក់ត្រង់ចំណុចមួយ ។ ចុងឫស្សីប៉ះដីត្រង់ចំណុចមួយដែលមានចម្ងាយ $3m$ ពីគល់ឫស្សី ។ គណនាប្រវែងពីគល់ឫស្សីទៅចំណុចបាក់ ។
16. គេធ្វើប្រអប់មួយពីក្រដាសកាត់តុងរឹងរាងចតុកោណកែងដែលមានបណ្តោយ $12cm$ និងទទឹង $8cm$ ។ គេកាត់ការេបួនដែលជ្រុងមានរង្វាស់ $x(cm)$ ចេញពីបួនកាច់ជ្រុងរបស់ក្រដាសនោះ រួចបត់បណ្តោយនិងទទឹងតាមចំណុចដើម្បីធ្វើប្រអប់មួយរាងប្រលេពីប៉ែតកែង ។ រកតម្លៃ $x$ បើមាឌនៃប្រអប់នោះស្មើនឹង $64cm^3$ ។
17. រកតម្លៃ $a,b,c$ ជាវិមាត្រប្រលេពីប៉ែតកែងមួយដែលមានផលធៀប $a \div b \div c = 3 \div 5 \div 8$ ហើយមានក្រឡាផ្ទៃសរុប $15800cm^2$ ។
18. កសិករម្នាក់ភ្ជួរដីមួយកន្លែងបីលើក ។ លើកទី១ភ្ជួរបាន $30\%$ នៃដីទាំងអស់ ។ លើកទី២ ភ្ជួរបាន $60\%$ នៃដីនៅសល់ ។ ដីនៅសល់ $28$ អា ទុកភ្ជួរបង្ហើយនៅលើកទី៣ ។ តើដីដែលភ្ជួររួចមានប៉ុន្មានហិចតា ?
19. ក្នុងការសិក្សាស្រាវជ្រាវសិស្ស $800$ នាក់ បានឱ្យដឹងថាសិស្សដែលចូលចិត្តរៀន Math មានចំនួនស្មើនឹង $3$ ដងនៃចំនួនសិស្សដែលចូលចិត្តរៀន Physics និងមានសិស្សចំនួន $48$ នាក់ ចូលចិត្តរៀនទាំងពីរមុខវិជ្ជា ។ ចូររកចំនួនសិស្សដែលចូលចិត្តរៀន Math និងចំនួនសិស្សដែលចូលចិត្តរៀន Physics ។
20. ចំនួនសិស្សក្នុងក្រុមទី១មានពីរដងនៃចំនួនសិស្សក្នុងក្រុមទី២ ។ ក្រុមទី១ ដាំកូនឈើបាន $2700$ ដើម ចំណែកក្រុមទី២ ដាំបានតែ $1275$ ដើម ។ រកចំនួនសិស្សក្នុងក្រុមនីមួយៗ បើគេដឹងថាសិស្សម្នាក់ៗនៃក្រុមទី១ ដាំបាន $5$ ដើម លើសសិស្សម្នាក់ៗនៃក្រុមទី២ ។

**« ពេជ្រមិនទាន់ច្នៃតម្លៃគ្មាន សិស្សខ្ជិលរៀនគ្មានវិជ្ជា »**

# មេរៀនទី២ វិសមីការ និងប្រព័ន្ធវិសមីការ

## I. វិសមភាព

ជាទូទៅ: បើគេមានវិសមភាព $a>b$ នោះគេបាន: $c\in\mathbb{R}$

1. $a+c>b+c$
2. $a-c>b-c$
3. $\begin{cases} ac>bc \text{ , បើ } c>0 \\ ac<bc \text{ , បើ } c<0 \end{cases}$
4. $\begin{cases} a\div c>b\div c \text{ , បើ } c>0 \\ a\div c<b\div c \text{ , បើ } c<0 \end{cases}$

ឧទាហរណ៍ទី១ 1. បើ $10>4$

គេបាន: $10+5>4+5$

$19>9$ ពិត

2. បើ $10>4$

គេបាន: $10-5>4-5$

$5>-1$ ពិត

3. បើ $10>4$

គេបាន: $\begin{cases} 10\times 2>4\times 2 \\ 10\times(-2)>4\times(-2) \end{cases}$

ឬ $\begin{cases} 20>8 \\ -28<-8 \end{cases}$ ពិត

4. បើ $10>4$

គេបាន: $\begin{cases} 10\div 2>4\div 2 \\ 10\div(-2)>4\div(-2) \end{cases}$

ឬ $\begin{cases} 5>2 \\ -5<-2 \end{cases}$ ពិត

* ការបង្ហាញវិសមភាព

បើគេមានកន្សោមពីរ $A\&B$

- ដើម្បីឱ្យកន្សោម $A>B$ កាលណា $A-B>0$ ឬ $\frac{A}{B}>1$
- ដើម្បីឱ្យកន្សោម $A<B$ កាលណា $A-B<0$ ឬ $\frac{A}{B}<1$

បញ្ជាក់: ចំពោះវិសមភាពដែលមានសញ្ញា $\geq,\leq$ យើងអនុវត្តន៍ដូចគ្នា ។

ឧទាហរណ៍ទី២ គេឱ្យ $a,b$ ជាចំនួនពិតខុសពីសូន្យ ។

1. ស្រាយថា $a^2+b^2\geq 2ab$
2. បើ $a,b$ មានសញ្ញាដូចគ្នា ស្រាយថា: $\frac{a}{b}+\frac{b}{a}\geq 2$
3. បើ $a,b$ មានសញ្ញាផ្ទុយគ្នា ស្រាយថា: $\frac{a}{b}+\frac{b}{a}\leq 2$
4. បើ $a>b>0$ ស្រាយថា: $a^2>b^2$

<u>ចម្លើយ</u>

1. ស្រាយថា: $a^2+b^2\geq 2ab$

ដោយ: $(a-b)^2\geq 0$ ជានិច្ច

$a^2-2ab+b^2\geq 0$

$a^2-2ab+b^2+2ab\geq 2ab$

2. ស្រាយថា: $\frac{a}{b}+\frac{b}{a}\geq 2$

គេបាន: $\frac{a^2+b^2}{ab}\geq 2$

ដោយ $a,b$ មានសញ្ញាដូចគ្នា គេបាន: $ab>0$

នាំឱ្យ $\left(\frac{a^2+b^2}{ab}\right)ab\geq 2ab$

$a^2+b^2\ge 0$ ពិត

ម្យ៉ាងទៀត: $a^2+b^2\ge 2ab$

$a^2+b^2-2ab\ge 0$

$(a-b)^2\ge 0$ ពិត

ដូចនេះ $\boxed{a^2+b^2\ge 2ab}$ ។

$a^2+b^2\ge 2ab$

$a^2+b^2-2ab\ge 0$

$(a-b)^2\ge 0$ ពិត

ដូចនេះ: $\boxed{\frac{a}{b}+\frac{b}{a}\ge 2}$ ។

3. ស្រាយថា: $\frac{a}{b}+\frac{b}{a}\le 2$

គេបាន: $\frac{a^2+b^2}{ab}\le 2$

ដោយ $a,b$ មានសញ្ញាផ្ទុយគ្នា, គេបាន: $ab<0$

នាំឱ្យ $\left(\frac{a^2+b^2}{ab}\right)ab\ge 2ab$

$a^2+b^2\ge 2ab$

$a^2+b^2-2ab\ge 0$

$(a-b)^2\ge 0$ ពិត

ដូចនេះ: $\boxed{\frac{a}{b}+\frac{b}{a}\le 2}$ ។

4. ស្រាយថា: $a^2>b^2$

ដោយ: $a>b>0$

នាំឱ្យ $a-b>0\ ;\ a+b>0$

គេបាន: $(a-b)(a+b)>0$

$\Leftrightarrow a^2-b^2>0$

$\Leftrightarrow\quad a^2>b^2$ ពិត

ដូចនេះ: $\boxed{a^2>b^2}$ ។

## វិសមភាពកូស៊ី

*ជាទូទៅ:* បើ $a\ge 0\ ;\ b\ge 0$ គេបាន: $a+b\ge 2\sqrt{ab}$ វិសមភាពកើតមានកាលណា $a=b$ ។

*ឧទាហរណ៍:* ចំពោះ $a>0\ ;\ b>0$ ស្រាយបញ្ជាក់ថា:

1. $a+\frac{1}{a}\ge 2$

2. $\left(\frac{a}{b}+\frac{c}{d}\right)\left(\frac{b}{a}+\frac{d}{c}\right)\ge 4$

*ចម្លើយ*

បើ $a>0\ ,b>0$

1. ស្រាយបញ្ជាក់ថា: $a+\frac{1}{a}\ge 2$

តាមវិសមភាពកូស៊ី គេបាន $a+\frac{1}{a}\ge 2\sqrt{a\times\frac{1}{a}}$

$a+\frac{1}{a}\ge 2$ ពិត

ដូចនេះ $\boxed{a+\frac{1}{a}\ge 2}$ ។

2. $\left(\frac{a}{b}+\frac{c}{d}\right)\left(\frac{b}{a}+\frac{d}{c}\right)\geq 4$

តាមវិសមភាពកូស៊ី គេបាន $\times\begin{cases}\frac{b}{a}+\frac{d}{c}\geq 2\sqrt{\frac{b}{a}\times\frac{d}{c}}\\ \frac{a}{b}+\frac{c}{d}\geq 2\sqrt{\frac{a}{b}\times\frac{c}{d}}\end{cases}$

$$\left(\frac{a}{b}+\frac{c}{d}\right)\left(\frac{b}{a}+\frac{d}{c}\right)\geq 4\sqrt{\frac{acbd}{bdac}}=4$$ ពិត

ដូចនេះ $\boxed{\left(\frac{a}{b}+\frac{c}{d}\right)\left(\frac{b}{a}+\frac{d}{c}\right)\geq 4}$ ។

## II. វិសមីការដឺក្រេទី១មានមួយអញ្ញាត

### 1. សញ្ញាណវិសមីការដឺក្រេទី១មានមួយអញ្ញាត

*ជាទូទៅ:* វិសមីការដឺក្រេទី១មានមួយអញ្ញាតមានទម្រង់ $Ax+B>0$ ឬ $Ax+B<0$ ឬ $Ax+B\geq 0$ ឬ $Ax+B\leq 0$ ដែល $A,B$ ជាចំនួនពិត ។

ឧទាហរណ៍: $x+3<7$ , $\frac{\sqrt{3}}{2}x+5>\frac{2}{3}$ , $\frac{7}{\sqrt{2}}x+3x\geq 3+x$ ហៅថាសមីការដឺក្រេទី១មានមួយអញ្ញាត ។

### 2. ដោះស្រាយវិសមីការដឺក្រេទី១មានមួយអញ្ញាត

*ក. ដោះស្រាយវិសមីការដោយប្រើលក្ខណៈវិសមភាព*

* ដោះស្រាយវិសមីការគឺជាការរកគ្រប់តម្លៃនៃអញ្ញាតដែលផ្ទៀងផ្ទាត់វិសមីការ។គេដោះស្រាយដោយប្រើលក្ខណៈវិសមភាព ។

ឧទាហរណ៍: ដោះស្រាយវិសមីការខាងក្រោម ៖

**1.** $x-2<5$

$x-2+2<5+2$

$x<7$

បកស្រាយលើអ័ក្ស




ដូចនេះ $\boxed{\text{តំបន់ចម្លើយគឺ: } x<7}$ ។

**2.** $\frac{x}{2}+2>7$

$x+4>14$

$x+4-4>14-4$

$x>10$

បកស្រាយលើអ័ក្ស




ដូចនេះ $\boxed{\text{តំបន់ចម្លើយគឺ: } x>10}$ ។

**3.** $2(x+3) \ge 5x+5$

$2x+6 \ge 5x+5$

$-3x \ge -1$

$x \le \frac{1}{3}$

បកស្រាយលើអ័ក្ស




ដូចនេះ សំណុំចម្លើយគឺ: $x \le \frac{1}{3}$ ។

**4**. $4x+2 \le 6x+2-2x$

$\Leftrightarrow 4x+2 \le 4x+2$

$\Leftrightarrow 4x-4x \le 2-2$

$\Leftrightarrow \quad 0x \le 0$ ក្នុងករណីនេះ តម្លៃ $x$ យកប៉ុណ្ណាក៏វិសមីការផ្ទៀងផ្ទាត់ជានិច្ច ។

ដូចនេះ: វិសមីការមានសំណុំឫសគ្រប់តម្លៃ $x$ ។

**5**. $3x+2x+5 \le 8x+4-3x$

$\Leftrightarrow 5x+5 \le 5x+4$

$\Leftrightarrow 5x-5x \le 4-5$

$\Leftrightarrow 0x \le -1$ ក្នុងករណីនេះ គ្មានតម្លៃ $x$ ណាដែលធ្វើឱ្យវិសមីការផ្ទៀងផ្ទាត់ទេ ។

ដូចនេះ: វិសមីការគ្មានសំណុំឫសទេ ។

*បញ្ជាក់:*

* សញ្ញាវង់ក្រចក ( ឬ ) បានន័យថាត្រង់តម្លៃនៃវង់ក្រចកប្រសព្វ និងអ័ក្សចំនួនមិនយកជាចម្លើយទេ។
* សញ្ញាឃ្នាប [ ឬ ] បានន័យថាត្រង់តម្លៃនៃឃ្នាបប្រសព្វ និងអ័ក្សចំនួនយកជាចម្លើយ។

ជាទូទៅ: បើវិសមភាពក្រោយពីសម្រួលរួចមានទម្រង់ $ax > b$ គេបាន

$x > \frac{b}{a}$ ( បើ $a > 0$ វិសមភាពមិនផ្លាស់ប្តូរទិដៅទេ )

ឬ $x < \frac{b}{a}$ ( បើ $a < 0$ វិសមភាពផ្លាស់ប្តូរទិដៅ ) ហើយចំពោះ $ax < b$ , $ax \ge b$ , $ax \le b$ គឺដូចគ្នា ។

*ឧទាហរណ៍:* ដោះស្រាយវិសមីការ $5(x-3)-7x \ge 4(x-3)+9$ ។

<u>ចម្លើយ</u>

គេមាន: $5(x-3)-7x \ge 4(x-3)+9$

$\Leftrightarrow 5x-15-7x \ge 4x-12+9$

$\Leftrightarrow -2x-15 \ge 4x-3$

$\Leftrightarrow -2x-4x \ge -3+15$

$\Leftrightarrow -6x \ge 12$

$\Rightarrow x \le \frac{12}{-6}$ ព្រោះ $-6<0$

ឬ $x \le -2$



ដូចនេះ $x \le -2$ ជាសំណុំឫសនៃវិសមីការ ។

## ខ. ដោះស្រាយវិសមីការដឺក្រេទី១តាមតារាងទ្វេធាដឺក្រេទី១ ( ថ្នាក់ទី10 ឡើងទៅ )

**a.** *សញ្ញាទ្វេធាដឺក្រេទី១*

*ជាទូទៅ:* ទ្វេធាដឺក្រេទី១មានរាង $f(x)=ax+b$ ដែល $a\neq 0$ ។

បើ $f(x)=0$ នោះ $ax+b=0$ នាំឱ្យ $x=-\frac{b}{a}$ ជាឫស គេបានតារាងសញ្ញាកំណត់ដោយ:

| $x$ | $-\infty$ | | $-\frac{b}{a}$ | | $+\infty$ |
|---|---|---|---|---|---|
| $f(x)$ | | មានសញ្ញាផ្ទុយ $a$ | 0 | មានសញ្ញាដូច $a$ | |

ឧទាហរណ៍ទី១ សិក្សាសញ្ញាទ្វេធានៃ $f(x)=-3x+21$ ។

បើ $f(x)=0 \Leftrightarrow -3x+21=0 \Rightarrow x=\frac{-21}{-3}=7$

តារាងសញ្ញាទ្វេធា

| $x$ | $-\infty$ | | 7 | | $+\infty$ |
|---|---|---|---|---|---|
| $-\infty$ | | $+$ | 0 | $-$ | |

ព្រោះ $a=-3<0$

ដូចនេះ:
បើ $x<7$ ឬ $x\in(-\infty,7)$ នាំឱ្យ $f(x)>0$
បើ $x>7$ ឬ $x\in(7,+\infty)$ នាំឱ្យ $f(x)<0$
បើ $x=7$ នាំឱ្យ $f(x)=0$

ឧទាហរណ៍ទី២ សិក្សាសញ្ញាទ្វេធា $g(x)=\frac{x}{4}+1$ ។

បើ $g(x)=0 \Leftrightarrow \frac{x}{4}+1=0 \Rightarrow x=(-1)\times 4=-4$

តារាងសញ្ញាទ្វេធា

| $x$ | $-\infty$ | | $-4$ | | $+\infty$ |
|---|---|---|---|---|---|
| $g(x)$ | | $-$ | 0 | $+$ | |

ដូចនេះ
បើ $x<-4$ ឬ $x\in(-\infty,-4)$ នាំឱ្យ $g(x)<0$
បើ $x>-4$ ឬ $x\in(-4,+\infty)$ នាំឱ្យ $g(x)>0$
បើ $x=-4$ នាំឱ្យ $f(x)=0$

**b.** *ដោះស្រាយវិសមីការដឺក្រេទី១មានមួយអញ្ញាតតាមសញ្ញាទ្វេធា*

ឧទាហរណ៍: ដោះស្រាយវិសមីការខាងក្រោម ៖

**1.** $-4x+\frac{5}{4}\le 0$

តាង $f(x)=-4x+\frac{5}{4}$

បើ $f(x)=0\Leftrightarrow -4x+\frac{5}{4}=0$

$\Leftrightarrow -4x=-\frac{5}{4}\Rightarrow x=\frac{5}{16}$

តារាងសញ្ញា

| $x$ | $-\infty$ | | $5/16$ | | $+\infty$ |
|---|---|---|---|---|---|
| $f(x)\le 0$ | | $+$ | $0$ | $-$ | |

ដូចនេះ $x\ge\frac{5}{16}$ ឬ $x\in\left(\frac{5}{16},+\infty\right)$ ជាសំណុំឫសនៃវិសមីការ ។

**2.** $3y+2-5>-y+7+2y$

$3y-3>y+7$

$2y-10>0$

តាង $f(y)=2y-10$

បើ $f(y)=0\Leftrightarrow 2y-10=0$

$\Leftrightarrow 2y=10\Rightarrow y=5$

តារាងសញ្ញា

| $y$ | $-\infty$ | | $5$ | | $+\infty$ |
|---|---|---|---|---|---|
| $f(y)>0$ | | $-$ | $0$ | $+$ | |

ដូចនេះ $y>5$ ឬ $y\in(5,+\infty)$ ជាសំណុំឫសនៃវិសមីការ ។

## III. ដោះស្រាយប្រព័ន្ធវិសមីការដឺក្រេទី១មានមួយអញ្ញាត

### 1. ដោះស្រាយប្រព័ន្ធវិសមីការដោយប្រើលក្ខណៈវិសមភាព

ឧទាហរណ៍: ដោះស្រាយប្រព័ន្ធវិសមីការខាងក្រោម ៖

**1.** $\begin{cases}2x+5\ge 5x-4 & (1)\\ x-7\ge 2x-3 & (2)\end{cases}$

តាម $(1)$ $2x+5\ge 5x-4$

$\Leftrightarrow 2x-5x\geq -4-5$

$\Leftrightarrow -3x\geq -9$

$\Rightarrow x\leq 3$

បកស្រាយលើបន្ទាត់ចំនួន $(1)$




តាម $(2)$ $x-7\geq 2x-3$

$\Leftrightarrow x-2x\geq -4+7$

$\Leftrightarrow -x\geq 4$

$\Rightarrow x\leq -4$

បកស្រាយលើបន្ទាត់ចំនួន $(2)$




តាម $(1)$ និង $(2)$, យើងបាន




តំបន់ចម្លើយផ្ទែកជិត

ដូចនេះ: $x\leq -4$ ឬ $x\in(-\infty,-4]$ ជាសំណុំចម្លើយនៃប្រព័ន្ធវិសមីការ ។

**2.** $\begin{cases}2x-7\leq 6x+5 & (1)\\ 4x-11\leq 4+x & (2)\end{cases}$

តាម $(1)$ $2x-7\leq 6x+5$

$\Leftrightarrow 2x-6x\leq 5+7$

$\Leftrightarrow -4x\leq 12$

$\Rightarrow x\geq -3$

បកស្រាយលើបន្ទាត់ចំនួន $(1)$




តាម $(2)$ $4x-11\geq 4+x$

$\Leftrightarrow 3x\leq 15$

$\Rightarrow x\leq 5$

បកស្រាយលើបន្ទាត់ចំនួន $(2)$




តាម $(1)$ និង $(2)$, យើងបាន




តំបន់ចម្លើយផ្នែកដិត

ដូចនេះ $-3\le x\le 5$ ឬ $x\in[-3,5]$ ជាសំណុំចម្លើយនៃវិសមីការ ។

**3.** $\begin{cases}5<4(x+2)-5x & (1)\\ \frac{1}{2}x+3>2 & (2)\end{cases}$

តាម $(1)$ $5<4(x+2)-5x$

$\Leftrightarrow 5<4x+8-5x$

$\Leftrightarrow -3<-x$

$\Rightarrow x<3$

បកស្រាយលើបន្ទាត់ចំនួន $(1)$




តាម $(2)$ $\frac{1}{2}x+3>2$

$\Leftrightarrow \frac{1}{2}x>-1$

$\Rightarrow x>-2$

បកស្រាយលើបន្ទាត់ចំនួន $(2)$




តាម $(1)$ និង $(2)$, យើងបាន




តំបន់ចម្លើយផ្នែកដិត

ដូចនេះ $-2<x<3$ ឬ $x\in(-2,3)$ ជាសំណុំចម្លើយនៃវិសមីការ ។

*បញ្ជាក់:* សំណុំចម្លើយរបស់ប្រព័ន្ធវិសមីការគឺជា ប្រសព្វរវាងចម្លើយរបស់វិសមីការនីមួយៗ ។ មានន័យថា ចម្លើយរបស់វាត្រូវផ្ទៀងផ្ទាត់គ្រប់វិសមីការទាំងអស់ក្នុងប្រព័ន្ធនោះ ។

### 2. ដោះស្រាយប្រព័ន្ធវិសមីការដឺក្រេទី១មានមួយអញ្ញាត តាមសញ្ញាទ្វេធា

ឧទាហរណ៍: ដោះស្រាយវិសមីការខាងក្រោម ៖

**1.** $\begin{cases}2x+5\le 3\\ 14-5x>4\end{cases}$

$\Leftrightarrow \begin{cases}2x+2\le 0 & (1)\\ 10-5x>0 & (2)\end{cases}$

តាង $\begin{cases} f(x)=2x+2 \\ g(x)=10-5x \end{cases}$

បើ $\begin{cases} f(x)=0 \\ g(x)=0 \end{cases} \Leftrightarrow \begin{cases} 2x+2=0 \\ 10-5x=0 \end{cases} \Rightarrow \begin{cases} x=-1\ (1) \\ x=2\ (2) \end{cases}$

តារាងសញ្ញា

| $x$ | $-\infty$ $-1$ | $2$ | $+\infty$ |
|---|---|---|---|
| $f(x)\le 0$ | $-$ 0 | $+$ | $+$ |
| $g(x)>0$ | $+$ | $+$ 0 | $-$ |
| $f(x)\cap g(x)$ | | | |

ដូចនេះ: $x\le -1$ ឬ $x\in(-\infty,-1]$ ជាសំណុំចម្លើយរបស់ប្រព័ន្ធវិសមីការ ។

**2.** $\begin{cases} 5-x>7 \\ 2x+3\ge 13 \end{cases} \Leftrightarrow \begin{cases} -x-2>0 & (1) \\ 2x-10\ge 0 & (2) \end{cases}$

តាម $(1)$ តាង $f(x)=-x-2$

បើ $f(x)=0 \Rightarrow x=-2$

តាម $(1)$ តាង $g(x)=2x-10$ បើ $g(x)=0 \Rightarrow x=5$

តារាងសញ្ញា

| $x$ | $-\infty$ $-2$ | $5$ | $+\infty$ |
|---|---|---|---|
| $f(x)>0$ | $+$ 0 | $-$ | $-$ |
| $g(x)\ge 0$ | $-$ | $-$ 0 | $+$ |
| $f(x)\cap g(x)$ | | | |

ដូចនេះ: ប្រព័ន្ធវិសមីការគ្មានសំណុំចម្លើយ ។

## IV. វិសមីការដឺក្រេទី២មានមួយអញ្ញាត( ថ្នាក់ទី១០ )

### 1. សញ្ញាណវិសមីការដឺក្រេទី២មានមួយអញ្ញាត

*ជាទូទៅ:* វិសមីការដឺក្រេទី២មានមួយអញ្ញាតមានទម្រង់ $ax^2+bx+c>0$ ឬ $ax^2+bx+c<0$ ឬ $ax^2+bx+c\ge 0$ ឬ $ax^2+bx+c\le 0$ ដែល $a\ne 0$ , $x$ ជាអញ្ញាត ។

ឧទាហរណ៍: $\frac{1}{2}x^2+5x+3>0$ , $\sqrt{2}x^2-\frac{\sqrt{3}}{2}x-1\le 0$ , $6x^2-\frac{1}{2}x\ge 0$ , $x^2-1<0$ ហៅថាវិសមីការដឺក្រេទី២ មានមួយអញ្ញាត ។

## 2. ដោះស្រាយវិសមីការដឺក្រេទី២មានមួយអញ្ញាត តាមសញ្ញាត្រីធាដឺក្រេទី២

### a. សញ្ញាត្រីធាដឺក្រេទី២

*ជាទូទៅ:* បើ $f(x)=ax^2+bx+c$ ជាត្រីធាដឺក្រេទី២ ដែល $a\neq 0$ ។ បើ $f(x)=0$ នោះ $ax^2+bx+c=0$

- បើ $\Delta>0$ សមីការមានឫស $x_1<x_2$ ជាចំនួនពិត គេបាន តារាងសញ្ញា

| $x$ | $-\infty$ | $x_1$ | | $x_2$ | $+\infty$ |
|---|---|---|---|---|---|
| $f(x)$ | សញ្ញាដូច $a$ | 0 | សញ្ញាផ្ទុយ $a$ | 0 | សញ្ញាដូច $a$ |

- បើ $\Delta=0$ សមីការមានឫសឌុប $x_1=x_2=x_0$ ជាចំនួនពិត គេបាន តារាងសញ្ញា

| $x$ | $-\infty$ | $x_0$ | $+\infty$ |
|---|---|---|---|
| $f(x)$ | សញ្ញាដូច $a$ | 0 | សញ្ញាដូច $a$ |

- បើ$\Delta<0$ សមីការគ្មានឫសក្នុងចំនួនពិត តែមានឫសក្នុងចំនួនកុំផ្លិច គេបាន តារាងសញ្ញា

| $x$ | $-\infty$ $+\infty$ |
|---|---|
| $f(x)$ | សញ្ញាដូច $a$ ជានិច្ច |

### b. ដោះស្រាយវិសមីកាដឺក្រេទី២ តាមសញ្ញាត្រីធា

ឧទាហរណ៍: ដោះស្រាយវិសមីការខាងក្រោម ៖

**1.** $2x^2-3x-2<0$

តាង $f(x)=2x^2-3x-2$

បើ $f(x)=0$ នោះ $2x^2-3x-2=0$

$$\Leftrightarrow (2x+1)(x-1)=0$$

$$\Rightarrow x_1=-\frac{1}{2}\ ,\ x_2=2$$

តារាងសញ្ញា

| $x$ | $-\infty$ | $-1/2$ | | $2$ | $+\infty$ |
|---|---|---|---|---|---|
| $f(x)<0$ | $+$ | 0 | $-$ | 0 | $+$ |

ដូចនេះ $-\frac{1}{2}<x<2$ ឬ $x\in\left(-\frac{1}{2},2\right)$ ជាសំណុំចម្លើយនៃវិសមីការ ។

**2.** $\frac{5x^2}{2}-\frac{x}{6}\geq\frac{1}{3}$

$\Leftrightarrow 15x^2-x-2\geq 0$

តាង $f(x)=15x^2-x-2$

បើ $f(x)=0$ នោះ $15x^2-x-2=0$

មាន $\Delta = 1 - 4\times 15(-2)$

$$= 1 + 80 = 81 \Rightarrow \sqrt{\Delta} = 9$$

$$\Rightarrow x_1 = \frac{1-9}{30} = -\frac{4}{15} \ , \ x_2 = \frac{1+9}{30} = \frac{1}{3}$$

តារាងសញ្ញា

| $x$ | $-\infty$ | | $-\frac{4}{15}$ | | $\frac{1}{3}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f(x) \geq 0$ | | $+$ | 0 | $-$ | 0 | $+$ | |

ដូចនេះ $x \in \left(-\infty, -\frac{4}{15}\right] \cup \left[\frac{1}{3}, +\infty\right)$ ជាសំណុំចម្លើយនៃវិសមីការ ។

**3.** $x^2 - 4x + 4 > 0$

$\Leftrightarrow x^2 - 4x + 4 > 0$

តាង $f(x) = x^2 - 4x + 4$

បើ $f(x) = 0$ នោះ $x^2 - 4x + 4 = 0$

មាន $\Delta = 4^2 - 4\times 4\times 1 = 0$

$$\Rightarrow x_1 = x_2 = -\frac{b}{2a} = -\frac{(-4)}{2\times 1} = 2$$

តារាងសញ្ញា

| $x$ | $-\infty$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|
| $f(x) > 0$ | | $+$ | 0 | $+$ | |

ដូចនេះ $x \in (-\infty, 2) \cup (2, +\infty)$ ជាសំណុំចម្លើយនៃវិសមីការ ។

4. $64 \leq 16x - x^2$

$x^2 - 16x + 64 \leq 0$

តាង $f(x) = x^2 - 16x + 64$

បើ $f(x) = 0$ នោះ $x^2 - 16x + 64 = 0$

មាន: $\Delta' = (-8)^2 - 1\times 64 = 0$

នាំឱ្យ $x_0 = -\frac{b'}{a} = 8$

តារាងសញ្ញា

| $x$ | $-\infty$ | | $8$ | | $+\infty$ |
|---|---|---|---|---|---|
| $f(x) \leq 0$ | | $+$ | 0 | $+$ | |

ដូចនេះ វិសមីការគ្មានសំណុំចម្លើយទេ ។

**5.** $x^2+2x+5<0$

តាង $f(x)=x^2+2x+5$

បើ $f(x)=0$ នោះ: $x^2+2x+5=0$

មាន: $\Delta'=4-20=-16<0$

តារាងសញ្ញា

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $f(x)<0$ | | $+$ | |

ដូចនេះ: វិសមីការគ្មានសំណុំចម្លើយទេ ។

**6.** $5x\geq x^2+9$

$-x^2+5x-9\geq 0$

តាង $f(x)=-x^2+5x-9$

បើ $f(x)=0$ នោះ: $-x^2+5x-9=0$

មាន: $\Delta=25-36=-11<0$

តារាងសញ្ញា

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $f(x)\geq 0$ | | $-$ | |

ដូចនេះ: វិសមីការគ្មានសំណុំចម្លើយទេ ។

**7.** $2x^2-4x+3\geq 0$

តាង $f(x)=2x^2-4x+3$

បើ $f(x)=0$ នោះ: $2x^2-4x+3=0$

មាន: $\Delta'=4-6=-2<0$

តារាងសញ្ញា

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $f(x)\geq 0$ | | $+$ | |

វិសមីការផ្ទៀងផ្ទាត់គ្រប់តម្លៃ $x$

ដូចនេះ: វិសមភាពមានសំណុំចម្លើយគ្រប់តម្លៃ $x$ ។

## V. ដោះស្រាយប្រព័ន្ធវិសមីការដឺក្រេទី២មានមួយអញ្ញាត

*ឧទាហរណ៍:* ដោះស្រាយប្រព័ន្ធវិសមីការខាងក្រោម ៖

1. $\begin{cases} x^2-6x+5\le 0 \\ x^2-9x+16<0 \end{cases}$ 2. $\begin{cases} -x^2+3x+4\ge 0 \\ \left(2x^2+3\right)\left(x^2-3x\right)>0 \end{cases}$ 3. $\begin{cases} x^2+x-5>0 \\ x^2-5x+4<0 \end{cases}$ 4. $\begin{cases} x^2+x-20\le 0 \\ 2x^2+7x+3<0 \end{cases}$

<u>*ចម្លើយ*</u>

✓ ដោះស្រាយប្រព័ន្ធវិសមីការ

**1.** $\begin{cases} x^2-6x+5\le 0 \ (1) \\ x^2-9x+16<0 (2) \end{cases}$

តាម $(1)$ តាង $f(x)=x^2-6x+5$

បើ $f(x)=0$ នោះ $x^2-6x+5=0$

មាន: $a+b+c=0$

នាំឱ្យ $x_1=1$ , $x_2=\dfrac{c}{a}=5$

តាម $(2)$ តាង $g(x)=x^2-9x+14$

បើ $f(x)=0$ នោះ $x^2-9x+14=0$

មាន: $\Delta=81-56=25\Rightarrow\sqrt{\Delta}=5$

នាំឱ្យ $x_1=\dfrac{9-5}{2}=2,\ x_2=\dfrac{9+5}{2}=7$

តារាងសញ្ញា

| $x$ | $-\infty$ | 1 | 2 | 5 | 7 | $+\infty$ |
|---|---|---|---|---|---|---|
| $f(x)\le 0$ | + | 0 | − | − 0 | + | + |
| $g(x)<0$ | + | + | 0 − | − | 0 | + |
| $f(x)\cap g(x)$ | | | | | | |

ដូចនេះ $x\in(2,5]$ ជាសំណុំចម្លើយនៃប្រព័ន្ធវិសមីការ ។

**2.** $\begin{cases} -x^2+3x+4\ge 0 \qquad (1) \\ \left(2x^2+3\right)\left(x^2-3x\right)>0 (2) \end{cases}$

តាម $(1)$ តាង $f(x)=-x^2+3x+4$

បើ $f(x)=0$ នោះ $-x^2+3x+4=0$

មាន: $a-b+c=0$

នាំឱ្យ $x_1=-1$ , $x_2=-\dfrac{c}{a}=4$

តាម $(2)$ តាង $g(x)=\left(2x^2+3\right)\left(x^2-3x\right)$

បើ $f(x)=0$ នោះ $\left(2x^2+3\right)\left(x^2-3x\right)=0$

គេបាន: $\left[\begin{array}{l}2x^2+3=0\\ x^2-3x=0\end{array}\right. \Leftrightarrow \left[\begin{array}{l}x^2=-\dfrac{3}{2}\\ x(x-3)=0\end{array}\right. \Leftrightarrow \left[\begin{array}{l}\text{គ្មានឫស}\\ x=0\ ,\ x=3\end{array}\right.$

តារាងសញ្ញា

| $x$ | $-\infty$ | | $-1$ | | $0$ | | $3$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f(x)\ge 0$ | | $-$ | 0 | $+$ | | $+$ | | $+$ | 0 | $-$ | |
| $(2x^2+3)$ | | $+$ | | $+$ | | $+$ | | $+$ | | $+$ | |
| $(x^2-3x)$ | | $+$ | | $+$ | 0 | $-$ | 0 | $+$ | | $+$ | |
| $g(x)>0$ | | $+$ | | $+$ | 0 | $-$ | 0 | $+$ | | $+$ | |
| $f(x)\cap g(x)$ | | | | | | | | | | | |

ដូចនេះ: $x\in[-1,0)\cup(3,4]$ ជាសំណុំចម្លើយនៃប្រព័ន្ធវិសមីការ ។

**3.** $\begin{cases}x^2+x-3>0 & (1)\\ x^2-5x+4<0 & (2)\end{cases}$

តាម $(1)$ តាង $f(x)=x^2+x-3$

បើ $f(x)=0$ នោះ: $x^2+x-3=0$

មាន: $\Delta=1-4\times(-3)$

$=1+12=13\Rightarrow\sqrt{\Delta}=\sqrt{13}$

គេបាន $x_1=\dfrac{-1-\sqrt{13}}{2}$ , $x_2=\dfrac{-1+\sqrt{13}}{2}$

តាម $(2)$ តាង $g(x)=x^2-5x+4$

បើ $g(x)=0$ នោះ: $x^2-5x+4=0$

មាន: $a+b+c=0$

គេបាន $x_1=1$ , $x_2=\dfrac{c}{a}=4$

តារាងសញ្ញា

| $x$ | $-\infty$ | | $\frac{-1-\sqrt{13}}{2}$ | | $1$ | | $\frac{-1+\sqrt{13}}{2}$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f(x)>0$ | | $+$ | 0 | $-$ | | $-$ | 0 | $+$ | | $+$ | |
| $g(x)<0$ | | $+$ | | $+$ | 0 | $-$ | 0 | $-$ | | $+$ | |
| $f(x)\cap g(x)$ | | | | | | | | | | | |

ដូចនេះ: $x\in\left(\dfrac{-1+\sqrt{13}}{2},4\right)$ ជាសំណុំចម្លើយនៃប្រព័ន្ធវិសមីការ ។

**4.** $\begin{cases} x^2+x-20\le 0 \quad (1) \\ 2x^2+7x+3>0 (2) \end{cases}$

តាម $(1)$ តាង $f(x)=x^2+x-20$

បើ $f(x)=0$ នោះ $x^2+x-20=0$

មាន: $\Delta=1-4\times(-20)$

$=1+80=13\Rightarrow\sqrt{\Delta}=9$

គេបាន $x_1=\frac{-1-9}{2}=-5$ , $x_2=\frac{-1+9}{2}=4$

តាម $(2)$ តាង $g(x)=2x^2+7x+3$

បើ $g(x)=0$ នោះ $2x^2+7x+3=0$

មាន: $\Delta=49-24=25\Rightarrow\sqrt{\Delta}=5$

គេបាន $x_1=\frac{-7-5}{4}=-3$ , $x_2=\frac{-7+5}{4}=-\frac{1}{2}$

តារាងសញ្ញា

| $x$ | $-\infty$ | | $-5$ | | $-3$ | | $-\frac{1}{2}$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $f(x)\le 0$ | | + | 0 | − | | − | | − | 0 | + | |
| $g(x)>0$ | | + | | + | 0 | − | 0 | + | | + | |
| $f(x)\cap g(x)$ | | | | | | | | | | | |

ដូចនេះ $x\in[-5,-3)\cup\left(-\frac{1}{2},4\right]$ ជាសំណុំចម្លើយនៃប្រព័ន្ធវិសមីការ ។

## VI. អនុវត្តន៍វិសមីការ ( *សម្រាប់ថ្នាក់ទី១០ឡើងទៅ* )

*ឧទាហរណ៍ទី១* ដោះស្រាយវិសមីការ $x^3-2x^2-8x\le 0$

តាម $(1)$ តាង $f(x)=x^3-2x^2-8x$

បើ $f(x)=0$ នោះ $x^3-2x^2-8x=0\Leftrightarrow x\left(x^2-2x-8\right)=0$

នាំឱ្យ $x=0$ ឬ $x^2-2x-8=0$

មាន: $\Delta'=1-(-8)=1+8=9\ \Rightarrow\sqrt{\Delta'}=3$

គេបាន $x_1=\frac{1-3}{1}=-2$ , $x_2=\frac{1+3}{1}=4$

តារាងសញ្ញា

| $x$ | $-\infty$ | | $-2$ | | $0$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $x$ | | − | | − | 0 | + | | + | |
| $x^2-2x-8$ | | + | 0 | − | | − | 0 | + | |
| $f(x)\le 0$ | | − | | + | | − | | + | |

ដូចនេះ $x\in(-\infty,-2]\cup[0,4]$ ជាសំណុំចម្លើយនៃវិសមីការ ។

*ឧទាហរណ៍ទី២* ដោះស្រាយវិសមីការ $\dfrac{x^2+3x-4}{x^2-9}>0$

តាង $f(x)=x^2+3x-4$

បើ $f(x)=0$ នោះ $x^2+3x-4=0$

មាន: $a+b+c=0$

គេបាន $x_1=1$ , $x_2=\dfrac{c}{a}=-4$

តាង $g(x)=x^2-9$

បើ $g(x)=0$ នោះ $x^2-3^2=0$ ឬ $(x-3)(x+3)=0$

$$\Leftrightarrow\left[\begin{array}{l}x-3=0\\x+3=0\end{array}\right.\Rightarrow\left[\begin{array}{l}x=3\\x=-3\end{array}\right.$$

តារាងសញ្ញា

| $x$ | $-\infty$ | $-4$ | $-3$ | $1$ | $3$ | $+\infty$ |
|---|---|---|---|---|---|---|
| $f(x)$ | $+$ | 0 $-$ | $-$ | 0 $+$ | $+$ | |
| $g(x)$ | $+$ | $+$ | 0 $-$ | 0 $-$ | $+$ | |
| $\dfrac{f(x)}{g(x)}>0$ | $+$ | $-$ | $+$ | $-$ | $+$ | |

ដូចនេះ $x\in(-\infty,-4)\cup(-3,1)\cup(3,+\infty)$ ជាសំណុំចម្លើយនៃ វិសមីការ ។

*ឧទាហរណ៍ទី៣* គេឱ្យសមីការ $x^2+2mx-3m-2=0$ ។ រកតម្លៃ $m$ ដើម្បីឱ្យសមីការមានឫសពីរផ្សេងគ្នា ជាចំនួនពិតវិជ្ជមាន ។

*<u>ចម្លើយ</u>*

ដើម្បីឱ្យសមីការ $x^2+2mx-3m-2=0$ មានឫសពីរផ្សេងគ្នាជាចំនួនពិតវិជ្ជមាន កាលណា: $\begin{cases}\Delta'>0\\P>0\\S>0\end{cases}$

នោះ $\begin{cases}m^2-1\times(-3m-2)>0\\\dfrac{-3m-2}{1}>0\\\dfrac{-2m}{1}>0\end{cases}\Leftrightarrow\begin{cases}m^2+3m+2>0 & (1)\\-3m-2>0 & (2)\\-2m>0 & (3)\end{cases}$

តាម $(1)$ គេបាន: $m^2+3m+2>0$

តាង $f(m)=m^2+3m+2$

បើ $f(m)=0$ នោះ $m^2+3m+2=0$

មាន: $a-b+c=0$ នោះ $m_1=-1$ , $m_2=-\frac{c}{a}=-2$

តារាងសញ្ញា

| $x$ | $-\infty$ $\quad$ $-2$ $\quad$ $-1$ $\quad$ $+\infty$ |
|---|---|
| $f(m)>0$ | $+$ $\quad$ 0 $\quad$ $-$ $\quad$ 0 $\quad$ $+$ |

នាំឱ្យ $m\in(-\infty,-2)\cup(-1,+\infty)$ $(*)$

តាម $(2)$ និង $(3)$ $\begin{cases}-3m-2>0\\-2m>0\end{cases} \Leftrightarrow \begin{cases}m<-\frac{2}{3}\\m<0\end{cases} \Rightarrow m<-\frac{2}{3}$ $(**)$

តាម $(*)$ និង $(**)$ គេបាន: $m\in(-\infty,-2)\cup\left(-1,-\frac{2}{3}\right)$

ដូចនេះ $m\in(-\infty,-2)\cup\left(-1,-\frac{2}{3}\right)$ នាំឱ្យសមីការមានឫសពីរផ្សេងគ្នាជាចំនួនពិតវិជ្ជមាន ។

✓ **ចំណាំ:** សមីការដឺក្រេទី២ $ax^2+bx+c=0$ ដែលមាន $x$ ជាអញ្ញាតមានលក្ខខណ្ឌដូចខាងក្រោម ៖

- បើ $a=0$ នាំឱ្យសមីការទៅជាសមីការដឺក្រេទី១ ដែលមានឫស $x=-\frac{c}{b}$ ។
- បើ $a\neq 0$
  - ○ ចំពោះ $\Delta>0$ នាំឱ្យសមីការមានឫសពីរផ្សេងគ្នា $x_1<x_2$ គឺ
    - – បើ $P>0$ , $S>0$ នោះ $0<x_1<x_2$
    - – បើ $P>0$ , $S<0$ នោះ $x_1<x_2<0$
    - – បើ $P<0$ នោះ $x_1<0<x_2$
  - ○ ចំពោះ $\Delta=0$ នាំឱ្យសមីការមានឫសឌុប គឺ $x_0=-\frac{b}{2a}$
  - ○ ចំពោះ $\Delta<0$ នាំឱ្យសមីការគ្មានឫសក្នុងចំនួនពិត ឬមានឫសពីរក្នុងចំនួនកុំផ្លិចឆ្លាស់ ។

*ឧទាហរណ៍ទី៤* សិក្សាអត្ថិភាព និងសញ្ញាឫសនៃសមីការ $mx^2-2(2m-3)x+2m-1=0$ តាមតម្លៃ $m$ ។

*ចម្លើយ*

យើងមានសមីការ $mx^2-2(2m-3)x+2m-1=0$

– បើ $m=0$ នាំឱ្យសមីការទៅជា $6x-1=0$ សមីការដឺក្រេទី១ ដែលមានឫស $x=\frac{1}{6}$

– បើ $m\neq 0$ សមីការមាន: $\Delta'=(2m-3)^2-m(2m-1)$

$$=4m^2-12m+9-2m^2+m$$

$$=2m^2-11m+9$$

បើ $\Delta'=0$ នោះ $2m^2-11m+9=0$

មាន: $a+b+c=0$ នាំឱ្យ $m_1=1$ , $m_2=\frac{c}{a}=\frac{9}{2}$

- $P=\frac{c}{a}=\frac{2m-1}{m}$

  បើ $P=0$ នោះ $\frac{2m-1}{m}=0\Rightarrow m=\frac{1}{2}$

- $S=-\frac{b}{a}=\frac{2(2m-3)}{m}$

  បើ $S=0$ នោះ $\frac{2(2m-3)}{m}=0\Rightarrow m=\frac{3}{2}$

តារាងសញ្ញា

| $m$ | $\Delta'$ | $P$ | $S$ | អត្ថិភាពនិងសញ្ញាឫស $x_1<x_2$ |
|---|---|---|---|---|
| $-\infty$ | $+$ | $-$ | $-$ | សមីការមានឫសពីរ គឺ $x_1<0<x_2$ |
| $0$ | | | | សមីការមានឫសមួយ គឺ $x=\frac{1}{6}$ |
| | $+$ | $-$ | $-$ | សមីការមានឫសពីរ គឺ $x_1<0<x_2$ |
| $\frac{1}{2}$ | | $0$ | | សមីការមានឫសពីរ គឺ $x_1=-8$ , $x_2=0$ |
| | $+$ | $+$ | $-$ | សមីការមានឫសពីរ គឺ $x_1<x_2<0$ |
| $1$ | $0$ | | | សមីការមានឫសឌុប គឺ $x_0=-1$ |
| | $-$ | $+$ | $-$ | សមីការគ្មានឫស ឬ សមីការមានឫសក្នុងចំនួនកុំផ្លិច |
| $\frac{3}{2}$ | | | $0$ | |
| | $-$ | $+$ | $+$ | |
| $\frac{9}{2}$ | $0$ | | | សមីការមានឫសឌុប គឺ $x_1=x_2=x_0=\frac{4}{3}$ |
| $+\infty$ | $+$ | $+$ | $+$ | សមីការមានឫសពីរ គឺ $0<x_1<x_2$ |

## VII. ចំណោទវិសមីការ

*វិធាន:* ដើម្បីដោះស្រាយចំណោទវិសមីការ គេត្រូវ ៖

១. តាងអញ្ញាត ( ដាក់លក្ខខណ្ឌបើមាន )

២. សរសេរវិសមីការតាមបម្រាប់ប្រធាន

៣. ដោះស្រាយវិសមីការ

៤. ផ្ទៀងផ្ទាត់ចម្លើយ រួចសន្និដ្ឋាន

*( យើងនឹងធ្វើការដោះស្រាយលំហាត់ចំណោទវិសមីការនេះនៅក្នុងការអនុវត្តលំហាត់តែម្តង )*

# លំហាត់

☞ **គម្រិត I** ( ថ្នាក់ទី 9 )

I. ដោះស្រាយវិសមីការខាងក្រោម ៖

1. $5-2(x-1)\le 2(4+x)$
2. $x+1<\frac{3}{2}x-3$
3. $4(2x+1)+5\ge 2(x-3)+1$
4. $1-\frac{x}{3}<\frac{1}{3}(2x-3)$
5. $\frac{2}{5}(x-5)-\frac{2}{3}(2-x)\le 2$
6. $7x+\frac{3}{2}(x-1)+1\ge 0$
7. $x-1\le 3x-\frac{1}{2}$
8. $x\left(x^2+1\right)+5x-2>x^3+x+2$
9. $\frac{1}{2}x^2+3x-1<x\left(\frac{x}{2}+5\right)-\frac{1}{2}$
10. $\frac{5}{3}x+\frac{2x-1}{2}\ge 3x-1$
11. $\frac{4}{5}x-1\ge\frac{2}{3}x-2$
12. $\frac{3}{7}x+\frac{2x-5}{14}+\frac{1-x}{2}\ge 0$
13. $\frac{4}{9}x+\frac{2-3x}{3}+\frac{x^2+1}{2}\le 1+\frac{27x^2}{54}$
14. $\frac{5x-1}{2}+\frac{3x-4}{3}>1$
15. $\frac{2x-\frac{1}{2}}{3}+\frac{4-\frac{2x}{3}}{2}<\frac{2x-1}{3}$ ។

II. ដោះស្រាយប្រព័ន្ធវិសមីការខាងក្រោម ៖

1. $\begin{cases}-4x-5>0\\3x-2<0\end{cases}$
2. $\begin{cases}x+1\ge\frac{1}{3}(x+5)\\\frac{1}{2}(3x-1)-1<0\end{cases}$
3. $\begin{cases}2x+7>5x-9\\x-8\le 4x-3\end{cases}$
4. $\begin{cases}6(x+1)>2x-5\\25-\frac{6-x}{2}\le 3x\end{cases}$
5. $\begin{cases}\frac{3x-1}{3}+\frac{1}{5}\ge\frac{x-1}{15}+1\\2x-5\ge\frac{1}{3}(x-5)\end{cases}$
6. $\begin{cases}\frac{7x-3}{2}-\frac{1}{3}x<\frac{2x-1}{6}\\4x-\frac{1}{5}>2x-1\end{cases}$
7. $\begin{cases}\frac{9x-2}{3}+\frac{1}{5}x>1\\\frac{x-2}{2}+1<0\end{cases}$
8. $\begin{cases}\frac{x+20}{2}+\frac{x-2}{5}+1\le\frac{x}{10}\\1-\frac{9x}{2}+3x\ge\frac{1}{2}x-3\end{cases}$
9. $\begin{cases}\frac{x+\frac{1}{2}}{3}-\frac{2-3x}{4}+\frac{1}{2}>0\\\frac{2x-\frac{1}{2}}{2}+\frac{\frac{x-2}{3}}{2}-1\ge 0\end{cases}$
10. $2(x-3)+5<5x-6<\frac{3x+4}{3}$

11. $\begin{cases}\frac{3x}{4}-\frac{2}{3}\le\frac{4x-3}{2}\\2x-1>\frac{3x-4}{4}\end{cases}$

12. $\begin{cases}2x+1<0\\-\frac{x}{2}+2<0\end{cases}$

13. $\begin{cases}3x+\frac{2x-1}{2}\ge\frac{3x+5}{4}\\x-\frac{1-2x}{3}>\frac{x-1}{5}\end{cases}$

14. $\begin{cases}x+1\ge1-\frac{x}{2}\\\frac{x+5}{6}+1\ge3x-1\end{cases}$

15. $\begin{cases}\frac{3x-1}{4}+\frac{x-5}{2}>1\\\frac{2x-3}{2}-\frac{x-3}{4}<2x\end{cases}$ ។

III. ចូររកតម្លៃ $x$ ដើម្បីឱ្យកន្សោមខាងក្រោមវិជ្ជមាន ៖

1. $\frac{-2015}{x+\frac{2}{3}x-1}$

2. $\frac{x+\frac{1}{2}}{2017}$

3. $\frac{1}{x+\frac{3}{2}}$

4. $\frac{(3x-5)^2-9(x+2)x}{2016}$

5. $\frac{2x-1}{x-3}$

6. $\frac{3x}{1-x}$

7. $\frac{2x+1}{x}$

8. $\frac{3x+\frac{1}{2}}{7x-1}$

9. $\frac{1}{20x-40}$

10. $\frac{(4x-1)^2-2x(6x-1)-4x^2}{x-1}$ ។

IV. ចូររកតម្លៃ $x$ ដើម្បីឱ្យកន្សោមខាងក្រោមអវិជ្ជមាន ៖

1. $\frac{-2}{x+\frac{1}{3}}$

2. $\frac{2x(x-5)+(\sqrt{2}x-1)^2+1}{-2x(x-1)+(3+2x)x+1-x}$

3. $\frac{2015}{x^2-(x-1)(x+2)}$

4. $\frac{7x+2(x-1)+1-9x}{(1-x)^2+2(x-1)-x^2}$

5. $\frac{x(x-1)+2x-(x+2)^2}{x-(x+1)}$

6. $\frac{2x-3}{4x-1}$

7. $\frac{x-3+2(x-3)}{2x+2(x-1)}$

8. $\frac{x-\frac{1}{2}}{3x+\frac{1}{4}}$

9. $\frac{2x-1}{3x+2}$

10. $\frac{(x-1)^2+2-(x-3)x}{2x(x-4)-2x^2}$ ។

V. ស្រាយបញ្ជាក់ថាចំពោះគ្រប់តម្លៃ$a,b,c$ គេបាន ៖

1. $a^2+b^2+c^2\ge ab+ac+bc$
2. $a^2\left(1+b^2\right)+b^2\left(1+c^2\right)\left(1+a^2\right)\ge 6abc$
3. $a^2+b^2+c^2\ge\frac{1}{3}(a+b+c)^2$
4. $a^2+b^2+c^2+3\ge 2(a+b+c)$
5. $\left(a^3+b^3\right)^2\le\left(a^2+b^2\right)\left(a^4+b^4\right)$ ។

VI. ស្រាយបញ្ជាក់វិសមភាពខាងក្រោម ៖

1. $\frac{a^2}{b+c}+\frac{b^2}{c+a}+\frac{c^2}{a+b}\ge\frac{a+b+c}{2}$ ចំពោះគ្រប់ $a,b,c>0$
2. $a^4+b^4\ge a^3+b^3$ ចំពោះ $a+b=2$
3. $\frac{1}{a+b}+\frac{1}{b+c}+\frac{1}{a+c}>\frac{3}{a+b+c}$ ចំពោះគ្រប់ $a,b,c>0$
4. $x^2+y^2+z^2\ge\frac{1}{3}$ ចំពោះ $x+y+z=1$
5. គេឱ្យ$a,b,c$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។

ស្រាយបញ្ជាក់ថា: $ab+bc+ac\le a^2+b^2+c^2<2(ab+bc+ac)$

VII. ស្រាយបញ្ជាក់វិសមភាពខាងក្រោម:

1. $\left(a+\frac{1}{b}\right)\left(b+\frac{1}{c}\right)\left(c+\frac{1}{a}\right)\ge 8$ បើ $a,b,c>0$
2. $2a^2\ge 3ab-2b^2$ បើ $a,b\ge 0$
3. $(ab+bc+ca)^2\ge 3abc(a+b+c)$
4. $a^2+b^2\ge 2(a-b-1)$
5. $(2a+1)(b+3)(3a+2b)\ge 48ab$ បើ $a,b\ge 0$
6. $ab(a+b)+bc(b+c)+ac(a+c)\ge 6abc$
7. $2\sqrt{a}+3\sqrt[3]{b}\ge 5\sqrt[5]{ab}$ បើ $a,b\ge 0$
8. $3a^3+7b^3\ge 9ab^2$ បើ $a,b\ge 0$
9. $\sqrt{(a+b)(c+d)}+\sqrt{(a+c)(b+d)}+\sqrt{(a+d)(b+c)}\ge 6\sqrt[4]{abcd}$ ចំពោះគ្រប់ $a,b,c,d\ge 0$
10. $(1+a)(1+b)\ge\left(1+\sqrt{ab}\right)^2$
11. $\frac{a}{b^2}+\frac{b}{c^2}+\frac{c}{a^2}\ge\frac{1}{a}+\frac{1}{b}+\frac{1}{c}$ បើ $a,b,c>0$
12. $\frac{ab}{c}+\frac{ac}{b}+\frac{bc}{a}\ge a+b+c$ បើ $a,b,c>0$
13. $a^2+b^2\ge\frac{1}{2}$ បើ $a+b\ge 1$ ។

VIII. ចំណោទវិសមីការ:

1. ចូររកគ្រប់ចំនួនដែលបីដងនៃចំនួននោះ បន្ថែមពាក់កណ្តាលនៃចំនួននោះ ហើយបន្ថយ5 ធំជាងពីរដងចំនួននោះបន្ថយ 3 ។
2. ផលបូកនៃបីចំនួនគត់តគ្នាតូចជាង 1918 តែធំជាង 1914 ។ ចូររកចំនួនគត់ទាំងបីនោះ ។
3. ពាក់កណ្តាលនៃមួយចំនួនថែម5 ធំជាងឬស្មើនឹង3 ដងចំនួននោះបន្ថយ4 ។ រកចំនួននោះ ។
4. បច្ចុប្បន្នឪពុកមានអាយុ32 ឆ្នាំ ហើយកូនគាត់មានអាយុ12 ឆ្នាំ ។ តើនៅក្នុងចន្លោះប៉ុន្មានឆ្នាំទៅមុខទៀតទើបអាយុឪពុកតិចជាងបីដងប៉ុន្តែច្រើនជាងពីរដងអាយុកូន ?
5. គេឱ្យចតុកោណកែងមួយមានវិមាត្រ5m និង $x(m)$ ។ តើ $x$ ត្រូវយកតម្លៃណាខ្លះដើម្បីឱ្យចតុកោណកែងនោះមានបរិមាត្រធំជាង18m និងមានផ្ទៃក្រឡាតូចជាង$50m^2$ ។

6. បង្ហាញថាជ្រុងនីមួយៗនៃត្រីកោណមានប្រវែងខ្លីជាងកន្លះបរិមាត្រនៃត្រីកោណនោះ ។
7. សួនមួយមានរាងជាចតុកោណកែង ដែលបណ្តោយមានរង្វាស់លើសបីដងនៃទទឹងប្រវែង $15m$ ។ ដោយដឹងថាបរិមាត្រនៃសួនវែងបំផុតស្មើនឹង $94m$ ។ ចូររកបរិមាត្រអតិបរមានៃសួននោះបើរង្វាស់ជ្រុងជាចំនួនគត់ ។
8. សំបុត្រដែលត្រូវលក់ឱ្យភ្ញៀវមានពីរប្រភេទគឺ $A$ និង $B$ ដែលប្រភេទ $A$ មានចំនួនលើសប្រភេទ $B$ ចំនួន $5$ សន្លឹក ។ បើគេលក់សំបុត្រយ៉ាងច្រើនបាន $37$ សន្លឹក ។ ចូររកចំនួនសំបុត្រនៃប្រភេទនីមួយៗដែលអាចលក់បានច្រើនបំផុត ។
9. គេឱ្យត្រីកោណ $ABC$ ដែលមានជ្រុង $AB=12cm, AC=3cm$ ។ តើជ្រុង $BC$ មានប្រវែងប៉ុន្មាន ? បើគេដឹងថាប្រវែងរបស់វាជាពហុគុណនៃ $3$ ហើយប្រវែង $BC$ ជាចំនួនគត់ ។
10. បូណាចង់កាត់ក្រណាត់មួយឱ្យបានរាងចតុកោណកែងមួយដែលមានទទឹងប្រវែង $3cm$ និងក្រឡាផ្ទៃនៅចន្លោះ $15cm^2$ ទៅ $24cm^2$ ។ តើបូណាត្រូវជ្រើសរើសយកប្រវែងបណ្តោយប៉ុន្មានខ្លះ បើប្រវែងបណ្តោយជាចំនួនគត់ ?
11. សុខមានក្រដាសប្រាក់ពីរដុំ ។ ដុំទីមួយមានក្រដាសប្រាក់ $500$ រៀល ចំនួន $20$ សន្លឹក ដុំទីពីរមានក្រដាសប្រាក់ $1000$ រៀល ចំនួន $30$ សន្លឹក ។ ថ្ងៃមួយសុខហូត $25$ សន្លឹក ពីក្រដាសប្រាក់ទាំងពីរដុំនោះ ។ បើសុខចង់បានប្រាក់យ៉ាងតិច $17500$ រៀល ហើយយ៉ាងច្រើន $20000$ រៀល តើសុខអាចមានក្រដាសប្រាក់ $500$ រៀលប៉ុន្មានសន្លឹក ?
12. កសិដ្ឋានចិញ្ចឹមត្រីមួយកន្លែងបានលែងកូនត្រីបួនប្រភេទដែលមានចំនួន $8900$ ក្បាល $9200$ ក្បាល និង $9000$ ក្បាល ។ តើគេត្រូវលែងកូនត្រីប្រភេទចុងក្រោយប៉ុន្មានក្បាលទៀត ដើម្បីឱ្យបានមធ្យមនៃកូនត្រីទាំងបួនប្រភេទយ៉ាងច្រើន $9000$ ក្បាល ?
13. អេក្រង់កុំព្យូទ័រមួយមានទទឹងប្រវែង $20cm$ ខ្លីជាងពីរដងនៃប្រវែងបណ្តោយ ។ រកប្រវែងវិមាត្រអតិបរមាគិតជា $cm$ នៃអេក្រង់កុំព្យូទ័រនោះ ដោយដឹថាជ្រុងរបស់វាជាចំនួនគត់ ។
14. រកតម្លៃ $m$ ដើម្បីឱ្យសមីការ $2(x+1)=5+mx$ មានឫសតូចជាងឬស្មើ $1$ ។
15. ពហុកោណមួយមានផលបូកមុំក្នុងទាំងអស់តូចជាង $2008^\circ$ ។រកចំនួនជ្រុងច្រើនបំផុតនៃពហុកោណ ។
16. គេជួលទូកឆ្លងទន្លេ ហើយទូកដែលត្រូវជួលមានពីរប្រភេទគឺ ទូកធំអាចផ្ទុកមនុស្ស $12$ នាក់ ទូកតូចអាចផ្ទុកមនុស្ស $5$ នាក់ បើគេមានមនុស្ស $99$ នាក់ តើគេត្រូវជួលទូកធំប៉ុន្មាន និងទូកតូចប៉ុន្មាន ? បើគេដឹងថាទូកតូចមានតិចជាង $19$ ។
17. សហគមន៍មួយបានកំណត់ឱ្យប្រជាជនខ្ចីប្រាក់ជាក្រុមដូចតទៅ: ក្រុមមានគ្នា $3$ នាក់ អាចខ្ចីប្រាក់បាន $300\$$ ក្រុមមានគ្នា $5$ នាក់អាចខ្ចីបាន $600\$$ និងក្រុម $10$ នាក់អាចខ្ចីបាន $1000\$$ ។ គេដឹងថាក្រុម

មានគ្នា 3 នាក់ស្មើនឹង 2 ដងក្រុមមានគ្នា 5 នាក់ ។ រកចំនួនក្រុមនីមួយៗបើសហគមន៍ចំណាយប្រាក់ឱ្យខ្ចីអស់ 5600$ ។

**18.** នៅវិទ្យាល័យមួយបានចំណាយប្រាក់ 1000000 រៀល ដើម្បីទិញរង្វាន់ចែកជូនដល់សិស្សពូកែ ។ ក្នុងរង្វាន់នោះប្រភេទ 20000 រៀលក្នុងមួយសម្រាប់មានតិចជាង 10 ដងនៃប្រភេទ 10000 រៀលក្នុងមួយសម្រាប់ ហើយចំនួនរង្វាន់ផ្សេងទៀតគឺប្រភេទ 50000 រៀលក្នុងមួយសម្រាប់ ។ តើវិទ្យាល័យនេះត្រូវទិញរង្វាន់ប្រភេទនីមួយៗចំនួនប៉ុន្មានសម្រាប់ ?

**19.** កសិករម្នាក់មានដំឡូង 5 ល្អីដែលមានទម្ងន់រៀងគ្នាគឺ $7\,kg, 10\,kg, 14\,kg, 18\,kg$ និង $19\,kg$ ។ គាត់បានលក់ដំឡូង 2 ល្អីឱ្យមនុស្ស 2 នាក់ ។ អ្នកទីមួយទិញបានដំឡូងដែលមានទម្ងន់ 2 ដង ទម្ងន់ដំឡូងនៃអ្នកទីពីរ ។

ក. រកទម្ងន់ដំឡូងដែលនៅសល់ ។

ខ. កសិករនោះបានយកដំឡូងដែលនៅសល់ទៅលក់បន្តទៀត ។ ដោយមានការតថ្លៃពីអ្នកទិញគាត់លក់បានតម្លៃនៅចន្លោះពី 11200 រៀលទៅ 15400 រៀល។ រកតម្លៃរបស់ដំឡូងក្នុង $1\,kg$ ។

## ☞ កម្រិតII ( ថ្នាក់ទី10 )

I. ដោះស្រាយវិសមីការខាងក្រោម:

1. $3x^2+3x+4\ge 2\left(x^2-3x+1\right)$
2. $7x^2-x+1<2\left(x^2-3x-2\right)$
3. $\frac{1}{2}x\left(2x+8\right)>x-1$
4. $5x^2-3x+9\ge\frac{1}{2}x+3$
5. $\frac{9}{3}x^2-x+2>1+x^2$
6. $\frac{5}{2}x^2+3x-1\le 2\left(x-3\right)$
7. $\frac{2}{3}x-\frac{x^2}{6}+1<\frac{1}{4}x\left(8x+4\right)$
8. $2x^2+5x+1<0$
9. $\left(x-1\right)^2+3x+1<0$
10. $9x^2-3x+1>7x^2+4x+10$
11. $\left(x-5\right)\left(x+4\right)\le x^2+x\left(2x+4\right)$
12. $3x^2+7x+2<\left(x-1\right)\left(x+2\right)$
13. $5\left(7x-1\right)^2+35>\sqrt{2}+1$
14. $2\left(x+3\right)^2-70\ge 100$
15. $\left(x-3\right)^2-3x+9<4-x$
16. $\left(x+2\right)^2+2\left(x+2\right)\left(x-1\right)+\left(x-1\right)^2>0$
17. $9x^2-x\left(4x+2\right)-7x\ge 0$
18. $\left(x+\frac{5}{8}\right)^2+\frac{49}{16}>0$
19. $5\sqrt{5}x^2-10x+\sqrt{5}\le 0$
20. $2\sqrt{3}x^2+2\sqrt{3}x+\sqrt{2}<0$ ។

II. រកតម្លៃ $x$ ដើម្បីឱ្យកន្សោមខាងក្រោម វិជ្ជមានឬស្មើសូន្យ:

1. $\frac{2x+5}{x^2+2x-1}$
2. $\frac{2x^2+1-x}{7x^2-5x+1}$
3. $\frac{\left(x-1\right)\left(x+2\right)}{\left(x+1\right)\left(x^2+2x-3\right)}$
4. $\frac{5x^2+2x+6}{x^3+3x^2+2x}$
5. $\frac{2x^4-5x^2+3}{x^3-2x^2-5x+6}$ ។

III. រកតម្លៃ $x$ ដើម្បីឱ្យកន្សោមខាងក្រោម អវិជ្ជមាន:

1. $\frac{7x^2+9x+2}{2017}$
2. $\frac{5x^2-4x+1}{(x+1)(x^2-2)}$
3. $\frac{-3x^2+2x+1}{x^2+2x+1}$
4. $\frac{x^2-36}{x^2+2x-5}$
5. $\frac{x^3-6x^2+11x-6}{x^3-1}$ ។

IV. រកតម្លៃ $k$ ដើម្បីឱ្យកន្សោមខាងក្រោម មានឫសពីរក្នុង $\mathbb{R}$ ៖

1. $kx^2+3(k+2)x+3k-1=0$
2. $kx^2-2(k-2)x+4k-2=0$
3. $(k-1)x^2-3kx+2k+3=0$
4. $(k+1)x^2-4kx+k+1=0$
5. $(k-3)x^2+(2k-1)x+2k-3=0$ ។

V. រកតម្លៃ $k$ ដើម្បីឱ្យកន្សោមខាងក្រោម មានឫសពីរផ្សេងគ្នាក្នុង $\mathbb{R}$ ៖

1. $kx^2+2(k+2)x+3k=0$
2. $(k-1)x^2-2(k-1)x-1+k=0$
3. $(k-3)x^2+4(k+2)x-k=0$
4. $(k-2)x^2+3kx+2k-3=0$
5. $(k+1)x^2-(2k-1)x+k-2=0$ ។

VI. រកតម្លៃ $k$ ដើម្បីឱ្យកន្សោមខាងក្រោម គ្មានឫសក្នុង $\mathbb{R}$ ៖

1. $2kx^2+(k-1)x+3k=0$
2. $3kx^2-2(k+1)x-k+1=0$
3. $(2k-1)x^2-kx+3k-2=0$
4. $(5k-2)x^2+2kx-k-1=0$
5. $(3k-1)x^2-4kx-k+2=0$ ។

VII. ដោះស្រាយប្រព័ន្ធវិសមីការខាងក្រោម:

1. $\begin{cases} 2x^2+5x+7\geq 0 \\ x^2-4x+4<0 \end{cases}$
2. $\begin{cases} \frac{1}{2}x^2-2x+3>0 \\ \frac{3}{2}x^2-x+4\leq 0 \end{cases}$
3. $\begin{cases} \frac{7}{2}x^2+4x-1\leq 0 \\ 3x(x-1)+3\geq 0 \end{cases}$
4. $\begin{cases} 2x^2+3x-1\geq 0 \\ \frac{1}{2}(x-1)+x^2\geq 2x-1 \end{cases}$
5. $\begin{cases} 5x(x-2)+2x>2(x-1)+1 \\ 9(x^2-2x)+1>3x(1-x) \end{cases}$
6. $\begin{cases} \frac{x+1}{2}+\frac{x^2-1}{6}\geq 2x-3 \\ \frac{(x+1)(x-2)}{4}+\frac{1}{2}\leq x^2+2+\frac{x}{3} \end{cases}$
7. $\begin{cases} \frac{(x+2)x}{2}+\frac{1}{3}<x+2 \\ \frac{x^2+3x+1}{4}+\frac{x+2}{2}\leq x^2 \end{cases}$
8. $\begin{cases} \frac{x^2+3x-1}{5}+\frac{1}{2}<\frac{x^2-1}{3} \\ 2x^2-3x+4<3x(x-2)+5 \end{cases}$
9. $\begin{cases} \frac{2x^2-4}{3}+\frac{1}{2}x>2x \\ \frac{(x-2)(x+5)}{8}-\frac{1}{3}\geq \frac{x^2+1}{2}+\frac{x}{12} \end{cases}$
10. $\begin{cases} \frac{x^2-2}{5}-\frac{3x}{2}<\frac{x-1}{3}-\frac{1}{10} \\ 7x^2+3x-\frac{1}{2}>x^2-1 \end{cases}$ ។

VIII. សិក្សាអត្ថិភាពនិងសញ្ញាឫសរបស់សមីការខាងក្រោម ( $m$ ជាប៉ារ៉ាម៉ែត្រ )៖

1. $mx^2+4(m-2)x+m-5=0$
2. $(m-1)x^2+2(m-2)x+1-m=0$
3. $(m+2)x^2-(1-m)x-2+m=0$
4. $(m-3)x^2-3mx-m=0$
5. $(m+1)x^2-4mx+m-1=0$
6. $(m-1)x^2+(2m-3)x+m+1=0$
7. $\dfrac{x^2-2(m+1)x+2m+5}{x^2-3x+2}=0$

IX. គេឱ្យត្រីកោណមួយដែលមានរង្វាស់ជ្រុង $a,b,c$ ។ ចូរធ្វើការស្រាយបញ្ជាក់ថា សមីការ $a^2x^2+(a^2+b^2-c^2)x+b^2=0$ គ្មានឫស រួចទាញបញ្ជាក់ថា $a^2x^2+(a^2+b^2-c^2)x+b^2>0$ ចំពោះ $\forall x\in\mathbb{R}$ ។

X. គេឱ្យសមីការដឺក្រេទីពីរ: $x^2+2(m+1)x+2m^2-m-3=0$ ។

1. កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការមានឫសពីរ $x_1,x_2$ ដែលផ្ទៀងផ្ទាត់នឹង $2x_1-x_2=m+5$ ។
2. កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការមានឫសពីរ $x_1,x_2$ ដែលធ្វើយ៉ាងណាឱ្យ $x_1^3+x_2^3=54(x_1+x_2)$ ។
3. កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការមានឫសពីរ $x_1,x_2$ ដែលធ្វើយ៉ាងណាឱ្យ $\dfrac{x_1}{x_2}+\dfrac{x_2}{x_1}\geq\dfrac{2m-3}{10}$ ។

XI. គេឱ្យសមីការដឺក្រេទីពីរ: $x^2+mx+1=0$ ។

1. កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការមានឫសពីរ $x_1,x_2$ ដែលផ្ទៀងផ្ទាត់ $\left(\dfrac{x_1}{x_2}\right)^2+\left(\dfrac{x_2}{x_1}\right)^2>14$ ។
2. កំណត់តម្លៃ $m$ ដើម្បីឱ្យសមីការមានឫសពីរ $x_1,x_2$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $x_1^3+x_2^3\leq 2$ ។
3. កំណត់តម្លៃ $m\in\mathbb{Z}$ ដើម្បីឱ្យសមីការមានឫសពីរ $x_1,x_2$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $A=\dfrac{(x_1-x_2)^2}{x_1+x_2+1}$ ជាចំនួនគត់ ។

## ស្នងការយល់ពីឧត្តមស្នងការសហប្រជាជាតិ
## សម្រាប់ជនភៀសខ្លួន

( U.N.H.C.R : United Nations High Commissioner for Refugees )

* ចាប់ពីឆ្នាំ១៩៥១មកអង្គការនេះបានផ្តល់ជំនួយដល់ជនភៀសខ្លួន ដោយសារសង្គ្រាម ជនទុរភិក្ស និងជនដែលគេត្រូវគេធ្វើទុក្ខបុកម្នេញលើពិភពលោកចំនួនជាង ៣០០.០០០.០០០ នាក់ ។
* នៅឆ្នាំ ១៩៩៤ មនុស្សជិត៣០០.០០០.០០០ នាក់ ដែលជួបប្រទះទុរភិក្សធ្ងន់ធ្ងរនៅក្នុង ៣៦ប្រទេស ហើយដែលបានទទួលជំនួយសង្គ្រោះជាបន្ទាន់ពីអង្គការនានា ។
* ទីស្នាក់ការនៅ: ទីក្រុងសឺណែវ ប្រទេសស្វីស ។

« និយាយពាក្យកុហក ដូចខ្លាក់លាមកចេញពីមាត់ »

# ដំណោះស្រាយសមីការ

I. ដោះស្រាយសមីការ

1. $4(x-5)=2x-14$

$4x-20=2x-14$

$4x-2x=-14+20$

$\Rightarrow 2x=6$ ឬ $x=3$

ដូចនេះ $x=3$ ជាឬសនៃសមីការ ។

2. $x-(8+4x)=2(3x-4)$

$x-4x-8=6x-8$

$-3x-6x=-8+8$

$\Rightarrow -6x=0$ ឬ $x=0$

ដូចនេះ $x=0$ ជាឬសនៃសមីការ ។

3. $5x-(8-x)=2[-4-(3+5x)-13]$

$5x-8+x=2(-17-3-5x)$

$5x-8+x=2(20-5x)$

$6x+10x=-40+8$

$\Rightarrow 16x=-32$ ឬ $x=-2$

ដូចនេះ $x=-2$ ជាឬសនៃសមីការ ។

4. $-[k-(4k+2)]=2+(2k+7)$

$-(-k-4k-2)=2+2k+7$

$3k+2=2+2k+7$

$3k-2k=9-2$

$\Rightarrow k=7$

ដូចនេះ $k=7$ ជាឬសនៃសមីការ ។

5. $2-4\langle -2x+3[-1+5(1-x)]-1\rangle=0$

$2-4\langle -2x+3[4-5x]-1\rangle=0$

$2-4\langle -2x+12-15x-1\rangle=0$

$2-4\langle -17x+11\rangle=0$

$2+68x-44=0$

$\Rightarrow 68x=42$ ឬ $x=\frac{42}{68}=\frac{21}{34}$

ដូចនេះ $x=\frac{21}{34}$ ជាឬសនៃសមីការ ។

6. $\sqrt{3}(x-2)-2\sqrt{2}x=2\left(\sqrt{3}x-3-\sqrt{2}x\right)$

$\sqrt{3}x-2\sqrt{3}-2\sqrt{2}x=2\sqrt{3}x-6-2\sqrt{2}x$

$\sqrt{3}x-2\sqrt{3}x=2\sqrt{3}-6$

$-\sqrt{3}x=2\sqrt{3}-6$

$\Rightarrow x=\frac{2\sqrt{3}-6}{-\sqrt{3}}\vee x=\frac{6\sqrt{3}-6}{3}=2\sqrt{3}-2$

ដូចនេះ $x=2\sqrt{3}-2$ ជាឬសនៃសមីការ ។

7. $6(7x+8)-7(6x+4)=5(6+7x)-35(x-1)$

$42x+48-35x-28=30+35x-35x+35$

$42x-35x=65-20$

$\Rightarrow 7x=45$ ឬ $x=\frac{45}{7}$

ដូចនេះ $x=\frac{45}{7}$ ជាឬសនៃសមីការ ។

8. $8(3-2x)-16(1-x)-3(x-4)=20-3x$

$24-16x-16+16x-3x+12=20-3x$

$-3x+3x=20-20$

$\Rightarrow 0x=0$

ដូចនេះ សមីការមានឬសច្រើនរាប់មិនអស់ ។

9. $(2x+3)^2-(2x+5)=4x(x+4)+4$

$4x^2+12x+9-2x-5=4x^2+16x+4$

$10x-16x=4-4$

$\Rightarrow -6x=0$ ឬ $x=0$

ដូចនេះ $x=0$ ជាឬសនៃសមីការ ។

10. $(3x-5)^2+(x-2)=(4x+1)^2-6x(x+1)$

$9x^2-30x+25+x^2-4x+4=16x^2+8x+1-6x^2-6x$

$10x^2-34x-10x^2-2x=1-29$

$\Rightarrow -36x=-28$ ឬ $x=\frac{7}{9}$

ដូចនេះ $x=\frac{7}{9}$ ជាឬសនៃសមីការ ។

11. $\left(x-2\right)\left(3x+4\right)=x\left(3x+1\right)-10$

$3x^2+4x-6x-8=3x^2+x-10$

$3x^2-2x-3x^2-x=-10+8$

$\Rightarrow -3x=-2$ ឬ $x=\frac{2}{3}$

ដូចនេះ: $x=\frac{2}{3}$ ជាឫសនៃសមីការ ។

12. $\left(2x-5\right)\left(2x+5\right)-4x^2+3=0$

$4x^2-25-4x^2+3=0$

$\Rightarrow 0x^2=21$

ដូចនេះ: សមីការគ្មានឫស ។

13. $\left(x+4\right)^2-\left(x-4\right)^2=32$

$x^2+8x+16-\left(x^2-8x+16\right)=32$

$\Rightarrow 16x=32$ ឬ $x=2$

ដូចនេះ: $x=2$ ជាឫសនៃសមីការ ។

14. $3\left(x+1\right)x-2x\left(x-1\right)=\left(x-1\right)\left(x+1\right)$

$3x^2+3x+-2x^2+2x=x^2-1$

$\Rightarrow 5x=-1$ ឬ $x=-\frac{1}{5}$

ដូចនេះ: $x=-\frac{1}{5}$ ជាឫសនៃសមីការ ។

15. $\left(2x+4\right)\left(3x-1\right)=\left(x-1\right)\left(2x+1\right)+4x^2$

$6x^2-2x+12x-4=2x^2+x-2x-1+4x^2$

$11x=3$

ដូចនេះ: $x=\frac{3}{11}$ ជាឫសនៃសមីការ ។

16. $7x\left(x-1\right)+8\left(x^2-1+2x\right)=\left(5x-1\right)\left(3x+2\right)$

$7x^2-7x+8x^2-8+16x=15x^2+10x-3x-2$

$9x-7x=-2+8$

$\Rightarrow 2x=6$ ឬ $x=3$

ដូចនេះ: $x=3$ ជាឫសនៃសមីការ ។

17. $x\left(x+3x^2\right)+3x^2-7x\left(x+1\right)=3\left(x^3-x^2+12\right)$

$x^2+3x^3+3x^2-7x^2-7x=3x^3-3x^2+36$

$\Rightarrow -7x=36$ ឬ $x=-\frac{36}{7}$

ដូចនេះ: $x=-\frac{36}{7}$ ជាឫសនៃសមីការ ។

18. $\left(x+1\right)\left(x+4\right)+\left(x+2\right)\left(x+3\right)=\left(2x+1\right)\left(x-2\right)+10$

$x^2+5x+4+x^2+5x+6=2x^2-4x+x-2+10$

$10x+3x=8-6$

$\Rightarrow 13x=2$ ឬ $x=\frac{2}{13}$

ដូចនេះ: $x=\frac{2}{13}$ ជាឫសនៃសមីការ ។

19. $2x+10x^2-x\left(x-1\right)=\left(3x+1\right)^2+2\left(x-1\right)$

$2x+10x^2-x^2+x=9x^2+6x+1+2x-2$

$3x-8x=-1$

$\Rightarrow -5x=-1$ ឬ $x=\frac{1}{5}$

ដូចនេះ: $x=\frac{1}{5}$ ជាឫសនៃសមីការ ។

20. $\sqrt{3}\left(x^2+3x-1\right)=\sqrt{3}\left(x-1\right)^2+2\sqrt{3}x-1$

$\sqrt{3}\left(x^2+3x-1\right)=\sqrt{3}\left(x^2-2x+1\right)+2\sqrt{3}x-1$

$\sqrt{3}x^2+3\sqrt{3}x-\sqrt{3}=\sqrt{3}x^2-2\sqrt{3}x+\sqrt{3}+2\sqrt{3}x-1$

$\Rightarrow 3\sqrt{3}x=2\sqrt{3}-1$ ឬ $x=\frac{2\sqrt{3}-1}{3\sqrt{3}}=\frac{6-\sqrt{3}}{9}$

ដូចនេះ: $x=\frac{6-\sqrt{3}}{9}$ ជាឫសនៃសមីការ ។

II. *ដោះស្រាយសមីការ*

1. $\frac{5x}{3}+\frac{9}{8}=\frac{7x}{6}+\frac{3}{16}$

ដោយ $3=3$ , $8=2^3$ , $6=2\times3$ , $16=2^4$ នាំឱ្យ $PPCM=2^4\times3=48$

គេបាន: $\frac{80x+54}{48}=\frac{56x+9}{48}$

$80x-56x=9-54$

$\Rightarrow 24x = -45$ ឬ $x = -\frac{45}{24} = -\frac{15}{8}$

ដូចនេះ: $x = -\frac{15}{8}$ ជាឫសនៃសមីការ ។

2. $\frac{2x+1}{3} + \frac{5-x}{4} = 1 - \frac{3x+2}{6}$

ដោយ $3 = 3$ , $4 = 2^2$ , $6 = 2\times 3$ នាំឱ្យ $PPCM = 2^2\times 3 = 12$

គេបាន: $\frac{8x+4+15-3x}{12} = \frac{12-6x-4}{12}$

$5x + 6x = 8 - 19$

$\Rightarrow 11x = -11$ ឬ $x = -1$

ដូចនេះ: $x = -1$ ជាឫសនៃសមីការ ។

3. $\frac{2(3x-8)}{9} - \frac{5(x-3)}{3} = \frac{3(x-8)}{4} + \frac{17}{36}$

ដោយ $9 = 3^2$ , $3 = 3$ , $4 = 2^2$ , $36 = 2^2\times 3^2$ នាំឱ្យ $PPCM = 2^2\times 3^2 = 36$

គេបាន: $\frac{24x-64-60x+180}{36} = \frac{27x-216+17}{36}$

$-36x - 27x = -199 - 116$

$\Rightarrow -63x = -315$ ឬ $x = 5$

ដូចនេះ: $x = 5$ ជាឫសនៃសមីការ ។

4. $\frac{3x-5}{8} + \frac{x+12}{12} = 1$

ដោយ $8 = 2^3$ , $12 = 2^2\times 3$ នាំឱ្យ $PPCM = 2^2\times 3 = 24$

គេបាន: $\frac{3(3x-5)+2(x+12)}{24} = \frac{24}{24}$

$9x - 15 + 2x + 24 = 24$

$\Rightarrow 11x = 15$ ឬ $x = \frac{15}{11}$

ដូចនេះ: $x = \frac{15}{11}$ ជាឫសនៃសមីការ ។

5. $\frac{x+4}{3} - \frac{x-4}{5} = 2 + \frac{3x-1}{15}$

$\frac{5(x+4)-3(x-4)}{15} = \frac{30+3x-1}{15}$

$5x + 20 - 3x + 12 = 29 + 3x$

$2x - 3x = 29 - 32$

$\Rightarrow -x = -3$ ឬ $x = 3$

ដូចនេះ: $x = 3$ ជាឫសនៃសមីការ ។

*បញ្ជាក់:* ការរកភាគបែងរួមនៃសមីការគឺត្រូវរកតាម $PPCM$ ដូចបង្ហាញក្នុងលំហាត់ពីទី 1- 4 សម្រាប់ជាគំរូ ហើយក្នុងការដោះស្រាយយើងអាចរក $PPCM$ នៅខាងក្រៅក្នុងការអនុវត្ត យើងគួរសរសេរតាមរបៀបលំហាត់ទី5 ,6 ,7,…..ឡើងទៅ ។

6. $1+\frac{2x}{3}-\frac{1}{2}-x=\frac{1-x}{3}$

$\frac{6+4x-3-6x}{6}=\frac{2-2x}{6}$

$-2x+2x=2-3$

$\Rightarrow 0x=-1$

ដូចនេះៈ សមីការគ្មានឫស ។

7. $3x+\frac{5x-3}{2}=37$

$\frac{6x+5x-3}{2}=\frac{37\times 2}{2}$

$11x=74+3$

$\Rightarrow x=\frac{77}{11}=7$

ដូចនេះៈ $x=7$ ជាឫសនៃសមីការ ។

8. $\left(\frac{3x}{4}-\frac{2}{5}\right)+\left(\frac{2x}{3}+0.6\right)-\left(\frac{7x}{12}-0.3\right)=5.8$

$\frac{3x}{4}-\frac{2}{5}+\frac{2x}{3}+0.6-\frac{7x}{12}+0.3=5.8$

$\frac{9x+8x-7x}{12}+0.5=5.8$

$\frac{10x}{12}=5.8-0.5$

$\Rightarrow x=\frac{5.3\times 12}{10}=6.36$

ដូចនេះៈ $x=6.36$ ជាឫសនៃសមីការ ។

9. $x+\frac{3}{2}-\frac{4x-3}{4}=1-\frac{5x-12}{6}$

$\frac{12x+18-12x+9}{12}=\frac{12-10x+24}{12}$

$27-36=-10x$

$\Rightarrow x=\frac{9}{10}$

ដូចនេះៈ $x=\frac{9}{10}$ ជាឫសនៃសមីការ ។

10. $8(x-2)+3=7x+\frac{2x-1}{2}-3$

$\frac{16x-32+6}{2}=\frac{14x+2x-1-6}{2}$

$16x-16x=-7+26$

$\Rightarrow 0x=19$

ដូចនេះៈ សមីការគ្មានឫស ។

11. $\frac{(2x+1)^2}{4}-\frac{3(x+2)^2}{6}=\frac{x(x-2)}{2}$

$\frac{(2x+1)^2}{4}-\frac{(x+2)^2}{2}=\frac{x(x-2)}{2}$

$\frac{(4x^2+4x+1)-2(x^2+4x+4)}{4}=\frac{2x(x-2)}{4}$

$4x^2+4x+1-2x^2-8x-8=2x^2-4x$

$2x^2-4x-2x^2+4x=7$

$\Rightarrow 0x=7$

ដូចនេះ: សមីការគ្មានឫស ។

12. $\frac{(x-2)^2}{3}+\frac{x(x-3)}{5}=\frac{(8x+7)(x-1)}{15}+\frac{4}{5}$

$\frac{5(x^2-4x+4)+3x(x-3)}{15}=\frac{(8x^2-x-7)+12}{15}$

$5x^2-20x+20+3x^2-9x=8x^2-x-7+12$

$8x^2-29x-8x^2+x=5-20$

$\Rightarrow -28x=-15$

$\Rightarrow x=\frac{15}{28}$

ដូចនេះ: $x=\frac{15}{28}$ ជាឫសនៃសមីការ ។

13. $\frac{x(1+x)}{4}+\frac{4x}{8}=\frac{2x(x-1)}{6}+\frac{1}{2}-\frac{x^2}{12}$

$\frac{6x(1+x)+12x}{24}=\frac{8x(x-1)+12-2x^2}{24}$

$6x+6x^2+12x=8x^2-8x+12-2x^2$

$6x^2+18x-6x^2+8x=12$

$\Rightarrow 26x=12$

$\Rightarrow x=\frac{12}{26}=\frac{6}{13}$

ដូចនេះ: $x=\frac{6}{13}$ ជាឫសនៃសមីការ ។

14. $\frac{(x-1)(x+5)}{3}+\frac{3x(x+7)}{6}=\frac{(x+5)(3x-4)}{4}+\frac{x^2}{12}$

$\frac{4(x^2+4x-5)+6x(x+7)}{12}=\frac{3(3x^2+11x-20)+x^2}{12}$

$4x^2+16x-20+6x^2+42x=9x^2+33x-60+x^2$

$10x^2+58x-10x^2-33x=-60+20$

$\Rightarrow 25x=-40$

$\Rightarrow x=-\frac{40}{25}=-\frac{8}{5}$

ដូចនេះ: $x=-\frac{8}{5}$ ជាឫសនៃសមីការ ។

15. $\frac{3}{5}\left[\frac{5}{3}\left(\frac{x}{4}+1\right)+5\right]-\frac{1}{2}=x$

$\frac{x}{4}+1+3-\frac{1}{2}=x$

$\frac{x}{4}-x=-\frac{7}{2}$

$\Rightarrow -3x=-14$ ឬ $x=\frac{14}{3}$

ដូចនេះ $\boxed{x=\frac{14}{3}\text{ ជាឫសនៃសមីការ}}$ ។

16. $\frac{x-4}{2013}+\frac{x-3}{2014}+\frac{x-2}{2015}+\frac{x-1}{2016}+\frac{x}{2017}=5$

$\frac{x-4}{2013}-1+\frac{x-3}{2014}-1+\frac{x-2}{2015}-1+\frac{x-1}{2016}-1+\frac{x}{2017}-1=0$

$\frac{x-4-2013}{2013}+\frac{x-3-2014}{2014}-1+\frac{x-2-2015}{2015}+\frac{x-1-2016}{2016}+\frac{x-2017}{2017}=0$

$\frac{x-2017}{2013}+\frac{x-2017}{2014}+\frac{x-2017}{2015}+\frac{x-2017}{2016}+\frac{x-2017}{2017}=0$

$\left(\frac{1}{2013}+\frac{1}{2014}+\frac{1}{2015}+\frac{1}{2016}+\frac{1}{2017}\right)(x-2017)=0$

$\Rightarrow x-2017=0$ ឬ $x=2017$

ដូចនេះ $\boxed{x=2017\text{ ជាឫសនៃសមីការ}}$ ។

17. ក. បើ $\frac{1}{x+2}=5$ តើ $\frac{1}{x+3}$ ស្មើនឹងប៉ុន្មាន ?

គេមាន: $\frac{1}{x+2}=5\Leftrightarrow x+2=\frac{1}{5}$

$\Leftrightarrow x+2+1=\frac{1}{5}+1$

$\Leftrightarrow x+3=\frac{6}{5}$

$\Leftrightarrow \frac{1}{x+3}=\frac{5}{6}$

ម្យ៉ាងទៀត: $\frac{1}{x+2}=5\Leftrightarrow 1=5x+10\Rightarrow x=-\frac{9}{5}$

នាំឱ្យ $\frac{1}{x+3}=\frac{1}{-\frac{9}{5}+3}=\frac{1}{\frac{6}{5}}=\frac{5}{6}$

ដូចនេះ $\boxed{\frac{1}{x+3}=\frac{5}{6}}$ ។

ខ. រកតម្លៃ $x$

$\frac{x}{3}-\frac{x}{6}+\frac{x}{9}-\frac{x}{12}=-1+\frac{1}{2}-\frac{1}{3}+\frac{1}{4}$

$\frac{x}{3}+1-\frac{x}{6}-\frac{1}{2}+\frac{x}{9}+\frac{1}{3}-\frac{x}{12}-\frac{1}{4}=0$

$\left(\frac{x}{3}+1\right)-\left(\frac{x}{6}+\frac{1}{2}\right)+\left(\frac{x}{9}+\frac{1}{3}\right)-\left(\frac{x}{12}+\frac{1}{4}\right)=0$

$\frac{x+3}{3}-\frac{x+3}{6}+\frac{x+3}{9}-\frac{x+3}{12}=0$

$\left(\frac{1}{3}-\frac{1}{6}+\frac{1}{9}-\frac{1}{12}\right)(x+3)=0$

$\Rightarrow x+3=0$ ឬ $x=-3$

ដូចនេះ: $x=-3$ ជាតម្លៃដែលត្រូវរក ។

18. $\frac{x-ab}{a+b}+\frac{x-bx}{b+c}+\frac{x-ac}{a+c}=a+b+c$

ដោយ $a+b\neq0$ , $b+c\neq0$ , $a+c\neq0$ , $x$ ជាអញ្ញាត

គេបាន $\frac{x-ab}{a+b}-c+\frac{x-bx}{b+c}-a+\frac{x-ac}{a+c}-b=0$

$\frac{x-ab-c(a+b)}{a+b}+\frac{x-bc-a(b+c)}{b+c}+\frac{x-ac-b(a+c)}{a+c}=0$

$\frac{x-ab-ac-bc}{a+b}+\frac{x-bc-ab-ac}{b+c}+\frac{x-ac-ab-bc}{a+c}=0$

$\left(\frac{1}{a+b}+\frac{1}{b+c}+\frac{1}{a+c}\right)(x-ab-ac-bc)=0$

$\Rightarrow x-ab-ac-bc=0$ ឬ $x=ab+bc+ac$

ដូចនេះ: $x=ab+bc+ac$ ជាឫសរបស់សមីការ ។

19. ក. $\frac{x-a}{bc}+\frac{x-b}{ac}+\frac{x-c}{ab}=2\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$

ដោយ $a\neq0$ , $b\neq0$ , $c\neq0$ , $x$ ជាអញ្ញាត

គេបាន $\frac{(x-a)a}{abc}+\frac{(x-b)b}{abc}+\frac{(x-c)c}{abc}=2\left(\frac{bc+ac+ab}{abc}\right)$

$\frac{ax-a^2+bx-b^2+cx-c^2}{abc}=\frac{2bc+2ac+2ab}{abc}$

$(a+b+c)x=a^2+b^2+c^2+2bc+2ac+2ab$

$\Rightarrow x=\frac{(a+b+c)^2}{a+b+c}$ ឬ $x=a+b+c$

ដូចនេះ: $x=a+b+c$ ជាឫសរបស់សមីការ ។

ខ. $\frac{a+b-x}{c}+\frac{b+c-x}{a}+\frac{a+c-x}{b}+\frac{4x}{a+b+c}=1$

ដោយ $a\neq0$ , $b\neq0$ , $c\neq0$ , $a+b+c\neq0$ , $x$ ជាអញ្ញាត

គេបាន $\frac{a+b-x}{c}+1+\frac{b+c-x}{a}+1+\frac{a+c-x}{b}+1-3-1+\frac{4x}{a+b+c}=0$

$\frac{a+b-x+c}{c}+\frac{b+c-x+a}{a}+\frac{a+c-x+b}{b}-4\left(1-\frac{x}{a+b+c}\right)=0$

$\frac{a+b+c-x}{c}+\frac{a+b+c-x}{a}+\frac{a+b+c-x}{b}-4\left(\frac{a+b+c-x}{a+b+c}\right)=0$

$\left(\frac{1}{c}+\frac{1}{a}+\frac{1}{b}-\frac{4}{a+b+c}\right)(a+b+c-x)=0$

$\Rightarrow a+b+c-x=0$ ឬ $x=a+b+c$

ដូចនេះ $\boxed{x=a+b+c \text{ ជាឫសរបស់សមីការ}}$ ។

20. $\frac{3}{2}+\frac{9}{2}+\frac{15}{2}+...+\frac{6x-3}{2}=\frac{75}{2}$

$\frac{3}{2}(1+3+5+...+2x-1)=\frac{75}{2}$

$1+3+5+...+(2x-1)=25$

តែ $1+3+5+...+(2x-1)=x^2$ , $x>0$

ព្រោះ $1=1^2$ មាន 1 តួ

$1+3=2^2$ មាន 2 តួ

$1+3+5=3^2$ មាន 3 តួ

$1+3+5+7=4^2$ មាន 4 តួ

……………………

…………………....

$1+3+5+7+...+(2x-3)=(x-1)^2$ មាន $(x-1)$ តួ

$1+3+5+7+...+(2x-3)+(2x-1)=x^2$ មាន $x$ តួ

សមីការទៅជា: $x^2=25$ ឬ $x=5$

ដូចនេះ $\boxed{x=5 \text{ ជាឫសនៃសមីការ}}$ ។

III. *ដោះស្រាយ និងពិភាក្សាសមីការ* ( $m$ ជាប៉ារ៉ាម៉ែត )

1. $(1-m)x=3m-1$

○ បើ $\begin{cases}1-m\neq 0\\3m-1\neq 0\end{cases}\Leftrightarrow\begin{cases}m\neq 1\\m\neq\frac{1}{3}\end{cases}$ នាំឱ្យសមីការមានឫសមួយគត់គឺ $x=\frac{3m-1}{1-m}$ ។

○ បើ $\begin{cases}1-m=0\\3m-1=0\end{cases}\Leftrightarrow\begin{cases}m=1\\m=\frac{1}{3}\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់។

○ បើ $1-m=0\Rightarrow m=1$ ឱ្យសមីការមានរាង $0x=2$ នោះសមីការគ្មានឫស ។

○ បើ $3m-1=0\Rightarrow m=\frac{1}{3}$ ឱ្យសមីការមានរាង $\frac{2}{3}x=0$ នោះសមីការមានឫសមួយគឺ $x=0$

សន្និដ្ឋាន:

- សមីការមានឫសមយខុសពីសូន្យ កាលណា $m\neq 1$ និង $m\neq\frac{1}{3}$
- សមីការមានឫសមួយស្មើសូន្យ កាលណា $m=\frac{1}{3}$
- សមីការគ្មានឫស កាលណា $m=1$
- សមីការមានឫសច្រើនរាប់មិនអស់ កាលណា $m=1$ និង $m=\frac{1}{3}$ ។

2. $x(x-4)+4m=x^2$

$x^2-4x+4m=x^2$

$-4x=-4m$ ឬ $x=m$

- បើ $m\neq 0$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យ គឺ $x=m$ ។
- បើ $m=0$ នាំឱ្យសមីការមានឫសមួយស្មើសូន្យ គឺ $x=0$ ។

សន្និដ្ឋាន:

| |
|---|
| បើ $m\neq 0$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យ គឺ $x=m$ ។ |
| បើ $m=0$ នាំឱ្យសមីការមានឫសមួយស្មើសូន្យ គឺ $x=0$ ។ |

3. $3mx+4m=13m+2mx$

$3mx-2mx=13m-4m$

$mx=9m$

- បើ $m\neq 0$ នាំឱ្យសមីការមានឫសមួយ គឺ: $x=9$
- បើ $m=0$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់ ។

សន្និដ្ឋាន:

| |
|---|
| - សមីការមានឫសមួយខុសពីសូន្យ គឺ $x=9$ កាលណា $m\neq 0$ |
| - សមីការមានឫសច្រើនរាប់មិនអស់ កាលណា $m=0$ ។ |

4. $\frac{2m}{5}x-\frac{m}{10}=1-\frac{7}{10}x$

$\left(\frac{2m}{5}+\frac{7}{10}\right)x=1+\frac{m}{10}$

$(4m+7)x=10+m$

- បើ $\begin{cases}4m+7\neq 0\\ m+10\neq 0\end{cases}\Leftrightarrow\begin{cases}m\neq -\frac{7}{4}\\ m\neq -10\end{cases}$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យគឺ $x=\frac{m+10}{4m+7}$ ។
- បើ $\begin{cases}4m+7=0\\ m+10=0\end{cases}\Leftrightarrow\begin{cases}m=-\frac{7}{4}\\ m=-10\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់
- បើ $4m+7=0\Rightarrow m=-\frac{7}{4}$ ឱ្យសមីការមានរាង $0x=\frac{33}{4}$ នោះសមីការគ្មានឫស ។
- បើ $m+10=0\Rightarrow m=-10$ ឱ្យសមីការមានរាង $-33x=0$ នោះសមីការមានឫសមួយគឺ $x=0$ ។

សន្និដ្ឋាន:

| |
|---|
| • សមីការមានឫសមួយខុសពីសូន្យ កាលណា $m\neq -\frac{7}{4}$ និង $m\neq -10$ |
| • សមីការមានឫសមួយស្មើសូន្យ កាលណា $m=-10$ |
| • សមីការគ្មានឫស កាលណា $m=-\frac{7}{4}$ |
| • សមីការមានឫសច្រើនរាប់មិនអស់ កាលណា $m=-\frac{7}{4}$ និង $m=-10$ ។ |

5. $\frac{m}{3}(3x+2)=1-\frac{m}{2}x$

$2m(3x+2)=6-3mx$

$6mx+4m=6-3mx$

$9mx = 6-4m$

- បើ $\begin{cases} m\neq 0 \\ 6-4m\neq 0\end{cases} \Leftrightarrow \begin{cases} m\neq 0 \\ m\neq \frac{3}{2}\end{cases}$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យគឺ $x=\frac{6-4m}{9m}$ ។
- បើ $\begin{cases} m=0 \\ 6-4m=0\end{cases} \Leftrightarrow \begin{cases} m=0 \\ m=\frac{3}{2}\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $m=0$ ឱ្យសមីការមានរាង $0x=6$ នោះសមីការគ្មានឫស ។
- បើ $6-4m=0 \Rightarrow m=\frac{3}{2}$ ឱ្យសមីការមានរាង $\frac{27}{2}x=0$ នោះសមីការមានឫសមួយគឺ $x=0$ ។

សន្និដ្ឋាន:

- សមីការមានឫសមួយខុសពីសូន្យ កាលណា $m\neq 0$ និង $m\neq\frac{3}{2}$
- សមីការមានឫសមួយស្មើសូន្យ កាលណា $m=\frac{3}{2}$
- សមីការគ្មានឫស កាលណា $m=0$
- សមីការមានឫសច្រើនរាប់មិនអស់ កាលណា $m=0$ និង $m=\frac{3}{2}$ ។

6. $3mx+5m-1=4m(x-2)+x+m$

$3mx-4mx-x=-8m+m-5m+1$

$-mx-x=-12m+1$

$(m+1)x=12m-1$

- បើ $\begin{cases} m+1\neq 0 \\ 12m-1\neq 0\end{cases} \Leftrightarrow \begin{cases} m\neq -1 \\ m\neq \frac{1}{12}\end{cases}$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យគឺ $x=\frac{12m-1}{m+1}$ ។
- បើ $\begin{cases} m+1=0 \\ 12m-1=0\end{cases} \Leftrightarrow \begin{cases} m=-1 \\ m=\frac{1}{12}\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់
- បើ $m+1=0 \Rightarrow m=-1$ ឱ្យសមីការមានរាង $0x=-13$ នោះសមីការគ្មានឫស ។
- បើ $12m-1=0 \Rightarrow m=\frac{1}{12}$ ឱ្យសមីការមានរាង $\frac{13}{12}x=0$ នោះសមីការមានឫសមួយគឺ $x=0$ ។

សន្និដ្ឋាន:

- សមីការមានឫសមួយខុសពីសូន្យ កាលណា $m\neq -1$ និង $m\neq\frac{1}{12}$
- សមីការមានឫសមួយស្មើសូន្យ កាលណា $m=\frac{1}{12}$
- សមីការគ្មានឫស កាលណា $m=-1$
- សមីការមានឫសច្រើនរាប់មិនអស់ កាលណា $m=-1$ និង $m=\frac{1}{12}$ ។

7. $4mx(5x-1)=5(4mx+3)x+m-1$

$20mx^2-4mx=20mx^2+15x+m-1$

$-4mx-15x=m-1$

$(4m+15)x=1-m$

○ បើ $\begin{cases}4m+15\neq 0\\1-m\neq 0\end{cases}\Leftrightarrow\begin{cases}m\neq\frac{-15}{4}\\m\neq 1\end{cases}$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យគឺ $x=\frac{1-m}{14m+15}$ ។

○ បើ $\begin{cases}4m+15=0\\m-1=0\end{cases}\Leftrightarrow\begin{cases}m=\frac{-15}{4}\\m=-1\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់

○ បើ $4m+15=0\Rightarrow m=-\frac{15}{4}$ ឱ្យសមីការមានរាង $0x=\frac{19}{4}$ នោះសមីការគ្មានឫស ។

○ បើ $1-m=0\Rightarrow m=1$ ឱ្យសមីការមានរាង $19x=0$ នោះសមីការមានឫសមួយគឺ $x=0$ ។

សន្និដ្ឋានៈ

- សមីការមានឫសមួយខុសពីសូន្យ កាលណា $m\neq-\frac{15}{4}$ និង $m\neq 1$
- សមីការមានឫសមួយស្មើសូន្យ កាលណា $m=1$
- សមីការគ្មានឫស កាលណា $m=-\frac{15}{4}$
- សមីការមានឫសច្រើនរាប់មិនអស់ កាលណា $m=-\frac{15}{4}$ និង $m=1$ ។

8. $7mx-4m+9=2(x-2m)+5$

$7mx-4m+9=2x-4m+5$
$7mx-2x=-4$
$(7m-2)x=-4$

○ បើ $7m-2\neq 0\Rightarrow m\neq\frac{2}{7}$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យគឺ $x=-\frac{4}{7m-2}$ ។

○ បើ $7m-2=0\Rightarrow m=\frac{2}{7}$ នាំឱ្យសមីការមានរាង $0x=-4$ នោះសមីការគ្មានឫស ។

សន្និដ្ឋានៈ

- សមីការមានឫសមួយខុសពីសូន្យ គឺ $x=-\frac{4}{7m-2}$ កាលណា $m\neq\frac{2}{7}$
- សមីការគ្មានឫស កាលណា $m=\frac{2}{7}$ ។

9. $2(x-m)+4=4x-(m-x)+1$

$2x-2m+4=4x-m+x+1$
$2x-5x=2m-4-m+1$
$-3x=m-3$
$3x=3-m$

○ បើ $3-m\neq 0\Rightarrow m\neq 3$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យគឺ $x=\frac{3-m}{3}$ ។

○ បើ $3-m=0\Rightarrow m=3$ នាំឱ្យសមីការមានរាង $3x=0$ នោះសមីការមានឫសមួយ គឺ $x=0$

សន្និដ្ឋានៈ

- សមីការមានឫសមួយខុសពីសូន្យ គឺ $x=\frac{3-m}{3}$ កាលណា $m\neq 3$
- សមីការមានឫសមួយ គឺ $x=0$ កាលណា $m=3$ ។

10. $\frac{5m}{10}x+\frac{3m-x}{5}=\frac{2x-1}{2}+m$

$\frac{5mx+6m-2x}{10}=\frac{10x-5+10m}{10}$

$(5m-2)x+6m=10x-5+10m$

$(5m-12)x=4m-5$

○ បើ $\begin{cases}5m-12\neq 0\\4m-5\neq 0\end{cases}\Leftrightarrow\begin{cases}m\neq\frac{12}{5}\\m\neq\frac{5}{4}\end{cases}$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យគឺ $x=\frac{5m-12}{4m-5}$ ។

○ បើ $\begin{cases}5m-12=0\\4m-5=0\end{cases}\Leftrightarrow\begin{cases}m=\frac{12}{5}\\m=\frac{5}{4}\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់

○ បើ $5m-12=0\Rightarrow m=\frac{12}{5}$ ឱ្យសមីការមានរាង $0x=\frac{23}{5}$ នោះសមីការគ្មានឫស ។

○ បើ $4m-5=0\Rightarrow m=\frac{5}{4}$ ឱ្យសមីការមានរាង $-\frac{23}{4}x=0$ នោះសមីការមានឫសមួយគឺ $x=0$ ។

សន្និដ្ឋាន:

- សមីការមានឫសមួយខុសពីសូន្យ កាលណា $m\neq\frac{12}{5}$ និង $m\neq\frac{5}{4}$
- សមីការមានឫសមួយស្មើសូន្យ កាលណា $m=\frac{5}{4}$
- សមីការគ្មានឫស កាលណា $m=\frac{12}{5}$
- សមីការមានឫសច្រើនរាប់មិនអស់ កាលណា $m=\frac{12}{5}$ និង $m=\frac{5}{4}$ ។

11. $\frac{2x-m}{6}+\frac{m}{3}=\frac{x-2m}{2}+mx$

$\frac{2x-m+2m}{6}=\frac{3x-6m+6mx}{6}$

$2x+m=(3+6m)x-6m$

$2x-(3+6m)x=-7m$

$(-3-6m+2)x=-7m$

$(-6m-1)x=-7m$

$(6m+1)x=7m$

○ បើ $\begin{cases}6m+1\neq 0\\m\neq 0\end{cases}\Leftrightarrow\begin{cases}m\neq-\frac{1}{6}\\m\neq 0\end{cases}$ នាំឱ្យសមីការមានឫសមួយខុសពីសូន្យគឺ $x=\frac{7m}{6m+1}$ ។

○ បើ $\begin{cases}6m+1=0\\m=0\end{cases}\Leftrightarrow\begin{cases}m=-\frac{1}{6}\\m=0\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់

- បើ $6m+1=0 \Rightarrow m=-\frac{1}{6}$ ឱ្យសមីការមានរាង $0x=-\frac{7}{6}$ នោះសមីការគ្មានឫស ។
- បើ $7m=0 \Rightarrow m=0$ ឱ្យសមីការមានរាង $x=0$ នោះសមីការមានឫសមួយគឺ $x=0$ ។

សន្និដ្ឋាន:

- សមីការមានឫសមួយខុសពីសូន្យ កាលណា $m\neq-\frac{1}{6}$ និង $m\neq 0$
- សមីការមានឫសមួយស្មើសូន្យ កាលណា $m=0$
- សមីការគ្មានឫស កាលណា $m=-\frac{1}{6}$
- សមីការមានឫសច្រើនរាប់មិនអស់ កាលណា $m=-\frac{1}{6}$ និង $m=0$ ។

12. $2mx+\frac{m-5}{7}=\frac{x-m}{2}+3$

$$\frac{28mx+2m-10}{14}=\frac{7x-7m+42}{14}$$
$$28mx+2m-10=7x-7m+42$$
$$28mx-7x=-7m+42-2m+10$$
$$(28m-7)x=-9m+52$$

- បើ $\begin{cases}28m-7\neq 0\\ -9m+52\neq 0\end{cases} \Leftrightarrow \begin{cases}m\neq\frac{1}{4}\\ m\neq\frac{52}{9}\end{cases}$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\frac{-9m+52}{28m-7}$ ។
- បើ $\begin{cases}28m-7=0\\ -9m+52=0\end{cases} \Leftrightarrow \begin{cases}m=\frac{1}{4}\\ m=\frac{52}{9}\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $28m-7=0 \Rightarrow m=\frac{1}{4}$ នាំឱ្យសមីការមានរាង $0x=\frac{199}{4}$ នោះសមីការគ្មានឫស ។
- បើ $-9m+52=0 \Rightarrow m=\frac{52}{9}$ នាំឱ្យសមីការមានរាង $\frac{1456}{9}x=0$ នោះសមីកាមានឫសមួយគឺ: $x=0$ ។

សន្និដ្ឋាន

- បើ $m\neq\frac{1}{4}$ និង $m\neq\frac{52}{9}$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\frac{-9m+52}{28m-7}$ ។
- បើ $m=\frac{1}{4}$ និង $m=\frac{52}{9}$ នាំឱ្យសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $m=\frac{1}{4}$ នាំឱ្យសមីការគ្មានឫស ។
- បើ $m=\frac{52}{9}$ នាំឱ្យសមីកាមានឫសមួយគឺ: $x=0$ ។

*បញ្ជាក់:* ក្នុងការសន្និដ្ឋាន យើងអាចសរសេរតាមលំហាត់ទី១០ ក៏បាន ឬតាមលំហាត់ទី១១ ក៏បាន ឬផ្សេងទៀតក៏បាន អាស្រ័យយើងឆ្លើយ ឱ្យតែអស់អ្វីដែលយើងបានបង្ហាញខាងលើ ។

13. $(2m-x)^2+4(1-m)m=x(x+5m)+m-1$

$4m^2-4mx+x^2+4m-4m^2=x^2+5mx+m-1$
$-4mx-5mx=m-1-4m$
$9mx=3m+1$

- បើ $\begin{cases}9m\neq 0\\3m+1\neq 0\end{cases}\Leftrightarrow\begin{cases}m\neq 0\\m\neq -\frac{1}{3}\end{cases}$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\frac{3m+1}{9m}$ ។
- បើ $\begin{cases}9m=0\\3m+1=0\end{cases}\Leftrightarrow\begin{cases}m=0\\m=-\frac{1}{3}\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $9m=0\Rightarrow m=0$ នាំឱ្យសមីការមានរាង $0x=1$ នោះសមីការគ្មានឫស ។
- បើ $3m+1=0\Rightarrow m=-\frac{1}{3}$ នាំឱ្យសមីការមានរាង $-3x=0$ នោះសមីកាមានឫសមួយគឺ: $x=0$ ។

សន្និដ្ឋាន

- បើ $m\neq 0$ និង $m\neq -\frac{1}{3}$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\frac{3m+1}{9m}$ ។
- បើ $m=0$ និង $m=-\frac{1}{3}$ នាំឱ្យសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $m=0$ នាំឱ្យសមីការគ្មានឫស ។
- បើ $m=-\frac{1}{3}$ នាំឱ្យសមីកាមានឫសមួយគឺ: $x=0$ ។

14. $(3m+2x)^2-(9m-1)(m-x)=(2x-1)^2-m(x-4)$

$9m^2+12mx+4x^2-9m^2+9mx+m-x=4x^2-4x+1-mx+4m$

$21mx-x+4x+mx=4m+1-m$
$(22m+3)x=3m+1$

- បើ $\begin{cases}22m+3\neq 0\\3m+1\neq 0\end{cases}\Leftrightarrow\begin{cases}m\neq -\frac{3}{22}\\m\neq -\frac{1}{3}\end{cases}$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\frac{3m+1}{22m+3}$ ។
- បើ $\begin{cases}22m+3=0\\3m+1=0\end{cases}\Leftrightarrow\begin{cases}m=-\frac{3}{22}\\m=-\frac{1}{3}\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $22m+3=0\Rightarrow m=-\frac{3}{22}$ នាំឱ្យសមីការមានរាង $0x=\frac{13}{22}$ នោះសមីការគ្មានឫស ។
- បើ $3m+1=0\Rightarrow m=-\frac{1}{3}$ នាំឱ្យសមីការមានរាង $-\frac{13}{3}x=0$ នោះសមីកាមានឫសមួយគឺ: $x=0$ ។

សន្និដ្ឋាន

- បើ $m\neq -\frac{3}{22}$ និង $m\neq -\frac{1}{3}$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\frac{3m+1}{22m+3}$ ។
- បើ $m=-\frac{3}{22}$ និង $m=-\frac{1}{3}$ នាំឱ្យសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $m=-\frac{3}{22}$ នាំឱ្យសមីការគ្មានឫស ។
- បើ $m=-\frac{1}{3}$ នាំឱ្យសមីកាមានឫសមួយគឺ: $x=0$ ។

15. $(m-3x)^2+(m-7x)x-2x(x-1)=(m-x)(m+2)$

$m^2-6mx+9x^2+mx-7x^2-2x^2+2x=m^2+2m-mx-2x$

$-5mx+2x+mx+2x=2m$

$4(1-m)x=2m$

$2(1-m)x=m$

- បើ $\begin{cases}1-m\neq 0\\ m\neq 0\end{cases}\Leftrightarrow\begin{cases}m\neq 1\\ m\neq 0\end{cases}$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\frac{m}{2(m-1)}$ ។
- បើ $\begin{cases}1-m=0\\ m=0\end{cases}\Leftrightarrow\begin{cases}m=1\\ m=0\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $1-m=0\Rightarrow m=1$ នាំឱ្យសមីការមានរាង $0x=1$ នោះសមីការគ្មានឫស ។
- បើ $m=0$ នាំឱ្យសមីការមានរាង $2x=0$ នោះសមីកាមានឫសមួយគឺ: $x=0$ ។

សន្និដ្ឋាន

- បើ $m\neq 1$ និង $m\neq 0$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\frac{m}{1-m}$ ។
- បើ $m=1$ និង $m=0$ នាំឱ្យសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $m=1$ នាំឱ្យសមីការគ្មានឫស ។
- បើ $m=0$ នាំឱ្យសមីកាមានឫសមួយគឺ: $x=0$ ។

16. $(m-3)^2+(x+m)^2-2m(m-1)=x^2+7mx-3$

$m^2-6m+9+x^2+2mx+m^2-2m^2+2m=x^2+7mx-3$

$2mx-7mx=-3-9+4m$

$-5mx=-12+4m$

$5mx=12-4m$

- បើ $\begin{cases}m\neq 0\\ 12-4m\neq 0\end{cases}\Leftrightarrow\begin{cases}m\neq 0\\ m\neq 3\end{cases}$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\frac{12-4m}{5m}$ ។
- បើ $\begin{cases}m=0\\ 12-4m=0\end{cases}\Leftrightarrow\begin{cases}m=0\\ m=3\end{cases}$ នាំឱ្យសមីការមានរាង $0x=0$ មានឫសច្រើនរាប់មិនអស់ ។
- បើ $m=0$ នាំឱ្យសមីការមានរាង $0x=12$ គ្មានឫស ។
- បើ $12-4m=0\Rightarrow m=3$ នាំឱ្យសមីកាមានរាង $15x=0$ មានឫសមួយគឺ: $x=0$ ។

សន្និដ្ឋាន

- បើ $m\neq 0$ និង $m\neq 3$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\dfrac{12-4m}{5m}$ ។
- បើ $m=0$ និង $m=3$ នាំឱ្យសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $m=0$ នាំឱ្យសមីការគ្មានឫស ។
- បើ $m=3$ នាំឱ្យសមីកាមានឫសមួយគឺ: $x=0$ ។

17. $\dfrac{m^2(x+2)^2}{8}-2(2x+m+1)=(m+1)^2+\dfrac{m^2(x-2)^2}{8}+1$

$$\frac{m^2(x^2+4x+4)-16(2x+m+1)}{8}=\frac{8(m^2+2m+1)+m^2(x^2-4x+4)+8}{8}$$

$m^2x^2+4m^2x+4m^2-32x-16m-16=8m^2+16m+8+m^2x^2-4m^2x+4m^2+8$

$8m^2x-32x=8m^2+32m+32$

$m^2x-4x=m^2+4m+4$

$(m+2)(m-2)x=(m+2)^2$

- បើ $\begin{cases}m-2\neq 0\\ m+2\neq 0\end{cases}\Leftrightarrow\begin{cases}m\neq 2\\ m\neq -2\end{cases}$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\dfrac{m+2}{m-2}$ ។
- បើ $m-2=0\Rightarrow m=2$ នាំឱ្យសមីការមានរាង $0x=16$ សមីការគ្មានឫស ។
- បើ $m+2=0\Rightarrow m=-2$ នាំឱ្យសមីកាមានរាង $0x=0$ នោះសមីការមានឫសច្រើនរាប់មិនអស់ ។

សន្និដ្ឋាន

- បើ $m\neq 2$ និង $m\neq -2$ នាំឱ្យសមីការមានឫសមួយ គឺ: $x=\dfrac{m+2}{m-2}$ ។
- បើ $m=-2$ នាំឱ្យសមីការមានឫសច្រើនរាប់មិនអស់ ។
- បើ $m=2$ នាំឱ្យសមីការគ្មានឫស ។

IV. *ដោះស្រាយសមីការដោយមិនប្រើរូបមន្តឌីគ្រីសមីណង់*

1. $x^2+14x+24=0$

| $x^2$ | $24$ | $14x$ |
|---|---|---|
| $x$ | $12$ → | $12x$ |
| $x$ | $2$ → | $2x$ |
| | | $14x$ ពិត |

គេបាន: $x^2+14x+24=0$

$(x+12)(x+2)=0$

នាំឱ្យ $x+12=0\Rightarrow x=-12$

ឬ $x+2=0\Rightarrow x=-2$

ដូចនេះ $x=-12$ , $x=-2$ ជាឫសនៃសមីការ ។

2. $x(x-2)=24$

$x^2-2x=24$

$x^2-2x+1=25$

$(x-1)^2=25$

$x-1=\pm\sqrt{25}$

$x=1\pm5$ នោះ $x=6$ ឬ $x=-4$

ដូចនេះ: $x=6$ ឬ $x=-4$ ជាឫសនៃសមីការ ។

3. $x^2-2x-8=0$

| $x^2$ | $-8$ | $-2$ |
|---|---|---|
| $x$ | $-4$ → | $-4x$ |
| $x$ | $2$ → | $2x$ |
| | | $-2x$ ពិត |

គេបាន: $x^2-2x-8=0$

$(x-4)(x+2)=0$

នាំឱ្យ $x-4=0\Rightarrow x=4$

ឬ $x+2=0\Rightarrow x=-2$

ដូចនេះ: $x=4\,,\ x=-2$ ជាឫសនៃសមីការ ។

4. $4x^2-16=0$

$4x^2=16$

$x=\pm\sqrt{4}=\pm2$

ដូចនេះ: $x=-2$ ឬ $x=2$ ជាឫសនៃសមីការ ។

5. $9x^2-21=-5$

$9x^2=-5+21$

$x^2=\dfrac{16}{9}$

$x=\pm\sqrt{\dfrac{16}{9}}\vee x=\pm\dfrac{4}{3}$

ដូចនេះ: $x=\dfrac{4}{3}\,,\ x=-\dfrac{4}{3}$ ជាឫសនៃសមីការ ។

6. $x^2-4x+4=0$

$(x-2)^2=0$

$x-2=0$

$x=2$

ដូចនេះ: $x=2$ ជាឫសឌុបនៃសមីការ ។

7. $x^2+2\sqrt{3}x-1=0$

$x^2+2\sqrt{3}x+\sqrt{3}^2-3-1=0$

$\left(x+\sqrt{3}\right)^2=4$

$x+\sqrt{3}=\pm 2$

$x=\pm 2-\sqrt{3}$

ដូចនេះ $x=-2-\sqrt{3}$ ឬ $x=2-\sqrt{3}$ ជាឫសនៃសមីការ ។

8. $2x^2+20x-22=0$

$x^2+10x-11=0$

| $x^2$ | $-11$ | $10x$ |
|---|---|---|
| $x$ | $11$ | $\to 11x$ |
| $x$ | $-1$ | $\to -x$ |
| | | $10x$ ពិត |

គេបាន: $x^2+10x-11=0$

$(x+11)(x-1)=0$

នាំឱ្យ $x+11=0 \Rightarrow x=-11$

ឬ $x-1=0 \Rightarrow x=1$

ដូចនេះ $x=-11$ , $x=1$ ជាឫសនៃសមីការ ។

9. $(2x-1)^2-25=0$

$(2x-1)^2=25$

$2x-1=\pm 5$

$2x=\pm 5+1$

$x=\dfrac{\pm 5+1}{2} \Leftrightarrow x=\dfrac{-5+1}{2}=-2 \vee x=\dfrac{5+1}{2}=3$

ដូចនេះ $x=3$ ឬ $x=-2$ ជាឫសនៃសមីការ ។

10. $2x^2-5x+3=0$

| $2x^2$ | $3$ | $-5x$ |
|---|---|---|
| $2x$ | $-3$ | $\to -3x$ |
| $x$ | $-1$ | $\to -2x$ |
| | | $-5x$ ពិត |

គេបាន: $2x^2-5x+3=0$

$(x-3)(2x-1)=0$

នាំឱ្យ $2x-3=0 \Rightarrow x=\dfrac{3}{2}$

ឬ $x-1=0 \Rightarrow x=1$

ដូចនេះ $x=1,\ x=\dfrac{3}{2}$ ជាឫសនៃសមីការ ។

11. $3x^2+7x+4=0$

| $3x^2$ | $4$ | $7x$ |
|---|---|---|
| $3x$ | $4$ | $\rightarrow 4x$ |
| $x$ | $1$ | $\rightarrow 3x$ |
| | | $7x$ ពិត |

គេបាន: $3x^2+7x+4=0$

$$(3x+4)(x+1)=0$$

នាំឱ្យ $3x+4=0\Rightarrow x=-\frac{4}{3}$

ឬ $x+1=0\Rightarrow x=-1$

ម៉្យាងទៀត: $3x^2+7x+4=0$

មាន: $\begin{pmatrix}3-7+4=0\\ a-b+c=0\end{pmatrix}\Rightarrow x_1=-1\vee x_2=-\frac{c}{a}=-\frac{4}{3}$

ដូចនេះ $x=-\frac{4}{3}$ , $x=-1$ ជាឫសនៃសមីការ ។

12. $6x^2+5x-11=0$

មាន: $\begin{pmatrix}6+5-11=0\\ a+b+c=0\end{pmatrix}$

នាំឱ្យ: $x_1=1$ , $x_2=\frac{c}{a}=-\frac{11}{6}$

ដូចនេះ $x=1$ $x=-\frac{11}{6}$ ជាឫសនៃសមីការ ។

13. $x^2-14=5x$

$x^2-5x-14=0$

| $x^2$ | $-14$ | $-5x$ |
|---|---|---|
| $x$ | $-7$ | $\rightarrow -7x$ |
| $x$ | $2$ | $\rightarrow 2x$ |
| | | $-5x$ ពិត |

គេបាន: $x^2-5x-14=0$

$$(x-7)(x+2)=0$$

នាំឱ្យ $x-7=0\Rightarrow x=7$

ឬ $x+2=0\Rightarrow x=-2$

ដូចនេះ $x=7,\ x=-2$ ជាឫសនៃសមីការ ។

14. $x^2 - x = 3x + 12$

$x^2 - 4x - 12 = 0$

| $x^2$ | $-12$ | $-4x$ |
|---|---|---|
| $x$ | $-6 \to$ | $-6x$ |
| $x$ | $2 \to$ | $2x$ |
| | | $-4x$ ពិត |

គេបាន: $x^2 - 4x - 12 = 0$

$(x-6)(x+2) = 0$

នាំឱ្យ $x - 6 = 0 \Rightarrow x = 6$

ឬ $x + 2 = 0 \Rightarrow x = -2$

ដូចនេះ $\boxed{x = 6,\ x = -2 \text{ ជាឫសនៃសមីការ}}$ ។

15. $x^2 - 12x + 32 = 0$

| $x^2$ | $32$ | $-12x$ |
|---|---|---|
| $x$ | $-8 \to$ | $-8x$ |
| $x$ | $-4 \to$ | $-4x$ |
| | | $-12x$ ពិត |

គេបាន: $x^2 - 12x + 32 = 0$

$(x-8)(x-4) = 0$

នាំឱ្យ $x - 8 = 0 \Rightarrow x = 8$

ឬ $x - 4 = 0 \Rightarrow x = 4$

ដូចនេះ $\boxed{x = 8\ ,\ x = 4 \text{ ជាឫសនៃសមីការ}}$ ។

16. $x^2 - 2x + 3 = 0$

$x^2 - 2x + 1 + 2 = 0$

$(x-1)^2 = -2 < 0$ សមីការគ្មានឫស

ព្រោះ $(x-1)^2 > 0$ ជានិច្ច

ដូចនេះ $\boxed{\text{សមីការគ្មានឫស}}$ ។

17. $4(x-1)^2 - (2x-3)^2 = 0$

$4(x^2 - 2x + 1) - (4x^2 - 12x + 9) = 0$

$4x^2 - 8x + 4 - 4x^2 + 12x - 9 = 0$

$4x - 5 = 0$ នោះ $4x = 5$ ឬ $x = \frac{5}{4}$

ដូចនេះ $\boxed{x = \frac{5}{4} \text{ ជាឫសសមីការ}}$ ។

18. $x^2+2x=2(x+4)$

$x^2+2x=2x+8$

$x^2=8 \Rightarrow x=\pm\sqrt{8}=\pm 2\sqrt{2}$

ដូចនេះ $\boxed{x=\pm 2\sqrt{2} \text{ ជាឫសសមីការ}}$ ។

19. $3x^2+9x=0$

$3x(x+3)=0$

$\left[\begin{array}{l}3x=0\\x+3=0\end{array}\right. \Leftrightarrow \left[\begin{array}{l}x=0\\x=-3\end{array}\right.$

ដូចនេះ $\boxed{x=0 \text{ ឬ } x=-3 \text{ ជាឫសនៃសមីការ}}$ ។

20. $2x^2+3x-5=0$

មាន: $\begin{pmatrix}2+3-5=0\\a+b+c=0\end{pmatrix}$

នាំឱ្យ: $\left[\begin{array}{l}x_1=1\\x=\frac{c}{a}=-\frac{5}{2}\end{array}\right.$

ដូចនេះ $\boxed{x=1 \text{ ឬ } x=-\frac{5}{2} \text{ ជាឫសនៃសមីការ}}$ ។

V. *ដោះស្រាយសមីការខាងក្រោម ៖*

1. $x^2-9x-22=0$

មាន: $\Delta=(-9)^2-4\times 1\times(-22)$

$=81+88=169>0 \Rightarrow \sqrt{\Delta}=\sqrt{169}=13$

នោះ $x_1=\frac{9-13}{2}=-2$ , $x_2=\frac{9+13}{2}=11$

ដូចនេះ $\boxed{x=-2 \text{ ឬ } x=11 \text{ ជាឫសនៃសមីការ}}$ ។

2. $2x^2+7x-1=0$

មាន: $\Delta=7^2-4\times 2\times(-1)$

$=49+8=57>0 \Rightarrow \sqrt{\Delta}=\sqrt{57}$

នោះ $x_1=\frac{-7-\sqrt{57}}{4}$ , $x_2=\frac{-7+\sqrt{57}}{4}$

ដូចនេះ $\boxed{x=\frac{-7-\sqrt{57}}{4} \text{ ឬ } x=\frac{-7+\sqrt{57}}{4} \text{ ជាឫសនៃសមីការ}}$ ។

3. $3x^2+7x+4=0$

មាន: $a-b+c=0$

នាំឱ្យ $x_1 = -1$ , $x_2 = \frac{c}{a} = \frac{4}{3}$

ដូចនេះ $\boxed{x = 1 \text{ ឬ } x = \frac{4}{3} \text{ ជាឫសនៃសមីការ}}$ ។

4. $3x^2 + 5x - 11 = 0$

មាន: $\Delta = 5^2 - 4\times 3\times(-11)$

$= 25 + 132 = 157 > 0 \Rightarrow \sqrt{\Delta} = \sqrt{157}$

នោះ $x_1 = \frac{-5-\sqrt{157}}{6}$ , $x_2 = \frac{-5+\sqrt{157}}{6}$

ដូចនេះ $\boxed{x = \frac{-5-\sqrt{157}}{6} \text{ ឬ } x = \frac{-5+\sqrt{157}}{6} \text{ ជាឫសនៃសមីការ}}$ ។

5. $4x^2 - 4x - 24 = 0$

$x^2 - x - 6 = 0$

មាន: $\Delta = (-1)^2 - 4\times(-6)$

$= 1 + 24 = 25 > 0 \Rightarrow \sqrt{\Delta} = \sqrt{25} = 5$ នោះ $x_1 = \frac{1-5}{2} = -2$ , $x_2 = \frac{1+5}{2} = 3$

ដូចនេះ $\boxed{x = -2 \text{ ឬ } x = 3 \text{ ជាឫសនៃសមីការ}}$ ។

6. $4x^2 - 37x + 9 = 0$

មាន: $\Delta = (-37)^2 - 4\times 4\times 9$

$= 1369 - 144 = 1225 > 0 \Rightarrow \sqrt{\Delta} = \sqrt{1225} = 35$

នោះ $x_1 = \frac{37-35}{8} = \frac{1}{4}$ , $x_2 = \frac{37+35}{8} = 9$

ដូចនេះ $\boxed{x = \frac{1}{4} \text{ ឬ } x = 9 \text{ ជាឫសនៃសមីការ}}$ ។

7. $13x - 36 = x^2$

$x^2 - 13x + 36 = 0$

មាន: $\Delta = (-13)^2 - 4\times 36$

$= 169 - 144 = 25 > 0 \Rightarrow \sqrt{\Delta} = \sqrt{25} = 5$

នោះ $x_1 = \frac{13-5}{2} = 4$ , $x_2 = \frac{13+5}{2} = 9$

ដូចនេះ $\boxed{x = 4 \text{ ឬ } x = 9 \text{ ជាឫសនៃសមីការ}}$ ។

8. $81x^2 + 1 = 18x$

$81x^2 - 18x + 1 = 0$

មាន: $\Delta' = (-9)^2 - 81\times 1 = 0$

នោះ $x_1 = x_2 = -\frac{b'}{a} = \frac{9}{81} = \frac{1}{9}$

ដូចនេះ $\boxed{x = \frac{1}{9} \text{ ជាឫសឌុបនៃសមីការ}}$ ។

9. $x^2 + 5x - 14 = 0$

មាន: $\Delta = 5^2 - 4\times(-14)$

$= 25 + 56 = 81 > 0 \Rightarrow \sqrt{\Delta} = \sqrt{81} = 9$

នោះ $x_1 = \frac{-5-9}{2} = -7$ , $x_2 = \frac{-5+9}{2} = 2$

ដូចនេះ $\boxed{x = 2 \text{ ឬ } x = -7 \text{ ជាឫសនៃសមីការ}}$ ។

10. $2x^2 - x - 1 = 0$

មាន: $a + b + c = 0$

នោះ $x_1 = 1$ , $x_2 = \frac{c}{a} = -\frac{1}{2}$

ដូចនេះ $\boxed{x = 1 \text{ ឬ } x = -\frac{1}{2} \text{ ជាឫសនៃសមីការ}}$ ។

11. $x^2 - 6x + 5 = 0$

មាន: $a + b + c = 0$

នោះ $x_1 = 1$ , $x_2 = \frac{c}{a} = 5$

ដូចនេះ $\boxed{x = 1 \text{ ឬ } x = 5 \text{ ជាឫសនៃសមីការ}}$ ។

12. $3x^2 + 8x - 4 = 0$

មាន: $\Delta' = 4^2 - 3\times(-4)$

$= 16 + 12 = 28 > 0 \Rightarrow \sqrt{\Delta'} = \sqrt{28} = 2\sqrt{7}$

នោះ $x_1 = \frac{-4-2\sqrt{7}}{3}$, $x_2 = \frac{-4+2\sqrt{7}}{3}$

ដូចនេះ $\boxed{x = \frac{-4-2\sqrt{7}}{3} \text{ ឬ } x = \frac{-4+2\sqrt{7}}{3} \text{ ជាឫសនៃសមីការ}}$ ។

13. $x^2 + x - 9 = 0$

មាន: $\Delta = 1^2 - 4\times(-9)$

$= 1 + 36 = 37 > 0 \Rightarrow \sqrt{\Delta} = \sqrt{37}$

នោះ $x_1 = \frac{-1-\sqrt{37}}{2}$, $x_2 = \frac{-1+\sqrt{37}}{2}$

ដូចនេះ $\boxed{x = \frac{-1-\sqrt{37}}{2} \text{ ឬ } x = \frac{-1+\sqrt{37}}{2} \text{ ជាឫសនៃសមីការ}}$ ។

14. $2x^2+3x-9=0$

មាន: $\Delta=3^2-4\times2\times(-9)$

$=9+72=81>0\Rightarrow\sqrt{\Delta}=\sqrt{81}=9$

នោះ $x_1=\dfrac{-3-9}{4}=-3,\ x_2=\dfrac{-3+9}{4}=\dfrac{3}{2}$

ដូចនេះ: $x=-3$ ឬ $x=\dfrac{3}{2}$ ជាឫសនៃសមីការ ។

15. $x^2+3x+5=0$

មាន: $\Delta=3^2-4\times5$

$=9-20=-11<0$

ដូចនេះ: សមីការគ្មានឫស ។

16. $6x^2=7x-5$

$6x^2-7x+5=0$

មាន: $\Delta=(-7)^2-4\times6\times(-5)$

$=49+120=169>0\Rightarrow\sqrt{\Delta}=\sqrt{169}=13$

នោះ $x_1=\dfrac{7-13}{12}=-\dfrac{1}{2}$ , $x_2=\dfrac{7+13}{12}=\dfrac{5}{3}$

ដូចនេះ: $x=-\dfrac{1}{2}$ ឬ $x=\dfrac{5}{3}$ សមីការគ្មានឫស ។

17. $x^2+2x-4=0$

មាន: $\Delta'=1^2-1\times(-4)$

$=1+4=5>0\Rightarrow\sqrt{\Delta'}=\sqrt{5}$

នោះ $x_1=\dfrac{-1-\sqrt{5}}{1}=-1-\sqrt{5}$ , $x_2=\dfrac{-1+\sqrt{5}}{1}=-1+\sqrt{5}$

ដូចនេះ: $x=-1-\sqrt{5}$ ឬ $x=-1+\sqrt{5}$ ជាឫសនៃសមីការ ។

18. $x^2+7=4x$

$x^2-4x+7=0$

មាន: $\Delta'=2^2-1\times7$

$=4-7=-3<0$

ដូចនេះ: សមីការគ្មានឫស ។

19. $2x^2+5x+1=0$

មាន: $\Delta=5^2-4\times2$

$=25-8=17>0\Rightarrow\sqrt{\Delta}=\sqrt{17}$

នោះ $x_1=\dfrac{-5-\sqrt{17}}{4}$ , $x_2=\dfrac{-5+\sqrt{17}}{4}$

ដូចនេះ: $x=\dfrac{-5-\sqrt{17}}{4}$ ឬ $x=\dfrac{-5+\sqrt{17}}{4}$ ជាឫសនៃសមីការ ។

20. $(x+1)(2-x)=7x(x+4)$

$2x-x^2+2-x=7x^2+28x$

$8x^2+27x-2=0$

មាន: $\Delta=27^2-4\times8\times(-2)$

$=729+64=793>0\Rightarrow\Delta=\sqrt{793}$

នោះ $x_1=\dfrac{-27-\sqrt{793}}{16}$ , $x_2=\dfrac{-27+\sqrt{793}}{16}$

ដូចនេះ: $x=\dfrac{-27-\sqrt{793}}{16}$ ឬ $x=\dfrac{-27+\sqrt{793}}{16}$ ជាឫសនៃសមីការ ។

VI. *ដោយ $\alpha$ , $\beta$ ជាឫសនៃសមីការ* $x^2+x+1=0$

តាមទ្រឹស្តីបទវ្យែត: $\begin{cases}\alpha+\beta=-\dfrac{b}{a}=-1\\ \alpha\beta=\dfrac{c}{a}=1\end{cases}$

គណនា:

1. $\alpha^2+\beta^2=(\alpha+\beta)^2-2\alpha\beta=(-1)^2-2\times1=-1$
2. $(\alpha-\beta)^2=\alpha^2+\beta^2-2\alpha\beta=-1-2\times1=-3$
3. $\alpha^3+\beta^3=(\alpha+\beta)(\alpha^2+\beta^2-\alpha\beta)=(-1)\times(-1-1)=2$

VII. *សមីការ* $x^2+2x+3=0$ *មានឫស* $\alpha$ , $\beta$

តាមទ្រឹស្តីបទវ្យែត: $\begin{cases}\alpha+\beta=-\dfrac{b}{a}=-2\\ \alpha\beta=\dfrac{c}{a}=3\end{cases}$

គណនា:

1. $\alpha+\beta=-2$ 2. $\alpha\beta=3$ 3. $(1+\alpha)(1+\beta)=1+\beta+\alpha+\alpha\beta=1-2+3=2$

4. $\dfrac{1}{\alpha}+\dfrac{1}{\beta}=\dfrac{\beta+\alpha}{\alpha\beta}=-\dfrac{2}{3}$ 5. $\dfrac{1}{\alpha-1}+\dfrac{1}{\beta-1}=\dfrac{\beta-1+\alpha-1}{(\alpha-1)(\beta-1)}=\dfrac{\beta+\alpha-2}{\alpha\beta-(\alpha+\beta)+1}=\dfrac{-2-2}{3+2+1}=-\dfrac{2}{3}$

VIII. *សមីការ* $x^2-x+8=0$ *មានឫស* $\alpha$ , $\beta$

តាមទ្រឹស្តីបទវ្យែត: $\begin{cases}\alpha+\beta=-\dfrac{b}{a}=1\\ \alpha\beta=\dfrac{c}{a}=8\end{cases}$

គណនា:

1. $\frac{\beta}{1+\alpha^2}+\frac{\alpha}{1+\beta^2}=\frac{\beta(1+\beta^2)+\alpha(1+\alpha^2)}{(1+\alpha^2)(1+\beta^2)}=\frac{\beta+\beta^3+\alpha+\alpha^3}{1+(\alpha^2+\beta^2)+\alpha^2\beta^2}$

$$=\frac{\alpha+\beta+\left[(\alpha+\beta)(\alpha^2+\beta^2-\alpha\beta)\right]}{1+(\alpha^2+\beta^2)+\alpha^2\beta^2}=\frac{(\alpha+\beta)\left[1+(\alpha+\beta)^2-\alpha\beta-2\alpha\beta\right]}{1+\left[(\alpha+\beta)^2-2\alpha\beta\right]+\alpha^2\beta^2}$$

$$=\frac{1\times(1+1^2-3\times 8)}{1+\left[1^2-2\times 8\right]+8^2}=\frac{-22}{50}=-\frac{11}{25}$$

ដូចនេះ $\boxed{\frac{\beta}{1+\alpha^2}+\frac{\alpha}{1+\beta^2}=-\frac{11}{25}}$

2. $\alpha^4+\beta^4=(\alpha^2+\beta^2)^2-2\alpha^2\beta^2=\left[(\alpha^2+\beta)^2-2\alpha\beta\right]^2-2(\alpha\beta)^2$

$$=(1^2-2\times 8)^2-2\times 8^2=225-128=97$$

*So.* $\boxed{\alpha^4+\beta^4=97}$

IX. *បង្កើតសមីការដឺក្រេទី២*

ដោយ $\alpha$ , $\beta$ ជាឫសនៃសមីការ $x^2+2x+4=0$

តាមទ្រឹស្តីបទវ្យែត: $\begin{cases}\alpha+\beta=-\frac{b}{a}=-2\\ \alpha\beta=\frac{c}{a}=4\end{cases}$

1.សមីការមានឫស $\alpha+3$ & $\beta+3$

នាំឱ្យ $S=\alpha+3+\beta+3=\alpha+\beta+6=-2+6=4$

$P=(\alpha+3)(\beta+3)=\alpha\beta+3\alpha+3\beta+9=\alpha\beta+3(\alpha+\beta)+9=4+3(-2)+9=7$

សមីការដែលត្រូវរកគឺ: $X^2-SX+P=0$

ដូចនេះ $\boxed{X^2-4X+7=0 \text{ ជាសមីការដែលត្រូវរក}}$ ។

2.សមីការមានឫស $\alpha^2+1$ & $\beta^2+1$

នាំឱ្យ $S=\alpha^2+\beta^2+2=(\alpha+\beta)^2-2\alpha\beta+2=4-8+2=-2$

$P=(\alpha^2+1)(\beta^2+1)=\alpha^2\beta^2+\alpha^2+\beta^2+1=(\alpha\beta)^2+(\alpha+\beta)^2-2\alpha\beta+1=16+4-8+1=13$

សមីការដែលត្រូវរកគឺ: $X^2-SX+P=0$

ដូចនេះ $\boxed{X^2-2X+13=0 \text{ ជាសមីការដែលត្រូវរក}}$ ។

3.សមីការមានឫស $2\alpha+4$ & $2\beta+4$

នាំឱ្យ $S=2\alpha+2\beta+8=2(\alpha+\beta)+8=2(-2)+8=4$

$P=(2\alpha+4)(2\beta+4)=4\alpha\beta+8\alpha+8\beta+16=4\alpha\beta+8(\alpha+\beta)+16=16-16+16=16$

សមីការដែលត្រូវរកគឺ: $X^2-SX+P=0$

ដូចនេះ $\boxed{X^2-4X+16=0}$ ជាសមីការដែលត្រូវរក ។

4.សមីការមានឫស $2\alpha^2-1$ & $2\beta^2-1$

នាំឱ្យ $S=2\alpha^2+2\beta^2-2=2\left(\alpha^2+\beta^2\right)-2=2\left[\left(\alpha+\beta\right)^2-2\alpha\beta\right]-2=2\left[\left(-2\right)^2-8\right]-2=-10$

$P=\left(2\alpha^2-1\right)\left(2\beta^2-1\right)=4\alpha^2\beta^2-2\alpha^2-2\beta^2+1$

$=4\left(\alpha\beta\right)^2-2\left[\left(\alpha+\beta\right)^2-2\alpha\beta\right]+1=64-2\left[\left(-2\right)^2-8\right]+1=73$

សមីការដែលត្រូវរកគឺ: $X^2-SX+P=0$

ដូចនេះ $\boxed{X^2+10X-73=0}$ ជាសមីការដែលត្រូវរក ។

5.សមីការមានឫស $\frac{1}{\alpha}$ & $\frac{1}{\beta}$

នាំឱ្យ $S=\frac{1}{\alpha}+\frac{1}{\beta}=\frac{\alpha+\beta}{\alpha\beta}=\frac{-2}{4}=-\frac{1}{2}$

$P=\frac{1}{\alpha\beta}=\frac{1}{4}$

សមីការដែលត្រូវរកគឺ: $X^2-SX+P=0$

ឬ $X^2+\frac{1}{2}X+\frac{1}{4}=0$

ដូចនេះ $\boxed{4X^2+2X+1=0}$ ជាសមីការដែលត្រូវរក ។

6.សមីការមានឫស $\frac{1}{\alpha+1}$ & $\frac{1}{\beta+1}$

នាំឱ្យ $S=\frac{1}{\alpha+1}+\frac{1}{\beta+1}=\frac{\alpha+\beta+2}{\alpha\beta+\alpha+\beta+1}=\frac{-2+2}{4-2+1}=\frac{0}{3}=0$

$P=\frac{1}{\alpha+1}\times\frac{1}{\beta+1}=\frac{1}{\alpha\beta+\alpha+\beta+1}=\frac{1}{4-2+1}=\frac{1}{3}$

សមីការដែលត្រូវរកគឺ: $X^2-SX+P=0$

ដូចនេះ $\boxed{X^2+\frac{1}{3}=0}$ ជាសមីការដែលត្រូវរក ។

7.សមីការមានឫស $\frac{1}{\alpha^2-1}$ & $\frac{1}{\beta^2-1}$

នាំឱ្យ $S=\frac{1}{\alpha^2-1}+\frac{1}{\beta^2-1}=\frac{\alpha^2+\beta^2-2}{\alpha^2\beta^2-\alpha^2-\beta^2+1}$

$=\frac{\left[\left(\alpha+\beta\right)^2-2\alpha\beta\right]-2}{\left(\alpha\beta\right)^2-\left[\left(\alpha+\beta\right)^2-2\alpha\beta\right]+1}=\frac{4-8-2}{16-4+8+1}=\frac{-6}{21}=-\frac{2}{7}$

$$P=\frac{1}{\alpha^2-1}\times\frac{1}{\beta^2-1}=\frac{1}{\alpha^2\beta^2-\alpha^2-\beta^2+1}=\frac{1}{(\alpha\beta)^2-\left[(\alpha+\beta)^2-2\alpha\beta\right]+1}=\frac{1}{16-4+8+1}=\frac{1}{21}$$

សមីការដែលត្រូវរកគឺ: $X^2-SX+P=0$

ដូចនេះ $\boxed{X^2+\frac{2}{7}X+\frac{1}{21}=0 \text{ ឬ } 21X^2+6X+1=0 \text{ ជាសមីការដែលត្រូវរក}}$ ។

*បញ្ជាក់:* ក្នុងលំហាត់នេះដើម្បីងាយស្រួលក្នុងការដោះស្រាយយើងគួរ រក $\alpha^2+\beta^2$ & $(\alpha\beta)^2$ ទុកឱ្យហើយ ខាងលើទើបងាយស្រួល ។ ម្យ៉ាងទៀតយើងអាចដោះស្រាយរកតម្លៃ $\alpha,\beta$ ជាមុន ជាតម្លៃលេខរួចយកទៅ ជួសក្នុងឫសនីមួយៗនៃសមីការថ្មីជាការស្រេច ( ប៉ុន្តែវិធីនេះបើអាចសូមកុំប្រើល្អជាង ព្រោះ បើធ្វើតាមនេះ គេអាចកាត់ពិន្ទុ ) ។

## X. *រកតម្លៃ$k$ ដើម្បីឱ្យសមីការមានឫសឌុប ហើយរកឫសឌុបនោះ ៖*

1. $(k-2)x^2+(3k-6)x+2k-3=0$

លក្ខខណ្ឌ $k-2\neq 0 \Rightarrow k\neq 2$

យើងមាន: $\Delta=(3k-6)^2-4(k-2)(2k-3)$

$=9k^2-36k+36-4(2k^2-7k+6)$

$=9k^2-36k+36-8k^2+28k-24$

$=k^2-8k+12$

ដើម្បីឱ្យសមីការមានឫសឌុបលុះត្រាតែ:

$$\Delta=0$$

$$k^2-8k+12=0$$

$$(k-6)(k-2)=0$$

នាំឱ្យ: $\begin{cases}k-6=0\\k-2=0\end{cases}$ ឬ $\begin{cases}k=6\\k=2\end{cases}$ (ប៉ុន្តែ $k=2$ មិនយក)

ឫសឌុបនៃសមីការគឺ $x_1=x_2=-\frac{b}{2a}=-\frac{3k-6}{2(k-2)}$

បើ $k=6\Rightarrow x_1=x_2=-\frac{18-6}{2(6-2)}=-\frac{12}{8}=-\frac{3}{2}$

ដូចនេះ $\boxed{\text{សមីការមានឫសឌុបកាលណា } k=6 \text{ ហើយឫសឌុបនោះគឺ } x_1=x_2=-\frac{3}{2}}$ ។

2. $4x^2-2kx+k+3=0$

ដើម្បីឱ្យសមីការមានឫសឌុបកាលណា: $\Delta'=0$

តែ $\Delta'=(-k)^2-4(k+3)$

$=k^2-4k-12$

នាំឱ្យ: $k^2-4k-12=0$

$(k-6)(k+2)=0$

នោះ $\begin{cases} k-6=0 \\ k+2=0 \end{cases} \Rightarrow \begin{cases} k=6 \\ k=-2 \end{cases}$

ឫសឌុបរបស់សមីការគឺ $x_1 = x_2 = -\frac{b'}{a} = \frac{k}{4}$

បើ: $k=-2 \Rightarrow x_1 = x_2 = \frac{-2}{4} = -\frac{1}{2}$

បើ: $k=6 \Rightarrow x_1 = x_2 = \frac{6}{4} = \frac{3}{2}$

ដូចនេះ: សមីការមានឫសឌុបកាលណា $k=-2 \vee k=6$ ហើយឫសឌុបនោះគឺ $x_1 = x_2 = -\frac{1}{2} \vee x_1 = x_2 = \frac{3}{2}$ ។

3. $(k+1)x^2 - (k+3)x + 3 - k = 0$ លក្ខខណ្ឌ $k+1 \neq 0 \Leftrightarrow k \neq -1$

ដើម្បីឱ្យសមីការមានឫសឌុបលុះត្រាតែ: $\Delta = 0$

$$\left[-(k+3)\right]^2 - 4(k+1)(3-k) = 0$$

$$k^2 + 6k + 9 - 4\left(3k - k^2 + 3 - k\right) = 0$$

$$k^2 + 6k + 9 + 4k^2 - 8k - 12 = 0$$

$$5k^2 - 2k - 3 = 0$$

$$(5k+3)(k-1) = 0$$

$$\begin{cases} 5k+3=0 \\ k-1=0 \end{cases} \Leftrightarrow \begin{cases} k=-\frac{3}{5} \\ k=1 \end{cases}$$

ឫសឌុបរបស់សមីការកំណត់ដោយ: $x_1 = x_2 = -\frac{b}{2a} = \frac{k+3}{2(k+1)}$

បើ: $k=-\frac{3}{5} \Rightarrow x_1 = x_2 = \frac{-\frac{3}{5}+3}{2\left(-\frac{3}{5}+1\right)} = \frac{\frac{12}{5}}{\frac{4}{5}} = \frac{12}{4} = 3$

$k=1 \Rightarrow x_1 = x_2 = \frac{1+3}{2(1+1)} = \frac{4}{4} = 1$

ដូចនេះ: $k=-\frac{3}{5}$ ឬ $k=1$ នាំឱ្យសមីការមានឫសឌុប ហើយឫសឌុបនោះគឺ $x_1 = x_2 = 3$ ឬ $x_1 = x_2 = 1$ ។

4. $kx^2 + 3(k+2)x + 3k - 1 = 0$ លក្ខខណ្ឌ $k \neq 0$

មាន: $\Delta = \left[3(k+2)\right]^2 - 4k(3k-1)$

$= 9\left(k^2 + 4k + 4\right) - 12k^2 + 4k$

$= -3k^2 + 40k + 36$

ដើម្បីឱ្យសមីការមានឫសឌុបលុះត្រាតែ: $\Delta = 0$

$$-3k^2 + 40k + 36 = 0$$

$$\Delta' = (20)^2 - (-3) \times 36$$

$$= 400 + 108 = 508$$

$$\Rightarrow \sqrt{\Delta'} = \sqrt{508} = 2\sqrt{127}$$

នាំឱ្យ: $k_1=\frac{-20-2\sqrt{127}}{-3}=\frac{20+2\sqrt{127}}{3}$ , $k_2=\frac{-20+2\sqrt{127}}{-3}=\frac{20-2\sqrt{127}}{3}$

ឫសឌុបនៃសមីការគឺ: $x_1=x_2=-\frac{b}{2a}=-\frac{3(k+2)}{2k}$

បើ: $k=\frac{20+2\sqrt{127}}{3}$ នោះ $x_1=x_2=-\frac{3\left(\frac{20+2\sqrt{127}}{3}+2\right)}{2\left(\frac{20+2\sqrt{127}}{3}\right)}=-\frac{3\left(13+\sqrt{127}\right)}{2\left(10+\sqrt{127}\right)}$

$k=\frac{20-2\sqrt{127}}{3}$ នោះ $x_1=x_2=-\frac{3\left(\frac{20-2\sqrt{127}}{3}+2\right)}{2\left(\frac{20-2\sqrt{127}}{3}\right)}=-\frac{3\left(13-\sqrt{127}\right)}{2\left(10-\sqrt{127}\right)}$

ដូចនេះ: $\left(k=\frac{20+2\sqrt{127}}{3}\vee k=\frac{20-2\sqrt{127}}{3}\right)$ នាំឱ្យសមីការមានឫសឌុប ហើយ

ឫសឌុបនោះគឺ: $x_1=x_2=-\frac{3\left(13+\sqrt{127}\right)}{2\left(10+\sqrt{127}\right)}$ ឬ $x_1=x_2=-\frac{3\left(13-\sqrt{127}\right)}{2\left(10-\sqrt{127}\right)}$ ។

5. $(k-3)x^2+(2k-1)x+2k-3=0$ លក្ខខណ្ឌ $k\neq 3$

មាន: $\Delta_x=(2k-1)^2-4(k-3)(2k-3)$

$=4k^2-4k+1-4\left(2k^2-9k+9\right)$

$=4k^2-4k+1-8k^2+36k-36$

$=-4k^2+32k-35$

ដើម្បីឱ្យសមីការមានឫសឌុបលុះត្រាតែ: $\Delta_x=0$

$-4k^2+32k-35=0$

មាន: $\Delta_k'=16^2-(-4)(-35)$

$=256-140=116>0$

$\Rightarrow \sqrt{\Delta_k'}=\sqrt{116}=2\sqrt{29}$

នោះ $k_1=\frac{-16-2\sqrt{29}}{-4}=\frac{8+\sqrt{29}}{2}\vee k_2=\frac{-16+2\sqrt{29}}{-4}=\frac{8-\sqrt{29}}{2}$

គេបានឫសឌុបនៃសមីការគឺ: $x_1=x_2=-\frac{b}{2a}=-\frac{2k-1}{2(k-3)}$

បើ: $k=\frac{8+\sqrt{29}}{2}$ នោះ $x_1=x_2=-\frac{2\left(\frac{8+\sqrt{29}}{2}\right)-1}{2\left(\frac{8+\sqrt{29}}{2}-3\right)}=-\frac{7+\sqrt{29}}{2+\sqrt{29}}$

$k=\frac{8-\sqrt{29}}{2}$ នោះ $x_1=x_2=-\frac{2\left(\frac{8-\sqrt{29}}{2}\right)-1}{2\left(\frac{8-\sqrt{29}}{2}-3\right)}=-\frac{7-\sqrt{29}}{2-\sqrt{29}}$

ដូចនេះ $\left(k=\frac{8+\sqrt{29}}{2}\vee k=\frac{8-\sqrt{29}}{2}\right)$ ធ្វើឱ្យសមីការមានឫសឌុប ហើយ ឫសឌុបនោះគឺ: $x_1=x_2=-\frac{7+\sqrt{29}}{2+\sqrt{29}}$ ឬ $x_1=x_2=-\frac{7-\sqrt{29}}{2-\sqrt{29}}$ ។

XI. ដោះស្រាយសមីការខាងក្រោម:

1. $\frac{x+1}{x-1}-\frac{x-5}{x-3}=0$

ល/ខ: $\begin{cases}x-1\neq 0\\ x-3\neq 0\end{cases}\Leftrightarrow\begin{cases}x\neq 1\\ x\neq 3\end{cases}$

នោះ $\frac{(x+1)(x-3)-(x-5)(x-1)}{(x-1)(x-3)}=0$

$x^2-2x-3-x^2+6x-5=0$

$4x-8=0$

$\Rightarrow x=\frac{8}{4}=2$

ដូចនេះ $x=2$ ជាឫសសមីការ ។

2. $\frac{4x-1}{x-1}+\frac{4x+1}{1-x}=\frac{9}{4}$

ល/ខ: $x-1\neq 0\Leftrightarrow x\neq 1$

នោះ $\frac{4(4x-1-4x-1)}{4(x-1)}=\frac{9(x-1)}{4(x-1)}$

$-8=9x-9$

$9x=1$

$\Rightarrow x=\frac{1}{9}$

ដូចនេះ $x=\frac{1}{9}$ ជាឫសសមីការ ។

3. $\frac{x}{x-3}-\frac{2}{x+3}=1$

ល/ខ: $\begin{cases}x-3\neq 0\\ x+3\neq 0\end{cases}\Leftrightarrow\begin{cases}x\neq 3\\ x\neq -3\end{cases}$

$\frac{x(x+3)-2(x-3)}{(x-3)(x+3)}=\frac{(x+3)(x-3)}{(x+3)(x-3)}$

$x^2+3x-2x+6=x^2-9$

$x^2-x^2+x=-9-6$

$x=-15$

ដូចនេះ $x=-15$ ជាឫសរបស់សមីការ ។

4. $\frac{x+3}{x-1}-\frac{2x-3}{x+5}=\frac{10-x^2}{(x-1)(x+5)}$

ល/ខ: $\begin{cases}x-1\neq 0\\ x+5\neq 0\end{cases}\Leftrightarrow\begin{cases}x\neq 1\\ x\neq -5\end{cases}$

$\frac{(x+3)(x+5)-(2x-3)(x-1)}{(x+5)(x-1)}=\frac{10-x^2}{(x-1)(x+5)}$

$x^2+8x+15-2x^2+5x-3=10-x^2$

$13x=-2$

$x=-\frac{2}{13}$

ដូចនេះ $x=-\frac{2}{13}$ ជាឫសរបស់សមីការ ។

5. $\frac{9x^2-25}{(x+2)(3x+5)}=0$

ល/ខ: $\begin{cases}x+2\neq 0\\ 3x+5\neq 0\end{cases}\Leftrightarrow\begin{cases}x\neq -2\\ x\neq -\frac{5}{3}\end{cases}$

$9x^2-25=0$

$9x^2=25$

$x^2=\frac{25}{9}$

$\Rightarrow x=\pm\sqrt{\frac{25}{9}}=\pm\frac{5}{3}$

6. $\frac{(x-2)(x-1)}{2x-4}+\frac{1}{2}=0$

ល/ខ: $2x-4\neq 0\Rightarrow x\neq 2$

$\frac{(x-2)(x-1)+(x-2)}{2(x-2)}=0$

$x^2-3x+2+x-2=0$

$x^2-2x=0$

$x(x-2)=0$

នោះ $\begin{cases} x = \frac{5}{3} \\ x = -\frac{5}{3} \text{ (មិនយក)} \end{cases}$

ដូចនេះ $\boxed{x = \frac{5}{3} \text{ ជាឫសរបស់សមីការ}}$ ។

នោះ $\begin{cases} x = 0 \\ x = 2 \text{ (មិនយក)} \end{cases}$

ដូចនេះ $\boxed{x = 0 \text{ ជាឫសរបស់សមីការ}}$ ។

7. $\frac{2}{5x} - \frac{6}{3x} = 1 - \frac{7}{15x}$

លខ: $x \neq 0$

$\frac{6-30}{15x} = \frac{15x-7}{15x}$

$-24 = 15x - 7$

$x = -\frac{17}{15}$

ដូចនេះ $\boxed{x = -\frac{17}{15} \text{ ជាឫសរបស់សមីការ}}$ ។

8. $\frac{3}{x} - \frac{8}{3x} + \frac{4}{5x} = \frac{1}{15}$

លខ: $x \neq 0$

$\frac{45-40+12}{15x} = \frac{x}{15x}$

$x = 17$

ដូចនេះ $\boxed{x = 17 \text{ ជាឫសរបស់សមីការ}}$ ។

9. $\frac{-\frac{3}{4}}{2x-1} = \frac{\frac{1}{3}}{\frac{8x}{5}}$

លខ: $\begin{cases} 2x-1 \neq 0 \\ 8x \neq 0 \end{cases} \Leftrightarrow \begin{cases} x \neq \frac{1}{2} \\ x \neq 0 \end{cases}$

$-\frac{3}{4(2x-1)} = \frac{5}{24x}$

$-3 \times 24x = 20(2x-1)$

$-72x = 40x - 20$

$112x = 20$

$x = \frac{20}{112} = \frac{5}{28}$

ដូចនេះ $\boxed{x = \frac{5}{28} \text{ ជាឫសសមីការ}}$ ។

10. $\frac{3x-4}{x-2} + \frac{3-x}{3+x} = \frac{2x^2+x}{(x-2)(3+x)}$

លខ: $\begin{cases} x-2 \neq 0 \\ x+3 \neq 0 \end{cases} \Leftrightarrow \begin{cases} x \neq 2 \\ x \neq -3 \end{cases}$

$\frac{(3x-4)(3+x)+(3-x)(x-2)}{(x-2)(3+x)} = \frac{2x^2+x}{(x-2)(3+x)}$

$5x + 3x^2 - 12 + 5x - 6 - x^2 = 2x^2 + x$

$3x^2 - 3x^2 + 10x - x = 12 + 6$

$9x = 18$

$x = \frac{18}{9} = 2$ (មិនយក)

ដូចនេះ $\boxed{\text{សមីការគ្មានឫស}}$ ។

11. $\frac{3}{x + \frac{1}{1 + \frac{x+1}{3-x}}} = x - 1$ លខ: $3 - x \neq 0 \Rightarrow x \neq 3$

$\frac{3}{x + \frac{1}{1 + \frac{x+1}{3-x}}} = x - 1$

$\Leftrightarrow \frac{3}{x + \frac{1}{\frac{3-x+x+1}{3-x}}} = x - 1$

$\Leftrightarrow \frac{3}{x + \frac{3-x}{4}} = x - 1$

$$\Leftrightarrow \frac{3}{\frac{4x+3-x}{4}}=x-1$$

$$\Leftrightarrow \frac{12}{3x+3}=x-1$$

$$\Leftrightarrow 4=(x-1)(x+1)$$

$$\Leftrightarrow x^2-1=4 \Rightarrow x^2=5 \vee x=\pm\sqrt{5}$$

ដូចនេះ $\boxed{x=\pm\sqrt{5} \text{ ជាឫសនៃសមីការ}}$ ។

XII. *ដោះស្រាយសមីការ:*

1. $4^x.16^{3x-1}=8$

$2^{2x}.2^{4(3x-1)}=2^3$

$2^{2x+12x-4}=2^3$

$\Leftrightarrow 14x-4=3$

$14x=7$

$\Rightarrow x=\frac{7}{14}=\frac{1}{2}$

ដូចនេះ $\boxed{x=\frac{1}{2} \text{ ជាឫសនៃសមីការ}}$ ។

2. $\frac{4^{x+1}}{8^{x-1}}=16^x$

$\frac{2^{2(x+1)}}{2^{3(x-1)}}=2^{4x}$

$2^{2x+2-3x+3}=2^{4x}$

$-x+5=4x$

$5x=5$

$\Rightarrow x=\frac{5}{5}=1$

ដូចនេះ $\boxed{x=1 \text{ ជាឫសនៃសមីការ}}$ ។

3. $\left(2^{2016}-2^{2015}\right)\left(2^{2017}-2^{2016}\right)=8^x$

$2^{2015}(2-1).2^{2016}(2-1)=8^x$

$2^{2015+2016}=2^{3x}$

$3x=4031$

$\Rightarrow x=\frac{4031}{3}$

ដូចនេះ $\boxed{x=\frac{4031}{3} \text{ ជាឫសនៃសមីការ}}$ ។

4. $\left[2\left(2^{\sqrt{x}+1}\right)^{\frac{1}{2}}\right]^{\frac{2}{\sqrt{x}-2}}=4$ លខ: $x\geq 0$ , $x\neq 4$

$\left(2.2^{\frac{\sqrt{x}+1}{2}}\right)^{\frac{2}{\sqrt{x}-2}}=4 \Leftrightarrow \left(2^{1+\frac{\sqrt{x}+1}{2}}\right)^{\frac{2}{\sqrt{x}-2}}=4$

ឬ $\left(2^{\frac{2+\sqrt{x}+1}{2}}\right)^{\frac{2}{\sqrt{x}-2}}=2^2 \Leftrightarrow 2^{\frac{2(\sqrt{x}+3)}{2(\sqrt{x}-2)}}=2^2$

ឬ $\frac{\sqrt{x}+3}{\sqrt{x}-2}=2 \Leftrightarrow \sqrt{x}+3=2\sqrt{x}-4$

ឬ $\sqrt{x}=7 \Rightarrow x=49$

ដូចនេះ $\boxed{x=49 \text{ ជាឫសនៃសមីការ}}$ ។

5. $\left(\frac{1}{5}\right)^{-x-\frac{1}{x}+\frac{3}{2}}=5\sqrt{5}$ លខ: $x\neq 0$

$5^{x+\frac{1}{x}-\frac{3}{2}}=5.5^{\frac{1}{2}}$

ព្រោះ $\left(\frac{a}{b}\right)^n=\left(\frac{b}{a}\right)^{-n}$ , $\sqrt[n]{a^m}=a^{\frac{m}{n}}$

$5^{\frac{2x^2+2-3x}{2x}}=5^{1+\frac{1}{2}}$

$5^{\frac{2x^2+2-3x}{2x}} = 5^{\frac{3}{2}} \Leftrightarrow \frac{2x^2-3x+2}{2x} = \frac{3}{2}$

$4x^2-6x+4=6x$

$4x^2-12x+4=0$

$4\left(x^2-3x+1\right)=0$ ឬ $x^2-3x+1=0$

- របៀបទី1 $x^2-3x+1=0$

$x^2-3x+\left(\frac{3}{2}\right)^2-\frac{9}{4}+1=0$

$\left(x-\frac{3}{2}\right)^2-\frac{5}{4}=0 \Leftrightarrow \left(x-\frac{3}{2}\right)^2=\frac{5}{4}$

$x-\frac{3}{2}=\pm\frac{\sqrt{5}}{2} \Rightarrow x=\frac{3\pm\sqrt{5}}{2}$

- របៀបទី2 $x^2-3x+1=0$

មាន: $\Delta=(-3)^2-4.1.1=5>0$

$\Rightarrow \sqrt{\Delta}=\sqrt{5}$ នោះ $x_{1,2}=\frac{3\pm\sqrt{5}}{2}$ ជាឫសសមីការ

ដូចនេះ: $x=\frac{3\pm\sqrt{5}}{2}$ ជាឫសនៃសមីការ ។

6. $4^x-5\times2^{x+4}+1024=0$

$2^{2x}-5\times2^x\times2^4+1024=0$

$\left(2^x\right)^2-80\times2^x+1024=0$

តាង: $t=2^x$ , $t>0$

សមីការទៅជា: $t^2-80t+1024=0$

មាន: $\Delta'=(-40)^2-1\times1024$

$=1600-1024=576>0$

$\Rightarrow \sqrt{\Delta'}=\sqrt{576}=24$

នាំឱ្យ: $t_1=\frac{40-24}{1}=16$ , $t_2=\frac{40+24}{1}=64$

បើ: $t=16 \Leftrightarrow 2^x=16$

$2^x=2^4$

$\Rightarrow x=4$

បើ: $t=64 \Leftrightarrow 2^x=64$

$2^x=2^6 \Rightarrow x=6$

ដូចនេះ: $x=4 \vee x=6$ ជាឫសនៃសមីការ ។

7. $3\times4^{x+1}+6^{x+1}=18\times9^x$

$3\times4^x\times4+6^x\times6=18\times9^x$

$12\times4^x+6\times6^x=18\times9^x$

ចែកអង្គទាំងពីរនឹង $9^x$ យើងបាន:

$12\times\frac{4^x}{9^x}+6\times\frac{6^x}{9^x}=18\times\frac{9^x}{9^x}$

